ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាភូមិន្ទរដ្ឋបាល

នាយកដ្ឋានបណ្តុះបណ្តាលដំបូង

សិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១៣

# សង្ខេបមេរៀន

# ការគ្រប់គ្រងគម្រោង

**ឧទ្ទេសនាមដោយ៖** **លោកស្រីបណ្ឌិត ព្រុំ ទេវី**

*រៀបរៀងដោយ៖* *លោក ស៊ីលី សុវណ្ណនី*

(ជំនាញ៖ រដ្ឋបាលសាធារណៈ)

ឆ្នាំសិក្សា ២០២៥-២០២៧

# អារម្ភកថា

គម្រោងគឺជាការងារអនុវត្តស្របទៅតាមធនធាន និងមានរយៈពេលកំណត់មួយច្បាស់លាស់ ដើម្បីឱ្យសម្រេចបាននូវលទ្ធផលដែលជាគោលបំណងបានរំពឹងទុកជាមុន។ ដូចគ្នានេះដែរ នៅក្នុងស្ថាប័នសាធារណៈអាចមានគម្រោងជាច្រើនត្រូវបានដាក់ឱ្យដំណើរអនុវត្តសម្រាប់បំពេញនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋដូចជា ការកសាងនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ផ្លូវ ស្ពាន អគារ ប្រឡាយជាដើម) ការអប់រំបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ការអភិវឌ្ឍសហគមន៍ និងសកម្មភាពសង្គមផ្សេងៗជាដើម។ ដូចនេះហើយ ដើម្បីទទួលបានជោគជ័យគឺទាមទាឱ្យមានការយល់ដឹងច្បាស់លាស់អំពីដំណើរការនៃការធ្វើផែនការ និងការគ្រប់គ្រងគម្រោងនៅពេលអនុវត្តការងារ។

នៅក្នុងសៀវភៅនេះបានចងក្រងនូវខ្លឹមសារមេរៀនសង្ខេបមុខវិជ្ជា«ការគ្រប់គ្រងគម្រោង»ដែលត្រូវបានដាក់ឱ្យសិក្សានៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់សិស្សមន្ត្រីជាន់ខ្ពស់ ជំនាន់ទី១៣ ជំនាញរដ្ឋបាលសាធារណៈ នៃសាលាភូមិន្ទរដ្ឋបាល។ មេរៀនទាំងអស់នេះសុទ្ធសឹងតែសម្រាប់ជាទន់ ជំនួយដល់សិស្សមន្ត្រីក្នុងការយកទៅអនុវត្តដើម្បីបម្រើដល់ការងារនៅក្នុងស្ថាប័នសាធារណៈសម្រាប់ជាប្រយោជន៍ដល់សង្គមជាតិ។ ជាពិសេសនៅក្នុងជំនាន់នេះ សិស្សមន្ត្រីជាន់ខ្ពស់ទាំងអស់នឹងចេញទៅបម្រើការងារជាមន្ត្រីរាជការនៅតាមបណ្តារដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី ខេត្ត) ដែលនៅកៀកនឹងមូលដ្ឋាន ដូចនេះនឹងអាចមើលឃើញកាន់តែច្បាស់អំពីតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។ ដើម្បីបំពេញបន្ថែមនូវតម្រូវការទាំងអស់នោះបាន ក្នុងនាមជាមន្ត្រីរាជការអាចនឹងផ្តួចផ្តើមដឹកនាំ គ្រប់គ្រងគម្រោងការងារដោយកំណត់គោលបំណងជាក់លាក់សម្រាប់ការអភិវឌ្ឍមូលដ្ឋានតាមរយៈគម្រោងរបស់រដ្ឋាភិបាល ដៃគូអភិវឌ្ឍ ឬសប្បុរសជនផ្សេងៗដែលបានជួយជ្រោមជ្រែង។

សូមគោរព និងថ្លែងអំណរគុណជាពិសេស ដោយស្មោះអស់ពីដួងចិត្តជូនចំពោះអ្នកស្រីសាស្ត្រាចារ្យបណ្ឌិត **ព្រុំ ទេវី** សមាជិកពេញសិទ្ធនៃរាជបណ្ឌិត្យសភាកម្ពុជា ដែលបានផ្តល់នូវគំនិតដឹកនាំ បទពិសោធន៍ និងចំណេះដឹងដ៏ថ្លៃថ្លា អំពីការគ្រប់គ្រងគម្រោងដល់យើងខ្ញុំជាសិស្សមន្ត្រីជាន់ខ្ពស់ទាំងអស់ ដើម្បីជាពុទ្ធិយកទៅបម្រើការងារ សម្រាប់ជាប្រយោជន៍ជាតិ និងប្រជាពលរដ្ឋ។ ខ្ញុំបាទសូមគោរពជូនពរអ្នកគ្រូ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃពុធ ២រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័កព.ស២៥៦៩

រាជធានីភ្នំពេញ, ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២៦

**អ្នករៀបរៀង**

**ស៊ីលី សុវណ្ណានី**

បានឃើញ និងឯកភាព

**គ្រូឧទ្ទេស**

**បណ្ឌិត ព្រុំ ទេវី**

# មាតិកា

**អារម្ភកថា**

**មេរៀនទី១ គម្រោងនាពេលបច្ចុប្បន្ន**..........1

**១. និយមន័យ**..........1

*១.១. គោលបំណងនៃគម្រោង*..........1

*១.២. គោលដៅរបស់គម្រោង*..........2

*១.៣. សកម្មភាពរបស់គម្រោង*..........2

**២. ប្រភេទគម្រោង**..........2

**៣. វដ្តនៃគម្រោង**..........4

**៤. ហានិភ័យរបស់គម្រោង**..........5

**មេរៀនទី២ អ្នកគ្រប់គ្រងគម្រោង**..........7

**១. លក្ខណៈសម្បត្តិអ្នកគ្រប់គ្រង**..........7

*១.១. កិត្តិយស*..........8

*១.២. ភាពឆាប់យល់ដឹង*..........8

*១.៣. របនាបទដឹកនាំ និងគ្រប់គ្រង*..........8

*១.៤. សមត្ថភាពដោះស្រាយភាពតានតឹង*..........9

**២. ការប្រៀបធៀបរវាងការគ្រប់គ្រងគម្រោង និងប្រធានគម្រោង**..........9

*២.១. អ្នកគ្រប់គ្រងផ្នែកជំនាញ និងអ្នកគ្រប់គ្រងគម្រោង*..........9

*២.២. ភារកិច្ចអ្នកគ្រប់គ្រងគម្រោង*..........10

**៣. ការទទួលខុសត្រូវគម្រោង**..........11

*៣.១. ការទទួលខុសត្រូវទៅនឹងស្ថាប័នអាណាព្យាបាល*..........11

*៣.២. ការទួលខុសត្រូវទៅនឹងគម្រោងនិងអតិថិជន*..........11

*៣.៣. ការទទួលខុសត្រូវទៅនឹងក្រុមការងារគម្រោង*..........11

**៤. គម្រូចការពិសេសនៃអ្នកគ្រប់គ្រងគម្រោង** ........ 11

*៤.១. ការទទួលបានផលជានសមល្មម* ........ 12

*៤.២. ការទទួលបាន និងជំរុញបុគ្គលិក* ........ 12

*៤.៣. ភាពអត់ធ្មត់ក្នុងការដោះស្រាយបញ្ហា* ........ 12

*៤.៤. បែងចែកបំណាងរបស់គម្រោង* ........ 13

**មេរៀនទី៣ ការចាត់ចែងគម្រោង** ........ 14

**១. រចនាសម្ព័ន្ធតាមបែបជំនាញ** ........ 14

*១.១. គុណសម្បត្តិ* ........ 14

*១.២. គុណវិបត្តិ* ........ 15

**២. ការចាត់ចែងគម្រោងតាមផលិតផល** ........ 15

*២.១. គុណសម្បត្តិ* ........ 16

*២.២. គុណវិបត្តិ* ........ 16

**៣. ការចាត់ចែងគម្រោងបែបខ្វែង** ........ 17

*៣.១. គុណសម្បត្តិ* ........ 17

*៣.២. គុណវិបត្តិ* ........ 18

**៤. ប្រព័ន្ធចាត់ចែងបែបចម្រុះ** ........ 18

**៥. ការជ្រើសរើសទម្រង់ចាត់ចែង** ........ 18

**៦. ក្រុមអនុវត្តគម្រោង** ........ 19

**មេរៀនទី៤ ការធ្វើផែនការគម្រោង** ........ 20

**១. សមាសធាតុចូលរួមក្នុងការរៀបចំផែនការ** ........ 20

*១.១. គំនិត* ........ 20

*១.២. បរិបទ* ........ 21

*១.៣. ជំនួយ* ........ 21

*១.៤. ធនធានមនុស្ស* ........ 22
*១.៥. ទម្រង់* ........ 22
*១.៦. ពេលវេលា* ........ 22
**២. ដំណើរការរៀបចំផែនការគម្រោង** ........ 22
*២.១. សំណើគម្រោង* ........ 23
*២.២. ឯកសារគម្រោង* ........ 23
**មេរៀនទី៥ ការរៀបចំគម្រោងថវិកា** ........ 25
**១. និយមន័យនិងគោលការណ៍បន្ទុកចំណាយមួយចំនួន** ........ 25
**២. ការប៉ាន់ស្មានថវិកាគម្រោង** ........ 26
*២.១. ការរៀបចំថវិកាពីថ្នាក់លើចុះក្រោម* ........ 26
*២.២. ការរៀបចំថវិកាពីថ្នាក់ក្រោមឡើងលើ* ........ 27
*២.៣. ការរៀបថវិកាផ្អែកលើសកម្មភាព* ........ 28
*២.៤. ការរៀបចំថវិកាសមិទ្ធកម្ម* ........ 28
**មេរៀនទី៦ ការរៀបចំគម្រោងពេលវេលា** ........ 30
**១. បរិយាកាសនៃការរៀបចំគម្រោងពេលវេលា** ........ 30
*១.១. កត្តាខាងក្រៅ* ........ 30
*១.២. កត្តាការងារ* ........ 31
*១.៣. កត្តារួមចំណែកជាមួយលទ្ធផល* ........ 31
**២. រចនាសម្ព័ន្ធបំបែកការងារ** ........ 32
**៣. ការប្រើប្រាស់តារាង** ........ 32
*៣.១. តារាងខ្វែង និងតារាងពេល* ........ 32
*៣.២. ជំហាននៃការរៀបចំតារាងពេល* ........ 32
*៣.៣. តារាងហ្គិន* ( Gantt Chart ) ........ 33

*៣.៤. ជំហាននៃការរៀបចំតារាងហ្គិន* ........................................ 33
**មេរៀនទី៧ ការរៀបចំផែនការធនធាន** ........................................ 34
**១. ប្រភេទផ្សេងៗរបស់ធនធាន** ........................................ 34
*១.១. ធនធានមិនអាចជំនួសបាន* ........................................ 34
*១.២. ធនធានអាចបន្ថែមបាន* ........................................ 34
*១.៣. ធនធានអាចប្រើឡើងវិញបាន* ........................................ 34
**២. ករណីសិក្សា៖ គម្រោងសង់យានដ្ឋាន** ........................................ 35
*២.១. និយមន័យ-គម្រោងយានដ្ឋាន* ........................................ 35
*២.២. តារាងហ្គិន* ........................................ 35
**៣. គោលការណ៍អាទិភាពមូលដ្ឋានសម្រាប់រៀបចំផែនការធនធាន** ........................................ 38
*៣.១. គម្រោងពេលវេលាមានធនធានកំណត់* ........................................ 38
*៣.២. គម្រោងពេលវេលាមានពេលកំណត់* ........................................ 38
*៣.៣. វិធីសាស្ត្រដើម្បីសម្រួលការដាក់ដែនកំណត់លើធនធាន និងពេល* ........................................ 39
**មេរៀនទី៨ ការរៀបចំផែនការសម្រាប់ការតាមដាននិងវាយតម្លៃ** ........................................ 40
**១. តើអ្វីទៅជាការតាមដាន និងវាយតម្លៃ?** ........................................ 40
**២. ពេលនៃការតាមដាន និងវាយតម្លៃ** ........................................ 41
**៣. ការសិក្សា និងរៀបចំគម្រោងផែនការតាមដាន និងវាយតម្លៃ** ........................................ 41
*៣.១. ការសិក្សាអំពីតារាងតក្កភាព* ........................................ 42
*៣.២. ជំហាននៃការតាមដាន និងវាយតម្លៃ* ........................................ 42
**៤. ការប្រមូលទិន្នន័យ** ........................................ 43
**៥. របាយការណ៍** ........................................ 43
**មេរៀនទី៩ ការបញ្ចប់គម្រោង** ........................................ 45
**១. ប្រភេទផ្សេងៗនៃការបញ្ចប់គម្រោង** ........................................ 45

*១.១. ការបញ្ចប់គម្រោងដោយដំណើរអស់ទៅ*......45

*១.២. ការបញ្ចប់ដោយបន្ថែម*......45

*១.៣. ការបញ្ចប់ដោយសមាហរណកម្ម*......46

*១.៤. ការបញ្ចប់ដោយផ្ដាច់ការផ្គត់ផ្គង់*......46

**២. ដំណើរការបញ្ចប់គម្រោង**......46

**៣. របាយការណ៍បញ្ចប់ - ប្រវត្តិគម្រោង**......47

*៣.១. ការស្ដែងឡើងរបស់គម្រោង*......47

*៣.២. ការស្ដែងឡើងរបស់រដ្ឋបាល*......47

*៣.៣. រចនាសម្ព័ន្ធចាត់ចែង*......47

*៣.៤. ក្រុមការងារគម្រោង និងរដ្ឋបាល*......48

*៣.៥. បច្ចេកទេសគ្រប់គ្រងគម្រោង*......48

**ឯកសារយោង**......49

**ឧបសម្ព័ន្ធ**

# មេរៀនទី១ គម្រោងនាពេលបច្ចុប្បន្ន

## ១. និយមន័យ

គម្រោងគឺជាការខំប្រឹងប្រែងបណ្តោះអាសន្នមួយមានគោលបំណងមួយច្បាស់លាស់ដើម្បីបង្កើតផលិតផល ឬសេវាកម្មដោយប្រើប្រាស់ ធនធានហិរញ្ញវត្ថុនិងធនធានរូបសាស្ត្រដោយកំណត់ក្នុងរយៈពេលកំណត់មួយ។ ឬម្យ៉ាងទៀត គម្រោងគឺជាប្រតិបត្តិការមួយឬមួយលើកត្រូវបានរៀបចំដើម្បីសម្រេចគោលដៅទាំងឡាយដែលមានទំនាក់ទំនងជាមួយគ្នាក្នុងពេលកំណត់មួយ ហើយប្រើធនធានកំណត់ដែរ។

លទ្ធផលគម្រោងជាច្រើនដែលយើងអាចមើលឃើញនៅក្នុងពេល ឬស្នាដៃផ្សេងៗនៅក្នុងវិស័យយោធា។ ក្នុងវិស័យយោធាខាងផ្នែកបច្ចេក បច្ចុប្បន្ននេះដូចជា សំណង់ប្រាសាទអង្គរវត្ត ការចាត់ចែងកីឡាអូឡាំពិក ទេសនៃការគ្រប់គ្រងគម្រោងមានការវិវត្តន៍យ៉ាងខ្លាំង ដោយហេតុថាពេល សម្រាប់អនុវត្តការងារនិងធនធានមានកំណត់នាំឱ្យរបៀបចាត់ចែង គម្រោងក៏រីកសាយភាយ។

គម្រោងជាកិច្ចការបណ្តោះអាសន្នដោយហេតុថា៖

- មានពេលវេលាចាប់ផ្តើម និងពេលវេលាបញ្ចប់
- ប្រតិបត្តិការអាចប្រព្រឹត្តទៅក្នុងរយៈពេលវែងឬខ្លី
- ការងារមិនមានភាពអចិន្ត្រៃយ៍។

ឧទាហរណ៍៖ ការសិក្សាថ្នាក់បរិញ្ញាបត្ររបស់និស្សិតនឹងត្រូវបានបញ្ចប់ក្នុងរយៈពេល ៤ ឆ្នាំ។

### ១.១. គោលបំណងនៃគម្រោង

គម្រោងគឺជាសកម្មភាពដែលមានតែម្តងហើយមានការកំណត់យ៉ាងល្អនូវលទ្ធផលចុងក្រោយគួរឱ្យចង់បាន។ គេអាចបែងចែកចេញជាការងារតូចៗជាច្រើនដែលត្រូវតែបំពេញដើម្បីសម្រេចគោលបំណង។ គម្រោងមួយអាចអនុវត្តពេញលេញបរិបូរណ៍ ប្រសិនបើការងារតូចៗទាំងអស់នោះមានការចាត់ចែងនិងត្រួតពិនិត្យឱ្យបានត្រឹមត្រូវ។

គោលបំណងត្រូវមានលក្ខណៈដូចជា៖

- មានតែមួយគត់
- ជាមូលហេតុនាំឱ្យកើតមានគម្រោង
- ជាទូទៅគេអាចសរសេរតែអ្វីដែលអាចប្រាប់គេបាន
- អាចប្រាប់គេបាន និងមិនអាចប្រាប់គេបាន។

### ១.២. គោលដៅរបស់គម្រោង

គោលដៅរបស់គម្រោងគឺជាគំនិតដែលបានកើតចេញអំពីគោលបំណង ហើយសម្រេចថានឹងធ្វើឱ្យបានតាមការគ្រោងទុកនៅពេលខាងមុខនៅក្នុងដំណើរការគម្រោង។

*ក. គោលដៅត្រូវមានលក្ខណៈដូចជា៖*

- កើតចេញពីគោលបំណង
- អាចមានច្រើន យ៉ាងតិច២
- មានលក្ខណៈជាក់លាក់ ហើយត្រូវបំពេញឱ្យបាន
- បំពេញឱ្យគ្នាទៅវិញទៅមក

*ខ. ការកំណត់ចំនួនគោលដៅត្រូវផ្អែកលើ៖*

- ផែនការយុទ្ធសាស្ត្រ
- ទំហំថវិកាសម្រាប់ទ្រទ្រង់គម្រោង
- ពេលវេលាសមស្របដើម្បីប្រតិបត្តិការគម្រោង
- ចំណុចអាទិភាពរបស់ថ្នាក់ដឹកនាំ

### ១.៣. សកម្មភាពរបស់គម្រោង

សកម្មភាពរបស់គម្រោងគឺជាផែនការជាច្រើននៅគ្រប់ផ្នែកទាំងអស់ដែលបានកើតឡើងចេញពីការកំណត់គោលដៅចាំបាច់ សម្រាប់អនុវត្តនៅគ្រប់ជំហានក្នុងដំណើរការប្រតិបត្តិការគម្រោង។

សកម្មភាពគម្រោងត្រូវមានលក្ខណៈដូចជា៖

- ជាឯកតាតូចបំផុតនៃការងារ
- ត្រូវការធនធាន (មនុស្ស សម្ភារៈ និងបរិក្ខា)
- ត្រូវការពេលវេលាក្នុងការអនុវត្ត
- ត្រូវការទីកន្លែងសម្រាប់អនុវត្ត
- កំណត់ចេញបានពីគោលដៅ
- មានទំនាក់ទំនងជាមួយគ្នា
- បំពេញឱ្យគ្នាទៅវិញទៅមក។

## ២. ប្រភេទគម្រោង

គេអាចបែងចែកគម្រោងជាប្រភេទដោយផ្អែកលើមូលដ្ឋានដូចតទៅ៖

**ក. មូលដ្ឋានផលិតផល៖** គ្រប់គម្រោងទាំងអស់ប្រើប្រាស់ធនធានសេដ្ឋកិច្ចដើម្បីផលិត ផលិតផលដោយពឹងផ្អែកលើប្រភេទផ្សេងៗនៃផលិតផល គេអាចបែងចែកគម្រោងជាពីរប្រភេទ៖

- **គម្រោងផលិតកម្ម៖** ជាគម្រោងប្រើប្រាស់ធនធាននិងផលិត ផលិតផល ដែលអាចមើលឃើញ ចាប់កាន់បានដូចជា គ្រឿងសង្ហារឹម សម្ភារៈឧបទ្ទេស សម្ភារៈការិយាល័យ កន្ទេល ផ្ទាំងជាដើម។
- **គម្រោងផ្តល់សេវាកម្ម៖** ជាគម្រោងដែលផ្តល់សេវាកម្មដល់មនុស្សទូទៅ ហើយគេមិនអាចមើលឃើញនូវផលិតផលរបស់គម្រោងប្រភេទនេះទេ ដូចជាសេវាអប់រំ ឬសុខភាពជាដើម។

**ខ. មូលដ្ឋានបំណង៖** គេអាចបែងចែកគម្រោងជាពីរប្រភេទ៖

- **គម្រោងបង្កើនប្រាក់ចំណូល៖** ក្នុងគម្រោងប្រភេទនេះធនធានត្រូវបានប្រើប្រាស់សម្រាប់ផលិត ផលិតផលដើម្បីលក់ និងបង្កើនប្រាក់ចំណូល ជាពិសេសគោលបំណងធំបំផុតគឺការរកបាននូវប្រាក់ចំណេញ។ ជាទូទៅគម្រោងប្រភេទនេះតែងតែត្រូវបានអនុវត្តដោយឯកត្តបុគ្គល ស្ថាប័នឯកជនតាមរយៈផលិតផលិតផល ឬផ្តល់សេវាកម្មផ្សេងៗ។
- **គម្រោងមិនស្វែងរកប្រាក់ចំណេញ/អភិវឌ្ឍសង្គម៖** គោលបំណងសំខាន់បំផុតនៃគម្រោងប្រភេទនេះ គឺចង់ធ្វើឱ្យប្រសើរ ឡើងនូវលក្ខខណ្ឌសង្គមរបស់មនុស្ស។ គម្រោងប្រភេទនេះក៏ប្រើធនធានដើម្បីបង្កើតសេវាកម្មសម្រាប់ផ្តល់ផលប្រយោជន៍ដល់មនុស្សជួនកាលដោយមិនគិតថ្លៃ ជួនកាលយកកម្រៃស្ទួចស្តើងបំផុត។ ឧទាហរណ៍៖ ការផ្តល់បង្គន់អនាម័យឬសង់សាលាធទាននៅតាមផ្លូវដាច់ស្រយាលជាដើម។

**គ. មូលដ្ឋានជំនួយថវិកា៖** គេអាចបែងចែកគម្រោងដោយផ្អែកលើប្រភពថវិកា៖

- **គម្រោងស្ថាប័នសាធារណៈ៖** ពន្ធលើទំនិញនាំចូល រដ្ឋាភិបាលប្រមូលថវិកាតាមរយៈការប្រមូលពន្ធចូល ចំណូលដោយការផ្តល់អាជ្ញាប័ណ្ណ។ល។ ប្រាក់ដែលប្រមូលបានត្រូវបានប្រើប្រាស់ សម្រាប់គម្រោងសាងសង់ផ្លូវថ្នល់ មន្ទីរពេទ្យ សាលារៀន។ល។
- **គម្រោងស្ថាប័នឯកជន៖** គម្រោងប្រភេទនេះឧបត្ថម្ភដោយឯកត្តបុគ្គល ឬស្ថាប័នឯកជន ហើយភាគច្រើនជួយបង្កើនប្រាក់ចំណូល។

**ឃ. ប្រភេទផ្សេងៗ៖** ក្រៅពីប្រភេទទាំងប៉ុន្មានដូចបានរៀបរាប់ខាងលើមកនេះមានគម្រោងប្រភេទផ្សេងៗទៀតដូចជា៖

- **គម្រោងស្រាវជ្រាវ ឬពិសោធន៍៖** គោលបំណងសំខាន់នៃគម្រោងប្រភេទនេះ គឺដើម្បីស្វែងរកអ្វីដែលថ្មី។ គម្រោងប្រភេទនេះត្រូវបានគេអនុវត្តក្នុងបរិបទមួយដែលត្រូវបានគេត្រួតពិនិត្យនិងធ្វើឡើងដោយមនុស្សមួយក្រុមតូច។ ឧទាហរណ៍៖ ការសាកល្បងវិធីសាស្ត្រថ្មីក្នុងការបង្ហាត់សិស្ស ឬការប្រើប្រាស់សៀវភៅសិក្សាថ្មីជាដើម។
- **គម្រោងសាកល្បង៖** គម្រោងប្រភេទនេះភាគច្រើនត្រូវបានគេធ្វើឡើងផ្អែកលើបទពិសោធន៍នៃគម្រោងស្រាវជ្រាវ ឬពិសោធន៍។ មូលហេតុនៃការរៀបចំគម្រោងសាកល្បងនេះគឺដើម្បីសាកល្បងអ្វីដែលទើបនឹងរកឃើញថ្មីនៅក្នុងបរិបទធម្មតា។ គេអាចនិយាយបានថាគម្រោងបែបនេះផ្តល់ឱកាសដើម្បីត្រួតពិនិត្យថាតើអ្វីដែលរកឃើញថ្មីនោះស្របនឹងបរិបទធម្មតា ឬមិនសមស្រប។ ក្នុងន័យទូលាយ គម្រោងមួយគឺជាសំណុំកិច្ចការកំណត់យ៉ាងពិសេសហើយត្រូវតែបំពេញ។ ទោះជាទំហំតូចឬធំសម្រាប់រយៈពេលវែង ឬរយៈពេលខ្លីគឺមិនពាក់ព័ន្ធទេ។ អ្វីដែលពាក់ព័ន្ធនោះគឺថាគម្រោងត្រូវចាត់ទុកថាជាឯកតានៃការងារមួយ។

## ៣. វដ្តនៃគម្រោង

ដូចជាអង្គធាតុផ្សេងៗទៀតដែរគម្រោងមានវដ្តនៃជីវិត។ ចាប់ផ្តើមពីការចេញដំណើរយឺតៗហើយបង្កើតជារូបរាងមួយបន្ទាប់មកដល់ចំណុចខ្ពស់បំផុតចាប់ផ្តើមថយចុះនិងចុងក្រោយបង្អស់ឈានទៅទីបញ្ចប់។

វដ្តនៃគម្រោងមាន ៤ តំណាក់កាលជាលំដាប់លំដោយគឺ៖ តំណាក់កាលកកើត តំណាក់កាលប្រមូលធនធាន តំណាក់កាលរីកលូតលាស់ និងតំណាក់កាលបញ្ចប់។

**ក. តំណាក់កាលកកើត៖** ជាតំណាក់កាលដំបូង ដែលការខិតខំប្រឹងប្រែងហាក់ដូចជាមានល្បឿនយឺតក្នុងនោះមានការបង្កើតជាគោលគំនិត និងការជ្រើសរើសគំរូគម្រោង។ តំណាក់កាលនេះមានសកម្មភាពដូចជា៖

- ជាក់ស្តែងមិនទាន់មានគម្រោងទេ អាចកើតត្រូវជាគំនិតផ្តួចផ្តើមគម្រោង
- ចាប់ផ្តើមសរសេរផែនការដើម្បីដាក់សំណើគម្រោង
- ការសរសេរត្រូវមានភាពទាក់ទាញដើម្បីដាក់ស្នើគម្រោងបានជោគជ័យ

- អាចមានទីប្រឹក្សាជួយប្រឹក្សាយោបល់ និងកែសម្រួលសំណើ
- បត់បែនតាមទៅតាមស្ថានការណ៍ កាលៈទេសៈជាក់ស្តែងនៃពេលវេលា និងទីកន្លែង។

**ខ. តំណាក់កាលប្រមូលធនធាន៖** ជាតំណាក់កាលជ្រើសរើសគម្រោងដើម្បីសម្រេចចិត្តក្នុងការអនុវត្តដំណើរការប្រតិបត្តិការគម្រោង។ តំណាក់កាលនេះសម្រេចទៅបានវាអាស្រ័យទៅលើ៖

- លក្ខខណ្ឌទូទៅនៃគម្រោង
- ជាទ្រឹស្តី សំដៅលើគោលបំណង គោលដៅដែលគម្រោងចង់សម្រេចបាន
- ជាក់ស្តែងអាស្រ័យលើស្ថានភាព ធនធានមនុស្ស សម្ភារៈ និងបរិក្ខា។

**គ. តំណាក់កាលរីកលូតលាស់៖** ជាតំណាក់កាលដែលគម្រោងពិតប្រាកដនឹងដំណើរការបន្ទាប់ពីការធ្វើផែនការរួចរាល់ ហើយសកម្មភាពជាច្រើនក៏កើតមានឡើងមុននឹងឈានដល់ទីបញ្ចប់។ សកម្មភាពទាំងនោះកើតឡើងពីការខិតខំប្រឹងប្រែងរបស់បុគ្គលិកក្នុងការអនុវត្ត ប្រតិបត្តិការគម្រោងដោយរួមផ្សំជាមួយនឹងកត្តាបច្ចេកទេសខ្ពស់ផងដែរ។ ក្នុងតំណាក់កាលនេះក៏ត្រូវមានការតាមដានត្រួតពិនិត្យជាបន្តបន្ទាប់ និងវាយតម្លៃដើម្បីឱ្យដំណើរការគម្រោងនឹងអាចសម្រេចបានប្រកបដោយប្រសិទ្ធភាព។

**ឃ. តំណាក់កាលបញ្ចប់៖** ជាតំណាក់កាលចុងក្រោយនៃដំណើរការប្រតិបត្តិការគម្រោងដែលបានចុះថយនៃសកម្មភាពនានា ហើយចុងក្រោយក្រោយបង្អស់គឺការវាយតម្លៃ និងការបញ្ចប់គម្រោងតែម្តង។ តំណាក់កាលនេះក៏ត្រូវបានប្រើប្រាស់នូវសម្ភារៈ បរិក្ខាមួយចំនួន ព្រមទាំងធនធានមនុស្សដែលមានបទពិសោធន៍ និងជំនាញផងដែរ សម្រាប់ធ្វើការវាយតម្លៃលទ្ធផលជារួមចុងក្រោយនៃគម្រោងដែលបានធ្វើសកម្មភាពជាច្រើនកន្លងមក ដើម្បីធានាថាគម្រោងបានសម្រេចដោយជោគជ័យស្របតាមគោលបំណងរបស់ម្ចាស់គម្រោង។

## ៤. ហានិភ័យរបស់គម្រោង

រាល់ដំណើរការគម្រោងទាំងអស់ មិនប្រាកដថានឹងដំណើររលូនស្របតាមផែនការរហូតនោះទេ។ ដូចនេះអ្នកគ្រប់គ្រង ត្រូវតែគិតគូរជាមុននូវកត្តាប្រឈមដែលអាចនឹងកើតមានឡើង និងធ្វើការត្រៀមលក្ខណៈពិសេសចាំបាច់សម្រាប់ដោះស្រាយឱ្យបានរួចរាល់ដើម្បីងាយស្រួលក្នុងការបត់បែនមិនបណ្តាលឱ្យប៉ះពាល់ដល់ដំណើរការប្រតិបត្តិការគម្រោង។ កត្តាដែលនៃឱ្យគម្រោងមានហានិភ័យអាចមកពី៖

- **កត្តាធម្មជាតិ៖** អាចមានគ្រោះធម្មជាតិកើតឡើងរាំងស្ទះនៅពេលធ្វើសកម្មភាពគម្រោង។

- **កត្តាមនុស្ស៖** បញ្ហាសុខភាព ឬភាពមិនចុះសម្រុងនឹងគ្នារបស់បុគ្គលិកជំនាញ ឬបុគ្គលិកតាមផ្នែកណាមួយ។
- **កត្តាហិរញ្ញវត្ថុ៖** បញ្ហាខ្វះថវិកាក្នុងពេលដំណើរការ ឬក៏ការប្រើប្រាស់ថវិកាមិនអស់នៅពេលដែលគម្រោងបានបញ្ចប់ជាស្ថាពរ។

# មេរៀនទី២ អ្នកគ្រប់គ្រងគម្រោង

ក្នុងការគ្រប់គ្រងគម្រោងមួយ អ្នកគ្រប់គ្រងគម្រោងត្រូវបានជ្រើសរើសនិងឱ្យបំពេញការងារតាំងពីគ្រាដំបូងនៃគម្រោងឬនៅពេលណាមួយដែលអ្នកគ្រប់គ្រងស្ថាប័នគិតថាសមល្មម។ បើអ្នកគ្រប់គ្រងគម្រោង ត្រូវបានជ្រើសរើសមុនការជ្រើសរើសគម្រោង ឬអ្នកគ្រប់គ្រងគម្រោងជាអ្នកផ្តួចផ្តើមរៀបចំផែនការគម្រោង ការងារជាច្រើនក្នុងតំណាក់កាលចាប់ផ្តើមត្រូវបានសម្រួល។ ដូចនេះ ការជ្រើសរើសអ្នកគ្រប់គ្រងគម្រោងត្រូវតែជាបុគ្គលដែលមានសមត្ថភាពខ្ពស់ ចំណេះដឹងទូលំទូលាយជាពិសេសពាក់ព័ន្ធនិងគម្រោងដែលត្រូវគ្រប់គ្រង និងមានភាពជាដឹកនាំដើម្បីឱ្យគម្រោងដំណើរការដល់ទីបញ្ចប់ដោយជោគជ័យ។

## ១. លក្ខណៈសម្បត្តិអ្នកគ្រប់គ្រង

ការជ្រើសរើសអ្នកគ្រប់គ្រងគម្រោង គឺជាការសម្រេចចិត្តដ៏សំខាន់បំផុតមួយក្នុងចំណោមការសម្រេចចិត្តសំខាន់ៗទាំងឡាយពាក់ព័ន្ធនឹងគម្រោង។ លក្ខណៈវិនិច្ឆ័យខ្លះៗដែលត្រូវយកមកពិចារណានៅពេលជ្រើសរើសអ្នកគ្រប់គ្រងគម្រោងមានដូចជា៖

- មានជំនាញឯកទេស
- មានបទពិសោធន៍
- មានទឹកចិត្តមោះមុត
- ជាបុគ្គលចាស់ទុំ
- ជាអ្នកមានពេលវេលាគ្រប់គ្រាន់
- ជាអ្នកមានកិត្តិស័ព្ទល្អជាមួយអ្នកដឹកនាំជាន់ខ្ពស់
- ជាមនុស្សដែលអាចធ្វើឱ្យក្រុមការងារមានភាពសប្បាយរីករាយ
- ជាមនុស្សធ្លាប់ធ្វើការក្នុងផ្នែកផ្សេងៗ
- ជាមនុស្សដែលអាចដើរលើទឹកបាន។

ចំណុចទាំងប៉ុន្មានខាងលើនេះមិនជាខុសប៉ុន្មានទេ តែក៏មិនទាន់គ្រប់គ្រាន់ដែរ។ តាមរយៈការពិភាក្សាខាងលើ យើងអាចបែងចែកជំនាញរបស់ អ្នកគ្រប់គ្រងគម្រោងដែលត្រូវការចំនួន៤ប្រភេទ៖

### ១.១. កិត្តិយស

អ្នកគ្រប់គ្រងគម្រោងត្រូវការកិត្តិយសឬភាពល្បីល្បាញ២ប្រភេទ៖

- **ភាពល្បីល្បាញខាងជំនាញ៖** មានសមត្ថភាពបច្ចេកទេសមានការផ្សាភ្ជាប់យ៉ាងច្រើនជាមួយជោគជ័យរបស់គម្រោង និងយល់ដឹងអំពីបច្ចេកវិទ្យាចាំបាច់សម្រាប់ការគ្រប់គ្រងគម្រោង។
- **ភាពល្បីល្បាញខាងការងាររដ្ឋបាល៖** មានភារកិច្ចទទួលខុសត្រូវសំខាន់ៗជាច្រើនក្នុងដំណើរការ គម្រោងដូចជាការគិតគូរអំពីក្របខ័ណ្ឌពេលវេលា បន្ទុកចំណាយ ធានានូវសម្ភារៈឧបករណ៍ផ្សេងៗ ព្រមទាំងមានរបាយការណ៍ត្រឹមត្រូវទៀងទាត់។

### ១.២. ភាពឆាប់យល់ដឹង

អ្នកគ្រប់គ្រងគម្រោងល្អ ត្រូវដឹងពីទំនាស់ជាមុនហើយដោះស្រាយមុននឹងបែកខ្ញែកខ្ចាយទៅកន្លែងផ្សេងទៀត គេត្រូវធ្វើយ៉ាងណារក្សាឱ្យបុគ្គលិកគម្រោងស្ថិតនៅក្នុងភាពសុខដុមជាមួយគ្នា។ លើសពីនេះអ្នកគ្រប់គ្រងគម្រោងត្រូវយល់ដឹងអំពី៖

- ឆាប់យល់ដឹងអំពីអារម្មណ៍របស់បុគ្គលិក បែងចែកឱ្យដាច់រវាងបញ្ហាបុគ្គលនិងបញ្ហារួមរបស់ក្រុមដោយខិតខំយ៉ាងណាឱ្យសម្រេចគោលដៅរបស់គម្រោង
- មានលំនាំនៃការដឹកនាំ និងគ្រប់គ្រងដោយធ្វើឱ្យមានការសហការគ្នាល្អនៅក្នុងក្រុមការងារ
- យល់ពីបរិយាកាសសេដ្ឋកិច្ច សង្គមកិច្ច
- យល់ពីបរិយាកាសច្បាប់
- យល់ពីវដ្តអាជីវកម្ម
- យល់ពីកម្រិតបច្ចេកវិទ្យាដើម្បីប្រើប្រាស់ក្នុងដំណើរការគម្រោង ជម្រុញឱ្យមានផលិតភាពខ្ពស់។

### ១.៣. រចនាបថដឹកនាំ និងគ្រប់គ្រង

អ្នកគ្រប់គ្រងគម្រោងត្រូវ៖

- ឆ្លៀតយកប្រយោជន៍ពីភាពខ្លាំង និងបិទបាំងចំណុចខ្សោយរបស់បុគ្គលិកគម្រោង
- ដឹងថាពេលណាត្រូវដាក់ទោសនិងពេលណាត្រូវផ្តល់រង្វាន់លើកទឹកចិត្ត
- ដឹងថាពេលណាត្រូវមានទំនាក់ទំនង និងពេលណាត្រូវរំលឹកស្ងាត់ៗ

– ដឹងថាត្រូវប្រមូលអ្នកដទៃទៀតដូចម្ដេចដើម្បីបែងចែកការសន្យា ទាំងឡាយសម្រាប់គម្រោង។

### ១.៤. សមត្ថភាពដោះស្រាយភាពតានតឹង

មានមូលហេតុ៤យ៉ាងសំខាន់ៗសម្រាប់ការកើតឡើងនៃភាពតានតឹង៖

– អ្នកគ្រប់គ្រងគម្រោងខ្លះមិនបានរៀបចំបង្កើតនីតិវិធីនិងបច្ចេកទេស ដើម្បីគ្រប់គ្រងការងារ
– ខ្លះទៀតគិតតែផលប្រយោជន៍យ៉ាងច្រើនសម្រាប់ខ្លួនឯងផ្ទាល់
– មានតម្រូវការខ្ពស់ដើម្បីសម្រេចកិច្ចការអ្វីមួយ ហេតុដូចនេះនាំឱ្យ មានការមិនពេញចិត្ត និង
– ស្ថាប័នអាណាព្យាបាលមានការផ្លាស់ប្ដូរខ្លាំង។

## ២. ការប្រៀបធៀបរវាងការគ្រប់គ្រងគម្រោង និងប្រធានគម្រោង

### ២.១. អ្នកគ្រប់គ្រងផ្នែកជំនាញ និងអ្នកគ្រប់គ្រងគម្រោង

អ្នកគ្រប់គ្រងតាមផ្នែកជំនាញ គឺជាអ្នកឯកទេស ជាអ្នកវិភាគ និងយល់ល្អិតល្អន់អំពីគ្រប់ប្រតិបត្តិការដែលគេជាអ្នកទទួលខុសត្រូវ។ កាលណាមានការលំបាកក្នុងការងារបច្ចេកទេសនៅក្នុងផ្នែករបស់គេ គេដឹងថាតើគេត្រូវវិភាគ និងដោះស្រាយដូចម្ដេច?

ដោយឡែក អ្នកគ្រប់គ្រងគម្រោងគឺទាមទារនូវសមត្ថភាពរបស់ចេះចាត់ចែងការងារដែលមានច្រើនផ្នែកឱ្យរលូននិងឱ្យមានដំណើរការហាក់ដូចជាកិច្ចការតែមួយ។ អ្នកគ្រប់គ្រងគម្រោងត្រូវចេះសំយោគខុសពីសមត្ថភាពអ្នកគ្រប់គ្រងតាមផ្នែកដែលត្រូវចេះវិភាគ។ គេអាចនិយាយបានថា អ្នកគ្រប់គ្រងតាមផ្នែកប្រើការវិភាគ ហើយអ្នកគ្រប់គ្រងគម្រោងប្រើប្រព័ន្ធ។

និយាយម្យ៉ាងទៀត អ្នកគ្រប់គ្រងតាមផ្នែកជាអ្នកត្រួតត្រាបច្ចេកទេសដោយផ្ទាល់ ហើយអ្នកគ្រប់គ្រងគម្រោងជាអ្នកសម្របសម្រួលទូទៅ។ ខាងក្រោមនេះ គឺជាការប្រៀបធៀបរវាងអ្នកគ្រប់គ្រងគម្រោង និងអ្នកគ្រប់គ្រងផ្នែកជំនាញ៖

| **អ្នកគ្រប់គ្រងគម្រោង** | **អ្នកគ្រប់គ្រងតាមផ្នែក** |
|---|---|
| -ជាអ្នកទូទៅនិងសម្របសម្រួល | -ជាអ្នកដឹកនាំ និងទីប្រឹក្សាបច្ចេកទេស |
| -មានសមត្ថភាពបច្ចេកទេសខ្ពស់ | -មានចំណេះដឹងក្នុងបច្ចេកវិទ្យានៃដំណើរការ |
| -ការងារបណ្ដោះអាសន្ន | -ការងារអចិន្ត្រៃយ៍ |
| -មាន ឬអាចមិនមានបទពិសោធន៍ | -មានបទពិសោធន៍ |

| | |
|---|---|
| -មានជំនាញក្នុងកិច្ចការរដ្ឋបាល (លិខិតបទដ្ឋាន, ទំនាក់ទំនង) | -អាចមិនចាំបាច់មានជំនាញកិច្ចការរដ្ឋបាល |
| -មានជំនាញកិច្ចការហិរញ្ញវត្ថុ | -អាចមិនមានជំនាញកិច្ចការហិរញ្ញវត្ថុ |
| -មានជំនាញបច្ចេកវិទ្យា | -មានជំនាញបច្ចេកវិទ្យា ជាចាំបាច់ |
| -ឥរិយាបទបត់បែន ទន់ភ្លន់ និងម៉ឺងម៉ាត់ | -តាមគោលការណ៍របស់ស្ថាប័ន |
| -មានសមត្ថភាពបង្រួមការងារ។ | -ត្រូវចេះបែងចែក ពង្រីកការងារ។ |

## ២.២. ភារកិច្ចអ្នកគ្រប់គ្រងគម្រោង

ក្នុងដំណើរការគម្រោងត្រូវបែងចែកឱ្យដាច់រវាងតួនាទីជាអ្នកគ្រប់គ្រងផ្នែកជំនាញ និងអ្នកគ្រប់គ្រងគម្រោង ដើម្បីធ្វើយ៉ាងជានាបាននូវប្រសិទ្ធភាពរបស់គម្រោង។ ក្នុងន័យនេះដែរ ក្នុងនាមជាអ្នកគ្រប់គ្រងគម្រោងត្រូវមានបញ្ហាមួយចំនួនត្រូវប្រឈមក្នុងការងារសំយោគដើម្បីឱ្យមានប្រសិទ្ធភាពដូចជា៖

- តើគម្រោងធ្វើដើម្បីអ្វី?(Why)
- តើធ្វើជាមួយនរណា និងនរណាទទួលខុសត្រូវ?(Who)
- តើពេលណាដែលត្រូវធ្វើ?(When), (បើសិនជាមិនមានការយឺតយ៉ាវទេ សម្រាប់គម្រោង)
- តើគម្រោងនោះត្រូវធ្វើនៅឯណា? (Where)
- តើត្រូវប្រើប្រាស់ធនធានដូចម្តេច ដើម្បីឱ្យគម្រោងទទួលបានជោគជ័យ? (How)
- តើគេធ្វើដើម្បីអ្វី? (What)

ទោះជាអ្នកគ្រប់គ្រងគម្រោងជាអ្នកទទួលខុសត្រូវចំពោះគម្រោង យ៉ាងណាក៏ដោយពាក់ព័ន្ធជាមួយគម្រោងអ្នកគ្រប់គ្រងតាមផ្នែកនឹងធ្វើការសម្រេចចិត្តជាមូលដ្ឋាននិងប្រកបដោយការប្រុងប្រយ័ត្ន។ ជួនកាល គេអាចជ្រើសរើសមនុស្សដែលនឹងចូលរួមក្នុងការងារគម្រោង។

ជាការកត់សម្គាល់ អ្នកគ្រប់គ្រងគម្រោងជាអ្នកទទួលខុសត្រូវចំពោះការចាត់ចែងចាត់តាំងបុគ្គលិក តម្រង់ទិស ធ្វើផែនការ និងត្រួតពិនិត្យគម្រោង។ គេអាចនិយាយម៉្យាងទៀតថា អ្នកគ្រប់គ្រងគម្រោងជាអ្នក គ្រប់គ្រង ប៉ុន្តែអ្នកគ្រប់គ្រងតាមជំនាញអាចមានឥទ្ធិពលលើការជ្រើសរើសបច្ចេកវិទ្យាដែលនឹងត្រូវប្រើប្រាស់ក្នុងគម្រោងក៏ដូចជាបុគ្គលិកនីមួយៗដែលនឹងត្រូវបំពេញការងារក្នុងគម្រោង។

## ៣. ការទទួលខុសត្រូវគម្រោង

ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងគម្រោងមានភាពទូលំទូលាយណាស់។ គេអាចបែងចែកជាបីផ្នែកសំខាន់ៗ៖

### ៣.១. ការទទួលខុសត្រូវទៅនឹងស្ថាប័នអាណាព្យាបាល

ការទទួលខុសត្រូវទៅនឹងស្ថាប័នដោយផ្ទាល់នេះ គឺរួមទាំងការថែរក្សា អភិរក្សយ៉ាងសមស្រប នៃធនធាន ពេលវេលា បញ្ហាទាក់ទងជាមួយគម្រោងដែលកើតឡើងនិងការគ្រប់គ្រងគម្រោងដោយយកចិត្តទុកដាក់ និងប្រកបដោយសមត្ថភាព។ ជាការល្អ បើសិនជាអ្នកគ្រប់គ្រងគម្រោងផ្តល់ព័ត៌មានពេញលេញដល់អ្នកគ្រប់គ្រងជាន់ខ្ពស់នៃស្ថាប័នអាណាព្យាបាលអំពីស្ថានភាពបន្ទុកចំណាយពេលវេលា និងភាពដែលអាចកើតមានឡើងរបស់គម្រោង។

### ៣.២. ការទួលខុសត្រូវទៅនឹងគម្រោងនិងអតិថិជន

ក្នុងការកិច្ចនេះហាក់ដូចជានៅកណ្តាលភាពចលាចល។ អ្នកគ្រប់គ្រងគម្រោងត្រូវជានានូវសេចក្តីសុច្ចរិតរបស់គម្រោង ទោះជាមានតម្រូវការពីភាគីជាច្រើនដែលមានសិទ្ធិទទួលផលប្រយោជន៍ពីគម្រោង។ អ្នកគ្រប់គ្រង ត្រូវដោះស្រាយជាមួយផ្នែកវិស្វកម្ម បើសិនជាមានការផ្លាស់ប្តូរតាមបំណងប្រាថ្នារបស់ផ្នែកទីផ្សារ ហើយក៏ជាការឆ្លើយតបទៅនឹងការសម្រេចចិត្តដែលមានប្រភពពីអតិថិជន។ អ្នកគ្រប់គ្រងគម្រោងត្រូវវែកញែកឱ្យដាច់រវាងការយល់ដឹងនិងការយល់ច្រឡំ។

### ៣.៣. ការទទួលខុសត្រូវទៅនឹងក្រុមការងារគម្រោង

ក្រុមការងារគម្រោងត្រូវបានចាត់ចែងឡើងតាមធម្មជាតិរបស់គម្រោង និងឯកទេសរបស់បុគ្គលនីមួយៗនៅក្នុងក្រុម។ អ្នកគ្រប់គ្រងគម្រោងត្រូវយកចិត្តទុកដាក់ជាមួយអនាគតរបស់មនុស្សម្នាក់ៗនៅក្នុងក្រុម។ បើសិនជាអ្នកគ្រប់គ្រងគម្រោងមិនយកចិត្តទុកដាក់ជាមួយក្រុមការងារទាំងនោះក្នុងពេលអន្តរកាលមុននឹងទទួលការងារថ្មី ឬត្រឡប់ទៅការងារដើមវិញ ពេលគម្រោងនឹងខិតជិតដល់ទីបញ្ចប់ គេនឹងយកចិត្ត ទុកដាក់ទៅលើការបន្ត ឬស្វែងរកការងារថ្មីជាងការងារក្នុងគម្រោងដែលគេកំពុងធ្វើ។

## ៤. តម្រូវការពិសេសនៃអ្នកគ្រប់គ្រងគម្រោង

អ្នកគ្រប់គ្រងគម្រោងត្រូវមានសមត្ថភាពពិសេសយ៉ាងច្រើន ហើយជោគជ័យរបស់អ្នកគ្រប់គ្រង

គម្រោង គឺអាស្រ័យទៅលើចំនួនសមត្ថភាព ដែលគេមាន និងការអនុវត្តន៍សមត្ថភាពទាំងនោះ។ សមត្ថភាពទាំងនោះ គេអាចបែងចែកដូចតទៅៈ

### ៤.១. ការទទួលបានធនធានសមល្មម

ជាទូទៅ ធនធានដែលមានបម្រុងទុកប្រើប្រាស់ក្នុងគម្រោង ភាគច្រើនមិនសមល្មមនឹងការងារដែលត្រូវធ្វើ។ វិបត្តិកើតឡើងនៅពេលធនធានពិសេសមិនបានផ្តល់ឱ្យអ្នកគ្រប់គ្រងគម្រោង។ បញ្ហាទាំងអស់នេះ បង្កើតបានជាការខកខានក្នុងដំណើរការរបស់គម្រោង។ ដើម្បីដោះស្រាយ នឹងបញ្ហាទាំងនេះ អ្នកគ្រប់គ្រងគម្រោងត្រូវតែព្យាយាមស្វែងរកជំនួយធ្វើការលើសម៉ោងលួងលោមឬធ្វើអ្វីដែលគិតថាចាំបាច់សម្រាប់ឱ្យគម្រោងអាចដំណើរការតាមពេលវេលាគ្រោងទុក។ ជាញឹកញាប់ជោគជ័យឬការលំបាករបស់គម្រោងគឺអាស្រ័យនឹងមិត្តភាព របស់អ្នកគ្រប់គ្រងគម្រោង។

### ៤.២. ការទទួលបាន និងជំរុញបុគ្គលិក

ភាគច្រើនអ្នកគ្រប់គ្រងតាមផ្នែកសហការជាមួយអ្នកគ្រប់គ្រងគម្រោង ហើយគេព្យាយាមរកមនុស្សល្អសម្រាប់ធ្វើការក្នុងគម្រោង ប៉ុន្តែការសហការនេះក៏មានដែនកំណត់ដែរ។ ក្រុមដែលមានប្រសិទ្ធភាពបំផុតត្រូវមាន លក្ខណៈសម្បត្តិដូចតទៅៈ

- ជំនាញបច្ចេកទេសប្រកបដោយគុណភាពខ្ពស់
- ភាពធាប់យល់ដឹងពីតម្រូវការរបស់ស្ថាប័ន
- តម្រង់ឆ្ពោះចំបញ្ហា
- តម្រង់ឆ្ពោះចំគោលដៅ
- គោរពខ្លួនឯងនិងស្គាល់តួនាទីច្បាស់លាស់។

### ៤.៣. ភាពអត់ធ្មត់ក្នុងការដោះស្រាយបញ្ហា

កាលណាគេធ្វើផែនការបានល្អ វិបត្តិក៏មានតិចដែរ ហើយអ្នកគ្រប់គ្រងគម្រោងដែលមានជោគជ័យគឺជាអ្នកព្យាយាមប្រយុទ្ធនឹងការងារ។ គ្រប់ពេលដែលកើតបញ្ហាឡើងការកាត់បន្ថយថវិកា និងពេលវេលា ត្រូវប្រែក្លាយជាការផ្លាស់ប្តូរបញ្ហាបច្ចេកទេស។ សម្រាប់អ្នកដែលមានការពាក់ព័ន្ធអាចជាបញ្ហា។

អ្នកគ្រប់គ្រងគម្រោងរៀនសូត្រតាមរយៈបទពិសោធន៍ផ្ទាល់ខ្លួន ឬពីអ្នកដទៃ។ ការដោះស្រាយបញ្ហាត្រូវធ្វើយ៉ាងណាឱ្យមានប្រសិទ្ធភាព ត្រូវចេះចាត់ចែងស្វែងរកនិងទទួលដឹងឱ្យបានធាប់រហ័ស។

បើធ្វើដូច្នោះ បានគេអាចចាត់ចែងឱ្យបុគ្គលិកគម្រោងណាម្នាក់ដែលមានជំនាញក្នុងបញ្ហានោះទទួលជួយដោះស្រាយ។ កាលណា គម្រោងជិតឈានដល់ទីបញ្ចប់បញ្ហាពីរសំខាន់ៗកើតឡើង៖

- ការបែងចែកពេលវេលាចុងក្រោយនិងការផ្លាស់ប្តូរបច្ចេកទេស និង
- ភាពមិនជាក់ច្បាស់ជុំវិញបុគ្គលិកគម្រោង នៅពេលដែលគម្រោង ត្រូវបានបញ្ចប់។

គន្លឹះនៃការដោះស្រាយបញ្ហាគឺទំនាក់ទំនង។ អ្នកគ្រប់គ្រងគម្រោងត្រូវមានទំនាក់ទំនងជាមួយបុគ្គលិក។ ទំនាក់ទំនងជាចំហរទាមទារឱ្យមានសន្តានចិត្ត ឬការព្រួយបារម្ភណ៍ជាដើម។

## ៤.៤. បែងចែកបំណងរបស់គម្រោង

អ្នកគ្រប់គ្រងគម្រោងត្រូវបែងចែកឱ្យដាច់រវាងគោលដៅរបស់គម្រោង ពេលវេលា និងការស្តែងឡើង។ មានចំណុចសំខាន់ៗ ២ ដែលត្រូវពិចារណា៖

- **ការទាមទារឱ្យមានតុល្យភាព**រវាងពេលវេលារបស់គម្រោងបន្ទុកចំណាយ និងការស្តែងឡើងនៃគោលដៅ។ នៅពេលចាប់ផ្តើម ពោលគឺពេលធ្វើផែនការគម្រោងអ្វីៗហាក់ដូចជាសំខាន់ណាស់សម្រាប់សម្រេចគោលដៅរបស់គម្រោង ដោយក្នុងនោះរួមមានការលះបង់បន្ទុកចំណាយ និងពេលវេលាដើម្បីតម្រូវការបច្ចេកទេសរបស់គម្រោង។ បន្ទាប់ពីរៀបចំហើយគម្រោងចាប់ផ្តើមរីកធំធាត់ ហើយដំណើរការដល់ចំណុចកំពូល។ ចុងក្រោយបង្អស់ នៅពេលដែលគម្រោងជិតបញ្ចប់ ការបែងចែកពេលវេលាគឺជាកិច្ចការសំខាន់បំផុត។
- **ការលះបង់របស់បុគ្គលិក**ដើម្បីការវិវត្តន៍បច្ចេកទេស។ អ្នកគ្រប់គ្រងគម្រោងចាំបាច់ត្រូវយល់ដឹងពីទឹកចិត្តរបស់បុគ្គលិកតាមរយៈការយកចិត្តទុកដាក់។ បើសិនជាអ្នកគ្រប់គ្រងគម្រោងដឹកនាំគម្រោងច្រើនក្នុងពេលតែមួយ គេត្រូវធ្វើការបែងចែកឱ្យបានច្បាស់លាស់។ ការយកចិត្តទុកដាក់របស់គេត្រូវជានានូវវដ្តរបស់គម្រោងទាំងឡាយខុសគ្នាសមល្មមដើម្បីឱ្យគម្រោងទាំងនោះមានតម្រូវការធនធានតែមួយក្នុងពេលជាមួយគ្នា ចៀសវាងកុំឱ្យមានជម្រើសរវាងគម្រោងនិងគម្រោង។

# មេរៀនទី៣ ការចាត់ចែងគម្រោង

ស្ថាប័នមួយ បើមានការរីកចម្រើនច្រើនមានការបន្ថែមធនធាននិងបុគ្គលិក។ តាមធម្មតា ចំណុចសំខាន់នៃរចនាសម្ព័ន្ធគឺជាជំនាញរបស់មនុស្សក្នុងក្រុម។ កាលណារចនាសម្ព័ន្ធនៅតែមាន ប្រសិទ្ធភាព សម្រាប់ការងារគេនឹងកសាងរចនាសម្ព័ន្ធនោះឱ្យកាន់តែប្រសើរឡើង។

បច្ចុប្បន្ននេះមានការកកើតឡើងនូវប្រភេទថ្មីជាច្រើននៃរចនាសម្ព័ន្ធគម្រោងដូចជា សហគ្រាស គ្រប់គ្រងគម្រោង ការចាត់ចែងស្ថាប័នដោយគម្រោងក្រុមហ៊ុនតម្រង់ឆ្ពោះគម្រោង។ល។

មានមូលហេតុជាច្រើនដែលនាំឱ្យមានការរីកចម្រើនស្ថាប័នប្រភេទខាងលើ តែទោះជាយ៉ាង ណារចនាសម្ព័ន្ធទាំងនោះមានទម្រង់ជាមូលដ្ឋាន ចំនួន៤សំខាន់ៗ។

## ១. រចនាសម្ព័ន្ធតាមបែបជំនាញ

រចនាសម្ព័ន្ធបែបនេះសមស្រប បើគម្រោងជាការទទួលខុសត្រូវជាក់លាក់របស់ផ្នែកណាមួយ។ រចនាសម្ព័ន្ធគម្រោងបែបនេះប្រើប្រាស់សម្រាប់គម្រោងដែលមានរយៈពេលវែង មានការងារជាអចិន្ត្រៃយ៍ ហើយស្ទើរតែគ្រប់ការងារទាំងអស់ក្នុងគម្រោងត្រូវបានចាត់ចែងជាការងាររបស់ផ្នែកជំនាញហើយនឹង ត្រូវបំពេញក្នុងផ្នែកមួយនោះ។

### ១.១. គុណសម្បត្តិ

- **ភាពជិតស្និទ្ធនៅក្នុងក្រុម៖** សមាជិកការងារគម្រោងសុទ្ធតែស្គាល់គ្នាទៅវិញទៅមក ហើយអ្នក ទាំងនោះសុទ្ធតែមានកម្រិតជំនាញច្បាស់លាស់។
- **ប្រើប្រាស់ធនធានមនុស្សសមស្រប៖** ដោយផ្អែកលើមូលដ្ឋានបច្ចេកទេស អ្នកជំនាញម្នាក់ៗ អាចធ្វើការក្នុងគម្រោងផ្សេងៗក្នុងពេលតែមួយ។
- **បង្កើនសមត្ថភាព៖** អ្នកជំនាញនៅក្នុងផ្នែកអាចប្រមូលផ្តុំដើម្បីផ្លាស់ប្តូរបទពិសោធន៍ ចែកចាយ ចំណេះដឹង។ ចំណេះដឹងស៊ីជម្រៅនេះគឺជាប្រភពនៃសក្តានុពលដើម្បីដោះស្រាយបញ្ហាថ្មី។
- **ការបម្រុងទុកធនធានមនុស្ស៖** បុគ្គលិកគម្រោងមានការត្រៀមលក្ខណៈជាស្រេច ដោយអ្នក គ្រប់គ្រងតាមផ្នែកជាអ្នកត្រួតពិនិត្យការចាត់ចែងការងារ។ ដូច្នេះបើសិនជាមានទំនាស់ពីបញ្ហា ប្រើប្រាស់ធនធានជាដើមក៏គ្មានទំនាស់ឆ្លងដែនដែរ។

- **ជាផ្លូវសម្រាប់ការរីកចម្រើនរបស់បុគ្គល៖** គម្រោងប្រភេទនេះអាចជាជោគជ័យសម្រាប់អ្នកណាម្នាក់ដែលចូលរួមក្នុងគម្រោង មិនតែប៉ុណ្ណោះជំនាញរបស់គេអាចរិតតែប្រសើរជាងមុន។

## ១.២. គុណវិបត្តិ

- **អតិថិជនមិនសំខាន់៖** គម្រោងតាមផ្នែកជំនាញមិនបានយកចិត្តទុកដាក់ជាមួយអតិថិជនទេ តែគេយកចិត្តទុកដាក់ខ្លាំងជាមួយសកម្មភាព។
- **មិនតម្រង់ចំបញ្ហា៖** បញ្ហាក្នុងន័យនេះថា តើគម្រោងទទួលបានជោគជ័យឬយ៉ាងណានោះគេមិនបានយកចិត្តទុកដាក់។
- **កង្វះខាតភាពទទួលខុសត្រូវពេញលេញ៖** អ្នកគ្រប់គ្រងគម្រោងទទួលខុសត្រូវផ្នែកខ្លះរបស់គម្រោងហើយអ្នកផ្សេងទៀតទទួលខុសត្រូវផ្នែកមួយឬច្រើន នឹងនាំឱ្យកើតនូវកង្វះខាតនៃការចាត់ចែងនិងភាពច្របូកច្របល់នៃលទ្ធផល។
- **ការឆ្លើយតបនឹងតម្រូវការរបស់អតិថិជនយឺតយ៉ាវ៖** តាមរយៈនៃការចាត់ចែងប្រកបដោយភាពច្របូកច្របល់ខាងលើ ធ្វើឱ្យការឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនមានការយឺតយ៉ាវនិងពិបាកក្រៃលែង។
- **ការជំរុញតិចតួច៖** គម្រោងមិនមែនជាចំណុចសំខាន់នៃការងារបុគ្គលិកគម្រោងខ្លះអាច គិតថាសេវាកម្មគម្រោងគឺជាផ្លូវវាងសម្រាប់វិជ្ជាជីវៈរបស់គេ ម្ល៉ោះហើយគេហាក់ដូចជាមិនសូវមានទឹកចិត្តបំពេញការងារ។
- **ធនធានមានកំណត់៖** គម្រោងបែបនេះអាចប្រើធនធានបច្ចេកទេសតែនៅក្នុងផ្នែកមួយ ដូចនេះអាចមិនគ្រប់គ្រាន់សម្រាប់ការងារគម្រោង។
- **ការបែងចែកបទពិសោធន៍យឺតយ៉ាវ៖** ការចាត់ចែងបែបនេះមិនអនុញ្ញាតឱ្យមានការសម្របសម្រួលទាំងស្រុងសម្រាប់គម្រោងទេ។

# ២. ការចាត់ចែងគម្រោងតាមផលិតផល

នៅក្នុងរចនាសម្ព័ន្ធគម្រោងតាមផលិតផល ក្រុមការងារគម្រោងត្រូវបានប្រគល់ភារកិច្ចដើម្បីសម្រេចគោលដៅរបស់គម្រោង។ តាមរយៈការចាត់ចែងបែបនេះ សមាជិកក្រុមការងារត្រូវធ្វើរបាយ

ការណ៍ទៅអ្នកគ្រប់គ្រងគម្រោងក្នុងកំឡុងពេលបំពេញការងារ។ ជាទូទៅ បើគម្រោងមានភាពស្មុគស្មាញ ហើយប្រើពេលលើសពីមួយឆ្នាំការចាត់ចែងគម្រោងតាមផលិតផលជាការប្រសើរបំផុត។

## ២.១. គុណសម្បត្តិ

- **ការគ្រប់គ្រងពេញលេញ៖** អ្នកគ្រប់គ្រងគម្រោងត្រូវធ្វើរបាយការណ៍ទៅអ្នកដឹកនាំជាន់ខ្ពស់នៃស្ថាប័នអាណាព្យាបាល។ ការធ្វើបែបនេះ អាចដោះស្រាយនូវទំនាស់ដែលអាចកើតមានព្រោះមានអ្នកដឹកនាំផ្ទាល់តែមួយគត់។
- **ភាពទទួលខុសត្រូវដោយផ្ទាល់នៃសមាជិកគម្រោង៖** ក្រុមការងារគម្រោងមានភាពទទួលខុសត្រូវដោយផ្ទាល់ចំពោះគម្រោង ពោលគឺពុំមានផ្នែកជំនាញឬអ្នកគ្រប់គ្រងណាម្នាក់មានសិទ្ធផ្តល់យោបល់អ្វីមុនធ្វើការសម្រេចចិត្តទេ។ អ្នកដឹកនាំគម្រោងគឺជាអ្នកដឹកនាំគម្រោងពិតៗ។
- **ទំនាក់ទំនងឆាប់រហ័ស៖** អ្នកគ្រប់គ្រាងគម្រោងទំនាក់ទំនងផ្ទាល់ជាមួយអ្នកដឹកនាំជាន់ខ្ពស់។ ទំនាក់ទំនងឆាប់រហ័សនេះក៏អាចបន្ថយការឆ្លាំឆ្លងដែរ។
- **ការសម្រេចចិត្តឆាប់រហ័ស៖** ដោយការគ្រប់គ្រងមានលក្ខណៈមជ្ឈការ គេធ្វើសេចក្តីសម្រេចចិត្តទាំងឡាយមានសភាពរហ័ស។ ទធ្វើបែបនេះ ជាបំណងប្រាថ្នារបស់អតិថិជន និងអ្នកដឹកនាំជាន់ខ្ពស់។
- **រចនាសម្ព័ន្ធងាយនិងបត់បែន៖** លក្ខណៈងាយស្រួលនិងបត់បែននៃការគ្រប់គ្រងគម្រោងតាមផលិតផល ធ្វើឱ្យមានការងាយស្រួលយល់និងអនុវត្តន៍ដែរ។

## ២.២. គុណវិបត្តិ

- **ការខ្វះខាតបុគ្គលិក៖** ដោយស្ថាប័នអាណាព្យាបាលភាគច្រើនមានគម្រោងច្រើន ធ្វើឱ្យមានការខ្វះខាតបុគ្គលិក។ ក្នុងស្ថានភាពបែបនេះ ករណីខ្លះអាចមានការចាត់ចែងបុគ្គលិកច្របូកច្របល់ ហើយអាចឈានទៅខ្ចីអ្នកជំនាញមកពីខាងក្រៅ។
- **ការខិតខំទ្វេរ៖** នៅពេលស្ថាប័នអាណាព្យាបាលមានគម្រោងច្រើនតម្រូវឱ្យមានការចាត់តាំងបុគ្គលិកជាន់គ្នា បែបនេះធ្វើឱ្យមានការចំណាយមិនចាំបាច់ច្រើន។
- **សមាជិកគម្រោងដើរក្រោយបច្ចេកវិទ្យា៖** ការផ្តាច់ចេញពីផ្នែកជំនាញគឺជាការល្អហើយ ប៉ុន្តែនឹងមានគុណវិបត្តិធំនៅពេលគម្រោងត្រូវការបច្ចេកវិទ្យាខ្ពស់មានលក្ខណៈជឿនលឿន។

- **ភាពនៅដោយឡែក៖** សមាជិកគម្រោងនៅឆ្ងាយពីស្ថាប័ន(គោលនយោបាយនិងនីតិវិធី)។ អ្នកនៅក្រៅគម្រោងច្រើនតែងគិតថាសមាជិកគម្រោងពុំយល់ពីបញ្ហារបស់គេទេ ហើយចេះតែមានគំនិតដោយឡែកៗពីគ្នា។
- **ភាពមិនជាក់ច្បាស់នៃការធ្វើសមារណកម្មបុគ្គលិក៖** អ្នកដែលចូលរួមក្នុងគម្រោងត្រូវបានគេគិតថាជាអ្នកក្រៅ កាលណាគេត្រឡប់មកបំពេញការងារដើមវិញឬការងារអាចមានការផ្លាស់ប្តូរក្នុងកំឡុងពេលបំពេញការងារគម្រោង។

## ៣. ការចាត់ចែងគម្រោងបែបខ្វែង

ការចាត់ចែងគម្រោងបែបខ្វែងក្រុមការងារគម្រោងបានបង្កើតឡើងហើយអ្នកទាំងនោះមកពីផ្នែកជំនាញផ្សេងៗ។ អ្នកគ្រប់គ្រងគម្រោងគឺជាអ្នកទទួលខុសត្រូវលើកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ។ សម្រាប់ការអនុវត្តគម្រោងត្រូវបានចាត់ឱ្យមានប្រធានផ្នែកជំនាញទទួលខុសត្រូវលើការងារជំនាញដោយឡែករបស់ខ្លួនយ៉ាងច្បាស់លាស់។ ចំណែកបុគ្គលិកតាមជំនាញនីមួយៗត្រូវតែធ្វើរបាយការណ៍អំពីលទ្ធផលទៅប្រធានផ្នែកជំនាញផង ព្រមទាំងអ្នកគ្រប់គ្រងគម្រោងផងដែរ។

### ៣.១. គុណសម្បត្តិ

- **ប្រើប្រាស់ធនធានផ្ទៃក្នុងអស់ពីលទ្ធភាព៖** ក្នុងពេលដែលគម្រោងដំណើរការមានច្រើន គេអាចចាត់ចែងប្រើប្រាស់ធនធានមានតុល្យភាពរវាងបន្ទុកចំណាយ ពេលវេលា និងជាពិសេសគឺធនធានមនុស្សនៅក្នុងស្ថាប័នទាំងមូល។ ដំណើរការគម្រោងមានការតម្រង់គោលដៅច្បាស់លាស់ ហើយត្រូវបានគ្រប់គ្រង និងទទួលខុសត្រូវដោយមនុស្សម្នាក់ រួមបញ្ចូលជាមួយការប្រើប្រាស់នូវបច្ចេកវិទ្យាក្នុងការគាំទ្រដំណើរការអនុវត្តគម្រោងដែលធ្វើឱ្យមានការសន្សំសំចៃពេលវេលា ថវិកា និងមានប្រសិទ្ធភាពខ្ពស់។
- **ភាពងាយស្រួលធ្វើសមាហរណកម្មបុគ្គលិក៖** គម្រោងបែបខ្វែងមានភាពបត់បែនក្នុងការដោះស្រាយបានយ៉ាងឆាប់រហ័សនូវតម្រូវការរបស់អតិថិន តាមរយៈស្ថាប័នអាណាព្យាបល និងការប្រើប្រាស់ធនធាមនុស្ស។ នៅពេលគម្រោងត្រូវបានបញ្ចប់ បុគ្គលិកជំនាញនឹងត្រូវធ្វើសមាហរណកម្មឱ្យធ្វើការក្នុងគម្រោងផ្សេងៗទៀតដែលពាក់ព័ន្ធជាមួយនឹងផ្នែកជំនាញរបស់គេបានដដែល។

### ៣.២. គុណវិបត្តិ

- **ការច្រណែនទំនាស់ច្រើន៖** នៅក្នុងការចាត់ចែងបែបខ្វែងអំណាចនៃការដឹកនាំមានតុល្យភាពជាងនៅក្នុងការចាត់ចែងតាមភារកិច្ចនិងតាមផលិតផល។ តុល្យភាពនេះ ជាញឹកញាប់មិនសូវមានរឹងមាំពិតប្រាកដទេ។ កាលណាគម្រោងទទួលជោគជ័យ ហើយមើលឃើញយ៉ាងច្បាស់អាចមានទំនាស់ផ្ទៃក្នុងដោយការច្រណែននឹងទទួលកិត្តិយសនិងជោគជ័យ។ បើសិនជាគម្រោងមានកំហុសវិញ នោះទំនាស់ផ្ទៃក្នុងរឹតតែមានសភាពធ្ងន់ធ្ងរទៅទៀត។
- **ពិបាកចាត់ចែងធនធាន៖** ដើម្បីឱ្យគម្រោងដំណើរការ គេត្រូវការឱ្យធនធានគ្រប់ទាំងអស់នេះជាការលំបាក។ លើសពីនេះគេអាចទាញយកធនធានទៅប្រើពីគម្រោងមួយទៅគម្រោងមួយអាចបង្កើតបានជាទំនាស់ផ្ទៃក្នុងរវាងអ្នកគ្រប់គ្រងគម្រោងទាំងឡាយ ដោយហេតុថាម្នាក់ៗសុទ្ធតែចង់ឱ្យគម្រោងរបស់ខ្លួនសម្រេចគោលដៅ។
- **បញ្ហាប្រធានច្រើន៖** បុគ្គលិកគម្រោងដែលត្រូវបានចាត់ចែងបែបខ្វែងនេះ ស្ថិតនៅក្រោមបង្គាប់របស់អ្នកគ្រប់គ្រងគម្រោងផង និងប្រធានផ្នែកបច្ចេកទេសរបស់ខ្លួនផង។ នេះជាមូលហេតុបង្កើតឱ្យមានការលំបាកព្រោះអ្នកគ្រប់គ្រងម្នាក់ តែងចង់បានលទ្ធផលសម្រាប់ការងារតាមផ្នែកឬរបស់គម្រោងខ្លួនច្រើន។

## ៤. ប្រព័ន្ធចាត់ចែងបែបចម្រុះ

ការចាត់ចែងបែបនេះគឺជាជាការរួមបញ្ចូលគ្នារវាងការចាត់ចែងបែបជំនាញ និងការចាត់ចែងបែបផលិតផលសុទ្ធសាធ។ ទម្រង់នេះអនុញ្ញាតឱ្យស្ថាប័នមានការបត់បែនឆាប់រហ័សដើម្បីធ្វើយ៉ាងណាសម្រាប់បំពេញតម្រូវការជាក់ស្តែង។ ការចាត់ចែងបែបនេះភាគច្រើននៅក្នុងរោងចក្រផលិតសម្ភារៈឧបទ្ទេស តុក្កតា ឬល្បែងក្មេងលេងជាដើម។

នៅក្នុងរចនាសម្ព័ន្ធបែបចម្រុះ ក្រុមការងារតូចៗ ឬភាគច្រើនជាបុគ្គលិកម្នាក់ៗព្យាយាមបង្កើតថ្មីនូវសម្ភារៈផ្សេងៗដើម្បីផ្គត់ផ្គង់តម្រូវការទីផ្សារ។ ការចាត់ចែងបែបនេះគឺជាការប្រើប្រាស់ឱ្យអស់លទ្ធភាពទាំងបច្ចេកទេស និងការគ្រប់គ្រងនៅក្នុងគម្រោង។

## ៥. ការជ្រើសរើសទម្រង់ចាត់ចែង

ការជ្រើសរើសទម្រង់ចាត់ចែងពិតជាមានសារៈសំខាន់ក្នុងដំណើរការអនុវត្តគម្រោងដើម្បីឱ្យមានប្រសិទ្ធភាព សមស្របជាមួយនឹងទំហំរយៈពេល និងធនធានសម្រាប់ប្រើប្រាស់ក្នុងគម្រោង។

បើសិនជា គម្រោងមានលក្ខណៈទ្រង់ទ្រាយធំទាមទារឱ្យមានការប្រើប្រាស់នូវជំនាញជាច្រើនដើម្បីសម្រេចបានក្នុងរយៈពេលយូរដូចជាជំនាញរដ្ឋបាល គណនេយ្យ ស្រាវជ្រាវជាដើម ពេលនោះការចាត់ចែងបែបខ្វែងសមស្របបំផុត។ បើគម្រោងនោះមានសភាពងាយហើយប្រើប្រាស់ធនធានមកតែពីផ្នែកបឋមណាមួយ គេអាចចាត់ចែងតាមបែបជំនាញ ដោយអាចប្រើជំនាញដែលមានស្រាប់។ ប៉ុន្តែបើសិនជាមានការចូលរួមពីធនធានខាងក្រៅខ្លះៗដើម្បីបំពេញកិច្ចការពិសេស នោះជាការចាត់ចែងបែបចម្រុះ។

នីតិវិធីមួយចំនួនសម្រាប់ជ្រើសរើសទម្រង់នៃការចាត់ចែងសម្រាប់គម្រោងមួយ៖

ក. កំណត់លទ្ធផលជាបំណងប្រាថ្នា។

ខ. កំណត់ភារកិច្ចគន្លឹះដើម្បីទទួលបានលទ្ធផលទាំងនោះ និងកំណត់ផ្នែកឬអង្គភាពក្នុងស្ថាប័នអាណាព្យាបាលដែលតាមធម្មតាមានភារកិច្ចទទួលខុសត្រូវកិច្ចការទាំងនោះ។

គ. រៀបចំជាលំដាប់នូវភារកិច្ចគន្លឹះទាំងនោះ និងរៀបចំចាត់ចែងជាលំដាប់ការងារសមស្រប។

ឃ. កំណត់អង្គភាពដែលត្រូវទទួលភារកិច្ចអនុវត្ត និងអង្គភាពណាដែលពាក់ព័ន្ធជិតបំផុត។

ង. កំណត់ស្ថាប័នពិសេសឬចរិតគម្រោង ការលំបាកឬបញ្ហាខ្លះៗដែលអាចមានឥទ្ធិពលទៅលើទម្រង់ចាត់ចែងគម្រោង។

ច. ពិចារណាចំណុចទាំងប៉ុន្មានខាងលើ ហើយបែងចែកជាការយល់ព្រម ឬការជំទាស់នៃ

ទម្រង់ចាត់ចែងជាការសម្រេចចិត្តចុងក្រោយ។

## ៦. ក្រុមអនុវត្តគម្រោង

ក្នុងគម្រោងផ្សេងគ្នាមានតម្រូវការក្រុមការងារផ្សេងគ្នា។ ដូចនេះគ្រប់គម្រោងទាំងអស់ត្រូវបង្កើតឱ្យមានការិយាល័យមួយ ទោះជាគម្រោងនោះតូចយ៉ាងណាក៏ដោយ។ ការិយាល័យគឺជាកន្លែងមួយបំពាក់ដោយឧបករណ៍នានាសម្រាប់កិច្ចដំណើរការគម្រោងដូចជាកុំព្យូទ័រ ទូរស័ព្ទ ទូរដាក់ឯកសារតាំងលម្អដោយសុខុបត្ថម្ភវត្ថុជាដើម។ ការិយាល័យនេះសម្រាប់ទុកដើម្បី៖

- ជាទីកន្លែងមជ្ឈមណ្ឌលត្រួតពិនិត្យ
- ជាកន្លែងធ្វើផែនការ
- ជាបន្ទប់ប្រជុំរបស់ថ្នាក់ដឹកនាំជាមួយបុគ្គលិក ជាមួយភ្ញៀវឬអតិថិជន
- ជាកន្លែងសម្រាកញ៉ាំកាហ្វេតិចតួច

– និងជាទូទៅជាចំណុចសំខាន់នៃសកម្មភាពទាំងអស់របស់គម្រោង។

## មេរៀនទី៤ ការធ្វើផែនការគម្រោង

គម្រោងការងារត្រូវបានកើតឡើងដោយការមើលឃើញអំពីតម្រូវការរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល។ ហើយការបង្កើតគម្រោងបែបណាមួយនោះគឺជាសម្រាប់បំពេញនូវសេចក្តីត្រូវការដែលគេចង់បានតាមរយៈលទ្ធផលនៅពេលបញ្ចប់នៃដំណើរគម្រោង។ មុនពេលដែលគម្រោងអាចដំណើរការបានត្រូវឆ្លងកាត់នូវដំណាក់កាលដំបូងបំផុតនោះគឺការធ្វើផែនការគម្រោង។ ការរៀបចំផែនការគម្រោងមានភាពចាំបាច់បំផុត ដើម្បីសិក្សាអំពីលទ្ធភាពដែលអាចសម្រេចទៅបានជាលទ្ធផលចុងក្រោយដែលគេចង់បាន ដោយសមស្របទៅតាមធនធាន របៀបរបបការងារ ពេលវេលា និងទីកន្លែងជាដើម។

មានមូលហេតុមូលហេតុ៥ យ៉ាងសម្រាប់ការរៀបចំផែនការគឺ៖

- គិត និង សម្រេចចិត្ត
- ប្រមូល / ប្រើប្រាស់ធនធាន
- គ្រប់គ្រងធនធាន និង មនុស្ស
- វាយតម្លៃ សិក្សា កែលំអ
- ធ្វើឱ្យរីកចម្រើនជាបុគ្គល និង ក្រុម។

### ១. សមាសធាតុចូលរួមក្នុងការរៀបចំផែនការ

គម្រោងមួយអាចដំណើរការទៅបានដោយប្រសិទ្ធភាព ត្រូវមានការរៀបចំផែនការមុនជាចាំបាច់បំផុត ដើម្បីភាពសមស្របជាមួយនឹងអ្វីដែលនៅជុំវិញធនធាន និងក្របខ័ណ្ឌពេលវេលាជាដើម។ ក្នុងចំណុចនេះការសរសេរផែនការគម្រោងមួយបានយើងត្រូវសមាសធាតុចូលរួមដូចជា៖ គំនិត បរិបទ ជំនួយ ធនធាន ទម្រង់ និងគម្រោងពេលវេលា។

#### ១.១. គំនិត

គំនិតនៃការបង្កើតគម្រោងអាចកើតចេញពីរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានមើលឃើញអំពីតម្រូវការសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃនៅក្នុងសង្គម។ ការផុសចេញនូវគំនិតបង្កើតគម្រោងណាមួយគឺជាការងារដើម្បីបំពេញបន្ថែមនូវតម្រូវការនោះ។ គោលគំនិតសំខាន់សម្រាប់គិតទាំងអស់មាន៥គឺ៖

- **គោលបំណង៖** គំនិតនៃការបង្កើតគម្រោងផែនការមានគោលបំណងអ្វីជាចាំបាច់។
- **ការបង្ហាញភស្តុតាង៖** មូលហេតុនៃការបង្កើតគម្រោង ហើយដើម្បីបម្រើផលឱ្យនរណា។

- **ការទាក់ទង៖** ស្វែងរកអំពីទំនាក់ទំនងនៃផែនការ ហើយផលប្រយោជន៍អ្វីខ្លះដែលនឹងទទួលបាន។
- **ភាពសមស្រប៖** ផែនការគម្រោងនេះបំពេញចំតម្រូវការ ហើយមានប្រសិទ្ធភាពឬទេ។
- **ភាពដែលអាចធ្វើបាន៖** គិតជាមុនអំពីកម្រិតនៃភាពជោគជ័យ និងកត្តាដែលអាចប្រឈមនៅពេលដំណើរការអនុវត្តគម្រោង។

### ១.២. បរិបទ

ក្នុងការបង្កើតគឺជាត្រូវលើបរិបទជុំវិញដើម្បីទាមទារឱ្យមានការចាប់អារម្មណ៍ និងចូលរួមក្នុងដំណើរការអនុវត្តគម្រោងទទួលបានជោគជ័យ។ គំនិតនៃការបង្កើតគម្រោងអាចជា៖

- **គំនិតថ្មីដែលមិនធ្លាប់មាន៖** គម្រោងបែបនេះអាចនឹងជួបប្រទះបញ្ហាច្រើន ដែលត្រូវដោះស្រាយ។
- **គំនិតចម្លង៖** គម្រោងដែលធ្លាប់មានគេធ្វើរួចទៅហើយ ដូចនេះត្រូវគិតទៅលើភាពចាំបាច់ ថាតើត្រូវធ្វើម្តងទៀតដើម្បីអ្វី? ឬក៏ត្រូវតែធ្វើម្តងទៀត ដោយហេតុថាគម្រោងមុនបានបញ្ចប់ដោយលទ្ធផលមិនសូវល្អ។
- **ការបំពេញបន្ថែម៖** គម្រោងអាចមានភាពស្រដៀងគ្នាហើយចូលរួមសហការក្នុងការបំពេញបន្ថែមសម្រាប់គម្រោងផ្សេង ដើម្បីទទួលបានផលច្រើនគម្រោងដែលមានតែមួយ។

### ១.៣. ជំនួយ

គម្រោងមួយអាចដំណើរការទៅបានត្រូវមានការឧបត្ថម្ភគាំទ្រ ដើម្បីបន្តការងារទៅមុខទៀត និងធ្វើឱ្យគំនិតបង្កើតបានជារូបរាងពេញលេញ។ ការឧបត្ថម្ភគាំទ្រទាំងនោះរួមមាន៖

- **ការឧបត្ថម្ភជាថវិកា៖** ជាតម្រូវការចាំបាច់សម្រាប់ដំណើរគម្រោង។ ការស្វែងរកថវិកាត្រូវគិតអំពីចំនួននៃតម្រូវការពិតប្រាកដ ប្រភព និងលក្ខខណ្ឌដើម្បីទទួលបានថវិកា។
- **ការឧបត្ថម្ភជារចនាសម្ព័ន្ធ៖** គិតអំពីគុណសម្បត្តិ និងគុណវិបត្តិនៃការគ្រប់គ្រងគម្រោង។ គម្រោងជាផ្នែកនៃកម្មវិធីណាមួយ ជាគម្រោងដាច់ដោយឡែក ឬជាគម្រោងដែលស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័នណាមួយ។
- **ការឧបត្ថម្ភជាសម្ភារៈ៖** មានដូចជាការប្រើប្រាស់ការិយាល័យ ឬយានជំនិះ ជំនួយរដ្ឋបាល ឬអ្នកជំនាញជាដើម។

### **១.៤. ធនធានមនុស្ស**

ធនធានមនុស្សជាសមាសធាតុសំខាន់ ព្រោះថាកត្តាកំណត់ហើយត្រូវចូលរួមអនុវត្តក្នុងដំណើរការគម្រោងដោយផ្ទាល់ដើម្បីឱ្យសម្រេចជាលទ្ធផលបាន។ ធនធានមនុស្សដែលត្រូវជ្រើសរើសត្រូវគិតទៅលើ៖

- តើអ្នកទាំងនោះជាអ្នកនៅក្នុងប្រទេស ឬក្រៅប្រទេស?
- តើយើងអ្នកទាំងនោះជាជនជាតិខ្មែរ ឬបរទេស?
- តើអ្នកទាំងនោះជាអ្នកនៅក្នុងស្ថាប័នឬនៅក្រៅស្ថាប័ន?
- តើគេមានសមត្ថភាពអ្វីខ្លះ?

បើអ្នកទាំងនោះជាអ្នកនៅក្រៅប្រទេស អាចមានបញ្ហាខ្លះក្នុងការកំណត់ពេលវេលា និងត្រូវបូកបញ្ចូលនូវថ្លៃធ្វើដំណើរ ការសុំសិទ្ធស្នាក់នៅជាដើម។

### **១.៥. ទម្រង់**

មានភាពខុសគ្នាក្នុងការអភិវឌ្ឍន៍ និងអនុវត្តន៍គម្រោង បើសិនជាគម្រោងនោះជាគម្រោងដោយឡែក ជាផ្នែកនៃកម្មវិធីមួយ ឬគម្រោងនោះជាកម្មសិទ្ធិរបស់ស្ថាប័នណាមួយ។ ក្នុងករណីខ្លះអាចធ្វើឱ្យមានការងាយ ស្រួលដែរ បើសិនគំនិតរបស់យើងជាផ្នែកនៃកម្មវិធីណាមួយ តែក៏មិនទៀងដែរ។ជួនកាលក៏ជាអត្ថប្រយោជន៍ដែរ បើសិនការអនុវត្តន៍គម្រោងស្ថិត ក្នុងបរិបទរបស់ស្ថាប័នណាមួយជួនកាលក៏មិនដូច្នោះដែរ។

### **១.៦. ពេលវេលា**

សមាសធាតុនៃគម្រោងចុងក្រោយបង្អស់នេះ គឺជាពេលវេលា។ ព្រោះថា គម្រោងអាចសម្រាប់រយៈពេលខ្លី មធ្យម ឬវែង ដែលត្រូវលើ៖

- រៀបចំផែនការ
- ស្វែងរកជំនួយ និងធនធាន
- ចាប់ផ្តើមដំណើរការ
- ធ្វើឱ្យសម្រេចជាស្ថាពរ។

## **២. ដំណើរការរៀបចំផែនការគម្រោង**

ការរៀបចំគម្រោងអាចសរសេរក្នុងទម្រង់ពីរប្រភេទគឺ សំណើគម្រោង និងឯកសារគម្រោង។

## **២.១. សំណើគម្រោង**

សំណើគម្រោងគឺជាឯកសារដែលត្រូវបានសរសេរនៅក្នុងដំណាក់កាលដំបូងពីអ្នកគ្រប់គ្រងគម្រោងដើម្បីស្នើបញ្ជូនទៅកាន់អតិថិជន ដៃគូអភិវឌ្ឍ សប្បុរសជន ឬក៏រដ្ឋាភិបាល។ ការជាសំណើគម្រោងអាចទទួលបានលទ្ធផលជាវិជ្ជមាន ឬអវិជ្ជមាន មានន័យថាគម្រោងខ្លះត្រូវបានគេទទួលឱ្យដើម្បីឱ្យអនុវត្ត ឬខ្លះទៀតមិនត្រូវបានគេទទួលយកនោះទេ គឺវាអាស្រ័យទៅលើតម្រូវការអាទិភាពធនធានរបស់អ្នកដែលត្រូវបានគេស្នើសុំគម្រោង។

ការសរសេរសំណើគម្រោង ត្រូវផ្តោតលើខ្លឹមសារមានលក្ខណៈខ្លីគ្រួសៗ រយៈពេលគម្រោងកញ្ចប់សរុបថវិកា អ្នកគ្រប់គ្រងនិងអ្នកជំនាញ បរិមាណសម្ភារៈនិងឧបករណ៍ដែលត្រូវប្រើបាស់ ដើម្បីស្នើសុំជាធនធានសម្រាប់ការគាំទ្រដំណើរការអនុវត្តគម្រោងអាចប្រព្រឹត្តទៅបាន។

## **២.២. ឯកសារគម្រោង**

ការសរសេរឯកសារគម្រោងគឺច្រើនជាងការសរសេរសំណើសុំសម្ភារៈបន្តិច ព្រោះត្រូវតែមានភាពលម្អិតជាង។ ឯកសារបែបនេះ គឺជាមូលដ្ឋានសម្រាប់ការស្នើសុំថវិកា និងបន្ទាប់មក ដោយមានការបន្ថែម ឬដូរផ្លាស់ខ្លឹមសារតិចតួចសម្រាប់ប្រើប្រាស់ក្នុងការ តាមដាន និងវាយតម្លៃ។ លក្ខណៈលម្អិតនៃឯកសារគម្រោងមានដូចជា៖

- បញ្ជាក់អំពីពេលចាប់ផ្តើម និងពេលបញ្ចប់
- លម្អិតតាមខ្ទង់ចំណាយច្បាស់លាស់
- បញ្ជីឈ្មោះអ្នកដែលចូលរួមក្នុងដំណើរការគម្រោងច្បាស់លាស់
- បញ្ជាក់អំពីសម្ភារៈនិងឧបករណ៍ ទាំងបរិមាណនិងកម្រិតគុណភាពដែលត្រូវយកមកប្រើប្រាស់។

ការសរសេរឯកសារគម្រោងត្រូវមានប្លង់នៃទម្រង់មាន ៣ចំណុចគឺ សេចក្តីផ្តើម ការអនុវត្តន៍ ការចងក្រងជាឯកសារ។

### *ក. សេចក្តីផ្តើម*

សេចក្តីផ្តើមគឺជាផ្នែកដំបូងបង្អស់នៃឯកសារ ដែលសរសេរពីព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងគម្រោង ដូចជា ប្រវត្តិ និងមូលហេតុ ឬគោលបំណងរបស់គម្រោង បរិបទ បើគម្រោងនោះជាផ្នែកមួយនៃកម្មវិធីណាមួយ យើងពិពណ៌នាគ្រួសៗពីកម្មវិធីនោះ អំពីស្ថាប័ន ឬក្រុមដែលនឹងត្រូវគ្រប់គ្រងគម្រោង តើគំនិតរបស់គម្រោងនេះបានបង្កើតដូចម្តេច? ហើយអ្នកណាបានចូលរួមខ្លះ? ។ល។

### *ខ. ការអនុវត្តន៍*

តួសេចក្តីនៃឯកសារគម្រោងត្រូវរួមបញ្ចូលព័ត៌មានទាំងឡាយដែលពាក់ព័ន្ធផ្ទាល់ជាមួយនឹងការអនុវត្តន៍ និងគ្រប់គ្រង។ តួសេចក្តីនៃឯកសារគម្រោងរួមផ្សំដោយសមាសធាតុ ៤ សំខាន់ៗគឺ៖

- **គោលបំណង៖** គោលបំណងនៃគម្រោងមួយ ត្រូវពិពណ៌នាឱ្យជាក់ច្បាស់ ហើយយ៉ាងណាកុំឱ្យមានការខ្វះចន្លោះត្រង់ណាមួយ។ ដូចនេះដើម្បីនឹងសរសេរ ឬកំណត់បំណងរបស់គម្រោង ត្រូវពិចារណាក្នុងកាលៈទេសៈផ្សេងៗឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។
- **គោលដៅ៖** គោលដៅដែលអាចធ្វើបានជាគោលដៅដែលជាទូទៅផ្តល់នូវបរិបទ ស្ថានភាព និងធនធានដែលនឹងត្រូវសម្រេចបាន។ គោលដៅត្រូវមានភាពជាក់លាក់ដោយបង្ហាញនូវព្រំដែនកំណត់នៃការអនុវត្តសកម្មភាពគម្រោង ហើយពាក់ព័ន្ធជាមួយនឹងពេលវេលាច្បាស់លាស់។ **ឧទាហរណ៍៖** ទៅកំសាន្តឆ្នេរសមុទ្រនៅក្រុងព្រះសីហនុ ដោយជិះ រថយន្តតាមផ្លូវជាតិលេខ៤ ចេញដំណើរម៉ោង ៥ ព្រឹក ហើយនឹងទៅដល់ ម៉ោង៩។
- **ផែនការសកម្មភាព៖** ផែនការសកម្មភាព គឺជាបញ្ជីនៃសកម្មភាពភ្ជាប់ជាមួយនឹង ផែនការ ការងារ តារាងកំណត់ពេល វេលា និងផែនការសម្រាប់តាមដាន ជាពិសេសត្រូវត្រៀមបម្រុងទុកនូវហានិភ័យដែលអាចនឹងកើតមានឡើងដោយកត្តាមនុស្ស ឬដោយកត្តាធម្មជាតិ។ ផែនការសកម្មភាពអាចមានទម្រង់ផ្សេងៗគ្នា។
- **សូចនាករ៖** អ្វីមួយដែលកំណត់សម្រាប់វាស់វែងសកម្មភាពនានារបស់គម្រោងមួយ។ សូចនាករបែងចែកជាពីរគឺ សូចនាករសមិទ្ធកម្មសម្រាប់វាស់វែងលទ្ធផលដែលអាចមើលឃើញភ្លាមៗ និងសូចនាករកម្មវិបាកសម្រាប់វាស់វែងលទ្ធផលជាក់ស្តែងដែលប្រាថ្នាចង់បាន។

*គ. ការចងក្រងឯកសារ*

ផ្នែកនេះគឺជាព័ត៌មាន ពិព័ណនាអំពី ថាតើគម្រោង និងលទ្ធផលទាំងឡាយដែលចេញពីសកម្មភាពទាំងឡាយត្រូវទុកដាក់យ៉ាងដូចម្តេច និងនៅកន្លែងណា (ក្រដាស រូបថត ហ្វីល ត្រូវទុកដាក់នៅមូលដ្ឋាន ឬនៅទីស្នាក់ការកណ្តាល ល។ល។)។ លើសពីនេះ ទៀតត្រូវពិពណ៌នាថា តើលទ្ធផលត្រូវផ្សព្វផ្សាយ ដូចម្តេច ? (របាយការណ៍ ការបង្ហាញក្នុងសិក្ខាសាលា ឬសន្និសីទ ការបោះពុម្ពផ្សាយ។ល។)។ ជាចុងក្រោយត្រូវពិពណ៌នាថា តើនៅពេលណា និងតាមរបៀបដូចម្តេចអ្នកឧបត្ថម្ភ និងអ្នកផ្សេងទៀតនឹងទទួលព័ត៌មាន អំពីដំណើរការការងារ? (រាល់ត្រីមាស ឬរាល់ឆ្នាំ ដោយសង្ខេប ឬជា របាយការណ៍ពេញលេញ)។

# មេរៀនទី៥ ការរៀបចំគម្រោងថវិកា

ថវិកាមានសារៈសំខាន់ណាស់ក្នុងដំណើរការគ្រប់គ្រងគម្រោងទាំងមូល។ ការរៀបចំថវិកា គឺមិនមែនគ្រាន់តែជាផ្នែកមួយនៃការធ្វើផែនការឬជាតែជាការគូសបញ្ជាក់នូវគោលនយោបាយរបស់ស្ថាប័នប៉ុណ្ណោះទេ តែជាការរៀបចំយន្តការត្រួតពិនិត្យផងដែរ។ ការរៀបចំសំណើគម្រោងថវិកាមានគោលបំណងធំបំផុតគឺដើម្បីទទួលបាននូវធនធាន(មនុស្ស បរិក្ខារ និងសម្ភារៈ) យកមកប្រើប្រាស់ក្នុងការអនុវត្តគម្រោងឱ្យមានប្រសិទ្ធភាព និងចេញជាលទ្ធផលស្របតាមក្តីរំពឹងទុករបស់ម្ចាស់គម្រោង។

## ១. និយមន័យនិងគោលការណ៍បន្ទុកចំណាយមួយចំនួន

ពាក្យថាបន្ទុកចំណាយនៅក្នុងភាសាគណនេយ្យ គឺសំដៅទៅលើថ្លៃដើមទាំងអស់ដែលត្រូវចំណាយក្នុងដំណើរការអនុវត្តគម្រោង។

- **បន្ទុកចំណាយផ្ទាល់** (Direct cost)៖ ជាបន្ទុកចំណាយដែលរួមចំណែកដោយផ្ទាល់ទៅនឹងកិច្ចការឬការងារគម្រោងអ្វីមួយ។ ឧទាហរណ៍៖ ការចំណាយទៅលើប្រាក់ម៉ោងសម្រាប់ជួលលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យមកបង្រៀននៅក្នុងសាលាភូមិន្ទរដ្ឋបាល។ ចំណាយលើការឧបត្ថម្ភប្រាក់បន្ថែមសម្រាប់លោកគ្រូ អ្នកគ្រូជំនួយ ដែលទទួលបន្ទុកថ្នាក់រៀននីមួយៗក្នុងវគ្គបណ្តុះបណ្តាលសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១៣ ជាដើម។ ប្រហាក់ប្រហែលគ្នានេះដែរចំពោះការចំណាយលើសម្ភារៈ និងចំណាយផ្សេងៗទៀតដែលចូលរួមដោយផ្ទាល់ក្នុងគម្រោងត្រូវបានចាត់ទុកថាជាការចំណាយផ្ទាល់របស់គម្រោង។
- **បន្ទុកចំណាយថេរ** (Fix cost)៖ ជាបន្ទុកចំណាយតាមរយៈការផ្តល់នៃការសម្របសម្រួលនិងសេវាដូចជាប្រាក់បៀវត្សប្រចាំខែរបស់បុគ្គលិក ចំណាយសម្ភារៈនៅក្នុងថ្នាក់រៀន ការិយាល័យ (តុ ទូសៀវភៅ កៅអី) ការគ្រប់គ្រងសេវាសង្គមកិច្ច របបសន្តិសុខសង្គម (បសស) ការបណ្តុះបណ្តាល គណនេយ្យថ្លៃដើមនិងគ្រប់គ្រង រដ្ឋបាលទូទៅ អគ្គីសនីទាំងអស់នេះសុទ្ធតែតម្រូវឱ្យមានដើម្បីដំណើរការអាជីវកម្ម។
- **បន្ទុកចំណាយប្រែប្រួល** (Variable cost)៖ បន្ទុកចំណាយដែលគេអាចហៅថាមិនប្រែប្រួលបានលុះត្រាតែ ទំហំការងារដែលត្រូវធ្វើអាចប្រែប្រួលពីសូន្យរហូតដល់ច្រើនបំផុត ហើយបន្ទុកចំណាយនោះស្ថិតនៅដដែល។ បន្ទុកចំណាយនោះរួម មានប្រាក់បៀវត្សសម្រាប់ការគ្រប់គ្រងនិងរដ្ឋបាល ថ្លៃឈ្នួលអគារ ថ្លៃធានារ៉ាប់រង ថ្លៃថែទាំអគារ។ល។ ក្នុងក្រុមហ៊ុនឬការផលិតធំៗដើម្បីឱ្យងាយស្រួលគេច្រើនហៅវាចំណាយផ្សេងៗឬចំណាយមិនផ្ទាល់។

- **បន្ទុកកម្លាំងពលកម្ម (Labor burden)៖** ជាទូទៅគឺជាចំណាយសម្រាប់ថ្លៃឈប់សម្រាក ព្យាបាលជំងឺ ឬអវត្តមានផ្សេងទៀតដែលត្រូវគិតសម្រាប់និយោជិកម្នាក់ៗ។ ចំនួននេះត្រូវចេញដោយនិយោជកហើយជាផលកម្រៃរបស់និយោជិក។
- **បន្ទុកចំណាយសម្ភារៈ (Material burden)៖** ការទិញសម្ភារៈសម្រាប់ប្រើប្រាស់នៅក្នុងគម្រោង។ អ្នកទទួលការងារធ្វើតែងតែត្រូវការចំណាយមួយចំនួនសម្រាប់ការគ្រប់គ្រង និងកាន់កាប់សម្ភារៈនោះ ហើយអាចគិតជាការចំណាយពី១៥ទៅ២៥ភាគរយនៃតម្លៃសម្ភារៈនោះ ជួនកាលក៏អាចតិចជាង១៥ភាគរយដែរ។
- **ការតម្លើងបន្ទុកចំណាយ៖** ការតម្លើងបន្ទុកចំណាយ គឺជាការបង្កើនបន្ទុកចំណាយណាមួយរបស់គម្រោងដោយប្រៀបធៀបកាលបរិច្ឆេទ២ខុសគ្នា។ គេច្រើនប្រើទំហំសម្រាប់បញ្ជាក់នូវអត្រាប្រចាំឆ្នាំគិតជាភាគរយ។

## ២. ការប៉ាន់ស្មានថវិកាគម្រោង

ការព្យាករណ៍ជាមុនអំពីតម្រូវការធនធានពិតជាសំខាន់ណាស់ដើម្បីរៀបចំគម្រោងថវិកាសម្រាប់អនុវត្តដំណើរគម្រោងមួយមានប្រសិទ្ធភាព ដោយគិតគូរនូវលក្ខខណ្ឌដូចជា ថាតើគម្រោងត្រូវការធនធានអ្វីខ្លះ ចំនួនប៉ុន្មានសម្រាប់ធនធានមួយមុខៗ ពេលណាដែលត្រូវការ ហើយត្រូវចំណាយប៉ុន្មាន និងគិតបន្ថែមទាំងឥទ្ធិពលនៃអតិផរណាតម្លៃដែលអាចកើតមានឡើង។ ទោះបីយ៉ាងណាក៏ដោយ ក៏តែងតែមានភាពមិនជាក់ច្បាស់នៅគ្រប់ពេលទាំងអស់ក្នុងការព្យាករណ៍ទោះតិចក្តីច្រើនក្តី។ ទោះបីជាការប៉ាន់ស្មានហាក់ដូចជាមានភាពងាយស្រួលដោយអាស្រ័យលើបទពិសោធន៍របស់អ្នកប៉ាន់ស្មាន ប៉ុន្តែក៏មិនត្រូវធ្វើការពឹងលើទម្លាប់បានដែរ ព្រោះថាគម្រោងភាគច្រើនជាការថ្មីដែលមិនធ្លាប់មានពីមុនមក។

### ២.១. ការរៀបចំថវិកាពីថ្នាក់លើចុះក្រោម

ការរៀបចំថវិកាប្រភេទនេះ គឺផ្អែកលើមូលដ្ឋាននៃការវាយតម្លៃ និងបទពិសោធន៍របស់អ្នកគ្រប់គ្រងថ្នាក់ខ្ពស់និងថ្នាក់កណ្តាល និងទិន្នន័យដែលពាក់ព័ន្ធនឹងសកម្មភាពប្រហាក់ប្រហែលគ្នា។ អ្នកគ្រប់គ្រងទាំងនេះប៉ាន់ស្មានថវិកាគម្រោងជាទូទៅ និងអនុគម្រោងទាំងឡាយដែលអាចរួមផ្សំជាគម្រោងទាំងមូលនោះ។ បន្ទាប់មកការប៉ាន់ស្មាននេះត្រូវបានប្រគល់ឱ្យអ្នកគ្រប់គ្រងបន្ទាប់ដើម្បីបន្តការប៉ាន់ស្មាន ចំពោះការងារដោយឡែកៗដែលនឹងផ្សំជាអនុគម្រោង។ ការរៀបចំថវិកាបែបនេះក៏មាននូវគុណសម្បត្តិ និងគុណវិបត្តផងដែរដូចជា៖

*ក. គុណសម្បត្តិចំនួន២សំខាន់ៗ៖*

- មិនសូវមានការលំអៀងទេ ព្រោះអ្នកដឹកនាំថ្នាក់លើៗមានបទពិសោធន៍គ្រប់គ្រាន់ក្នុងការរៀបចំថវិកា
- មានការចំណាយតិចតួចសម្រាប់ការងារនេះព្រោះមានអ្នកចូលរួមតិច។

*ខ. គុណវិបត្តិ៖*

- បុគ្គលិកមិនសូវមានបទសោធន៍
- លំបាកក្នុងការចំណាយ។

## ២.២. ការរៀបចំថវិកាពីថ្នាក់ក្រោមឡើងលើ

គ្រប់ភាគីដែលនឹងចូលរួមធ្វើការក្នុងគម្រោងត្រូវបានចូលរួមក្នុងការពិភាក្សាអំពីពេលវេលានិងថវិកាចំពោះការងារដែលគេត្រូវបំពេញដើម្បីធានានូវភាពជាក់ច្បាស់កម្រិតខ្ពស់។ ចាប់ផ្តើមប៉ាន់ស្មានជាដំបូងគឺគិតពីធនធានដូចជាកម្លាំងពលកម្ម គិតជាម៉ោង ឬថ្ងៃនិងសម្ភារៈ ដែលត្រូវគណនាគិតចេញជាទឹកប្រាក់។ វិធីសាស្ត្រនៃការរៀបចំថវិកាបែបនេះគឺ៖

1. ប្រធានគម្រោងកំណត់ការងារទៅឱ្យបុគ្គលិក
2. បុគ្គលិករៀបកញ្ចប់ថវិកាដើម្បីអនុវត្តការងារ
3. ប្រធានគម្រោងបូកសរុប បន្ទុកចំណាយផ្ទាល់រួមជាមួយបន្ទុកចំណាយមិនផ្ទាល់
4. ប្រធានគម្រោងធ្វើការអនុម័ត និងបែងចែកថវិកា
5. បុគ្គលិកធ្វើការស្នើសុំថវិកាដើម្បីយកទៅអនុវត្តការងារ

ការរៀបចំថវិកាពីថ្នាក់ក្រោមទៅលើគឺពិតជាមានភាពជាក់លាក់និងល្អិតល្អន់ ព្រោះគ្រប់ផ្នែកទាំងអស់ត្រូវបានបូកបញ្ចូល ដែលជាការលំបាកក្នុងការបង្កើតជាបញ្ជីការងារសរុបមួយ។ ទន្ទឹមនឹងនេះដែរបុគ្គលិកថ្នាក់ក្រោមក៏អាចពន្លើសថវិកាដែរ។

*ក. គុណសម្បត្តិ*

- បុគ្គលិកទទួលបានបទពិសោធន៍
- មានភាពងាយស្រួលក្នុងការចំណាយ

*ខ. គុណវិបត្ត*

- ប្រើពេលវេលាយូរក្នុងការរៀបចំ
- លទ្ធផលបំប៉ោង ដោយការពន្លើសថវិកាពីបុគ្គលិកថ្នាក់ក្រោម។

- *ការអនុវត្តញឹកញាប់ធ្វើគេតែងរៀបចំថវិកាពីលើទៅក្រោម ជាជាងការរៀបចំពីក្រោមទៅលើ ព្រោះថាអ្នកគ្រប់គ្រងជាន់ខ្ពស់តែងគិតអំពីហានិភ័យថវិកានៃដំណើរការរៀបចំពីក្រោមទៅលើ ដែលជាឧបករណ៍សំខាន់បំផុតសម្រាប់ត្រួតពិនិត្យស្ថាប័ន។*

## ២.៣. ការរៀបថវិកាផ្អែកលើសកម្មភាព

ការរៀបចំថវិកាតាមបែបនេះគឺពឹងផ្អែកលើទិន្នន័យរបស់ប្រព័ន្ធគណនេយ្យបានន័យថា ការកំណត់តម្លៃត្រូវពឹងផ្អែកលើសកម្មភាព។ ការចំណាយដោយឡែកៗទាំងឡាយត្រូវបានចាត់ទុកថាជាថវិកាមូលដ្ឋាន ដូចជាថ្លៃទូរសព្ទ សម្ភារៈ ទឹក ភ្លើង កម្លាំងពលកម្មផ្ទាល់ ឬប្រមូលផ្តុំទៅនឹងមជ្ឈមណ្ឌលផលិតឬកែច្នៃ។

ការរៀបចំថវិកាផ្អែកលើសកម្មភាព ជាទូទៅត្រូវបានអនុវត្តនៅក្នុងក្របខណ្ឌអង្គភាពមួយដោយៈ

- ដកចេញពីផែនការយុទ្ធសាស្ត្រ (រយៈពេលវែង)
- ដកចេញពីផែនការប្រតិបត្តិ (រយៈពេលមធ្យម)
- ដកចេញពីផែនការសកម្មភាព

**ក. គុណសម្បត្តិៈ** ងាយស្រួលត្រួតពិនិត្យថវិកាតាម ទីកន្លែង និងពេលវេលា។

**ខ. គុណវិបត្តៈ** ប្រើពេលវេលាយូរ ហើយស្មុគស្មាញក្នុងការរៀបចំ ដោយតម្រូវឱ្យអ្នករៀបចំដឹងពីលំហូរនៃសកម្មភាពជាមុន។

## ២.៤. ការរៀបចំថវិកាសមិទ្ធកម្ម

ការរៀបចំថវិកាសមិទ្ធកម្មច្រើនប្រើប្រាស់ក្នុងស្ថាប័នសាធារណៈដើម្បីឆ្លុះបញ្ចាំងពីប្រភពនិងសេវាកម្មជាធាតុចេញនៃការប្រើប្រាស់ថវិកា ដែលបានបង្ហាញនូវទំនាក់ទំនងរវាងការប្រើប្រាស់ចំណូលពន្ធដែលប្រមូលបាននិងសេវាកម្មដែលផ្តល់ដោយស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិមានប្រសិទ្ធផល។

*ក. គុណសម្បត្តិ*

- មានការទទួលខុសត្រូវខ្ពស់របស់អាជ្ញាធរមូលដ្ឋានចំពោះពលរដ្ឋដែលជាអ្នកបង់ពន្ធ
- ពលរដ្ឋមានទំនាក់ទំនងទៅនឹងស្ថាប័នសាធារណៈកាន់តែល្អប្រសើរអំពី អាទិភាព និងគោលបំណងដោយឡែក
- ពលរដ្ឋអាចដឹងបាន ថាប្រាក់របស់គាត់ប្រើប្រាស់សម្រាប់ធ្វើអ្វី និងដើម្បីអ្វី។

*ខ. គុណវិបត្ត*

- អាចមានការភ័ន្តច្រឡំលើលទ្ធផលក្នុងករណីដែលស្ថាប័នសាធារណៈមានប្រភពថវិកាច្រើន
- បើមានការកែសម្រួលទិន្នន័យដើម្បីសម្រេចឱ្យបានគោលដៅមួយអាចតម្រូវឱ្យមានការចំណាយទៅលើភាគីឯករាជ្យណាមួយដើម្បីផ្ទៀងផ្ទាត់លទ្ធផល
- ពុំមានភាពបត់បែនចំពោះផលធៀបរវាងធាតុចូលនិងធាតុចេញដែលបានកំណត់។

# មេរៀនទី៦ ការរៀបចំគម្រោងពេលវេលា

ការងារគម្រោងចាំបាច់ត្រូវមានការរៀបចំគម្រោងពេលវេលាឱ្យបានច្បាស់លាស់ជាមុន ដើម្បីឱ្យការបញ្ចប់គ្រោងទៅដោយរលូនត្រឹមត្រូវតាមការកំណត់។ ការប្រើប្រាស់គម្រោងពេលវេលាត្រូវតែមានគ្រប់គម្រោងទាំងអស់ ប៉ុន្តែចំពោះ គម្រោងខ្លះងាយដូចជាការរៀបចំអាហារពេលល្ងាច ហើយខ្លះទៀតលំបាក ស្មុគស្មាញដូចជាការរៀបចំការបោះឆ្នោតឬកីឡាអូឡាំពិចជាដើម។

## ១. បរិយាកាសនៃការរៀបចំគម្រោងពេលវេលា

អ្នកណាម្នាក់ដែលមានបំណងរៀបចំផែនការសម្រាប់គម្រោងក្នុងទំហំជាច្រើនទាំងខាងក្នុង និងខាង ក្រៅដែលអាចមានឥទ្ធិពលលើគម្រោង។ គុណភាពនៃការរៀបចំផែនការ និងគម្រោង ពេលវេលានឹងមានឥទ្ធិពលទៅលើលទ្ធផលដែលរំពឹងទុក សម្រាប់ស្ថាប័នឬការចាត់ចែងគម្រោងផ្សេងទៀត។ តំណាងយ៉ាងងាយបំផុតសម្រាប់គំនិតនេះ។

### ១.១. កត្តាខាងក្រៅ

កត្តាខាងក្រៅជាព្រឹត្តិការណ៍និងលក្ខខណ្ឌដែលនៅក្រៅពីការគ្រប់ គ្រងគម្រោង។កត្តាខ្លះអាចតម្រូវឱ្យគម្រោងបញ្ចប់ទាំងស្រុងក៏មានដែរ។

#### ក. កត្តាធម្មជាតិ

គ្រប់គម្រោងទាំងអស់សុទ្ធតែមានហានិភ័យ ហើយក្នុងចំណោមនោះ មួយចំនួនអាចមានឥទ្ធិពលយ៉ាងខ្លាំងដល់ផែនការគម្រោង។ ហានិភ័យទាំងនោះដូចជា៖

- ការរញ្ជួយដីនៅទីស្នាក់ការកណ្តាលរបស់គម្រោង
- ខ្យល់ព្យុះ និងទឹកជំនន់រំខានការងារគម្រោង
- ជំងឺរាលដាលធ្វើឱ្យឈឺដល់បុគ្គលិកអស់
- អ្នកគ្រប់គ្រងគម្រោងត្រូវស្លាប់ដោយចៃដន្យ។

#### ខ. នយោបាយពន្ធដារ

ជាគោលនយោបាយរបស់រដ្ឋាភិបាលពាក់ព័ន្ធនឹងការបង់ពន្ធ និងបញ្ហាហិរញ្ញវត្ថុផ្សេងៗទៀតដែលអាចមានឥទ្ធិពលដល់គម្រោង និងផែនការគម្រោង។ បើគម្រោងគាំទ្រដោយរដ្ឋាភិបាល។ ឧ. ក្នុងវិស័យយោធាអាច លុប ឬបោះបង់ចោលតាមរយៈការសម្រេចចិត្តផ្នែកនយោបាយ។

#### គ. យុទ្ធសាស្ត្រប្រតិបត្តិការ

ការសម្រេចចិត្តជាយុទ្ធសាស្ត្រដោយអ្នកគ្រប់គ្រងនៅខាងក្រៅ និងនៅថ្នាក់លើគម្រោង អាចមានឥទ្ធិពលយ៉ាងច្រើនដល់គម្រោង។ ឧទាហរណ៍ ដូចជា៖

- អ្នកគ្រប់គ្រងជាន់ខ្ពស់បានសម្រេចចិត្តឱ្យក្រុមផ្សេងទៀតជាអ្នកអនុ វត្តគម្រោង មិនមែនជាក្រុម ដែលបានគិតគូពីមុនមក។
- ការសម្រេចចិត្តមួយបានធ្វើឡើង ហើយតម្រូវឱ្យការចាប់ផ្តើម គម្រោងត្រូវពន្យាពេលដោយថវិកា គ្រោងទុករបស់គម្រោងត្រូវយកទៅប្រើ ប្រាស់សម្រាប់គោលដៅផ្សេង។
- មានការសម្រេចចិត្តថាមិនត្រូវជ្រើសរើសបុគ្គលិកថ្មី ដើម្បីកាត់បន្ថយ ការចំណាយ ដែលកាលពីមុនមករំពឹងថាសម្រាប់គម្រោង។
- អ្នកគ្រប់គ្រងជាន់ខ្ពស់បានផ្លាស់ប្តូរគំនិតអំពីអាទិភាពរបស់គម្រោង ដែលបានព្រមព្រៀងទុកពីមុនមក។

### ឃ. បទបញ្ញាផ្នែកច្បាប់

បទបញ្ញត្តិថ្នាក់ជាតិ និងថ្នាក់ខេត្តអាចជំរុញឱ្យមានការពាក់ព័ន្ធ ជាមួយអ្នករៀបចំគម្រោងនិងអ្នកទទួលការងារធ្វើ ដែលត្រូវគិតពិចារណា ដល់តំណាក់កាលនៃការរៀបចំផែនការ។ បើគម្រោងត្រូវអនុវត្តនៅក្រៅ ប្រទេសរឹតតែមានសារៈសំខាន់ទៅទៀត ព្រោះជាកន្លែងដែលអ្នកគ្រប់គ្រង គម្រោងត្រូវដឹងពីបទបញ្ញាការងារ សង្គមកិច្ច បច្ចេកទេស និងពាណិជ្ជកម្ម របស់ប្រទេសនោះ មុននឹងភ្ជាប់ធនធានទៅនឹងផែនការ។

## ១.២. កត្តាការងារ

កត្តាដែលមានឥទ្ធិពលលើការងារប្រចាំថ្ងៃរបស់អ្នកគ្រប់គ្រងគម្រោងមានដូចជា៖

- កង្វះនូវសេវាគាំទ្រ និងជំនាញគ្រប់គ្រង
- រចនាសម្ព័ន្ធស្ថាប័នមិនច្បាស់លាស់
- នីតិវិធីនិងប្រព័ន្ធការងារស្មុគស្មាញ
- សមត្ថភាពបច្ចេកទេស
- ឥរិយាបទនិងវប្បធម៌កន្លែងការងារ
- ខ្វះខាតនូវផ្នែកទំនាក់ទំនងការងារ
- កង្វះធនធាននិងសមត្ថភាពអនុវត្តការងារ។

## ១.៣. កត្តារួមចំណែកជាមួយលទ្ធផល

ការរៀបចំផែនការនិងគម្រោងពេលវេលាប្រកបដោយប្រសិទ្ធភាព ជាកត្តាចាំបាច់ដែលនាំឱ្យការងារមានប្រសិទ្ធភាពដែរ។ កត្តាដែលរួមចំណែកជាមួយលទ្ធផលមានដូចជា៖

- **គុណភាព៖** សុវត្ថិភាព ភាពជឿជាក់បាន ការស្តែងឡើង និងភាពល្បីល្បាញ។
- **ពេលវេលា៖** គម្រោងបញ្ចប់ទាន់ពេលវេលា។
- **ភាពចំណេញ៖** បន្ទុកចំណាយបានប្រើប្រាស់ត្រឹមត្រូវតាមការកំណត់។

## ២. រចនាសម្ព័ន្ធបំបែកការងារ

ការគិតជាមូលដ្ឋានដំបូងបង្អស់ក្នុងការរៀបចំផែនការគឺរចនាសម្ព័ន្ធ បំបែកការងារ។ រចនាសម្ព័ន្ធបែងចែកការងារ បែងចែកបំណងជាទូទៅ របស់គម្រោងឱ្យទៅជាសមាសធាតុការងារ។ សមាសធាតុការងារ នោះគឺជាឯកតាការងារ។ ឧទាហរណ៍៖ គម្រោងធ្វើកិច្ចការស្រាវជ្រាវសម្រាប់មុខវិជ្ជាមួយរបស់និស្សិត។

## ៣. ការប្រើប្រាស់តារាង

ជាទូទៅ ដើម្បីសម្រួលដល់ការងាររៀបចំគម្រោង គេអាចប្រើប្រាស់នូវតារាងចំនួន ៣ ដូចជា៖ តារាងខ្វែង តារាងពេល និងតារាងហ្គិន។

### ៣.១. តារាងខ្វែង និងតារាងពេល

តារាងបែបខ្វែង និងតារាងពេលគឺប្រើប្រាស់បានដូចគ្នាដែរសម្រាប់ពេលដែល៖

- គម្រោងតូចតាចមានបុគ្គលិកតិច
- សម្រាប់អ្នកគ្រប់គ្រងជាន់ទាប
- មានសម្ភារៈ បរិក្ខា តិច។

ឧ. កាលវិភាគសិក្សា គម្រោងនិពន្ធសៀវភៅ។

**តារាងខ្វែងនៃគម្រោងនិពន្ធសៀវភៅ**

| ឈ្មោះជំពូក | អ្នកនិពន្ធគ្រោង | អ្នកនិពន្ធជាក់ស្ដែង | ទឹកប្រាក់ | ពេលកំណត់ | ជំពូកយល់ព្រម | ខុទាត់ឱ្យអ្នកនិពន្ធ | កែសម្រួល | បរិយាយ |
|---|---|---|---|---|---|---|---|---|
| ១. | | | | | | | | |
| ២. | | | | | | | | |
| ៣. | | | | | | | | |
| ៤. | | | | | | | | |
| ៥. | | | | | | | | |
| ៦. | | | | | | | | |
| ៧. | | | | | | | | |

### ៣.២. ដំហាននៃការរៀបចំតារាងពេល

- បំបែកការងារឱ្យតូចៗ
- រៀបការងារតាមលំដាប់អាទិភាព ដោយការងារដែលធ្វើមុនត្រូវដាក់ខាងលើ និងការងារដែលធ្វើបន្ទាប់ត្រូវដាក់ខាងក្រោមបន្តបន្ទាប់
- កំណត់កាលបរិច្ឆេទនៃការចាប់ផ្ដើមនិងបញ្ចប់របស់សកម្មភាពនីមួយៗ

**តារាងពេលនៃគម្រោងផលិតកុំព្យូទ័រ**

| បញ្ជីការងារ | ចាប់ផ្ដើម | បញ្ចប់ |
|---|---|---|
| រចនារូបរាងនិងគូ | ១៦ ខែមេសា ឆ្នាំ២០២១ | ១៨ ខែឧសភា ឆ្នាំ២០២១ |
| ទិញសម្ភារៈ | ២១ ខែឧសភា ឆ្នាំ២០២១ | ១៥ ខែមិថុនា ឆ្នាំ២០២១ |
| ផលិត | ០៨ ខែមិថុនា ឆ្នាំ២០២១ | ២៩ ខែមិថុនា ឆ្នាំ២០២១ |
| ផ្គុំនិងសាកល្បង | ០២ ខែកក្កដា ឆ្នាំ២០២១ | ០៩ ខែកក្កដា ឆ្នាំ២០២១ |

### ៣.៣. តារាងហ្គិន (Gantt Chart)

តារាងហ្គិនមានការប្រើប្រាស់ច្រើន និងមានអត្ថប្រយោជន៍ខ្លាំងក្នុងការរៀបចំផែនការដែលមានភាពងាយស្រួលក្នុងការគូស និងបកស្រាយ។ តារាងនេះយកឈ្មោះតាមវិស្វករឧស្សាហកម្មអាមេរិកកាំងម្នាក់ឈ្មោះ Henry Gantt (១៨៦១-១៩១៩)។ តារាងហ្គិនមានលក្ខណៈសម្គាល់ដូចជា៖

- បន្ទាត់ឈរខាងឆ្វេងដែលសម្រាប់ដាក់ការងារដែលត្រូវធ្វើ
- បន្ទាត់ឈរខាងស្ដាំបន្តបន្ទាប់ត្រូវមានទំហំស្មើៗគ្នា
- ១បន្ទាត់ឈរ = ១ឯកតានៃពេល។

### ៣.៤. ជំហាននៃការរៀបចំតារាងហ្គិន

- បំបែកការងារឱ្យតូចៗ
- រៀបការងារតាមលំដាប់អាទិភាព
- កំណត់រយៈពេលនៃសកម្មភាពនីមួយៗដោយប្រើឯកតានៃពេលដូចគ្នា
- កំណត់ពេលដែលគ្មានសកម្មភាព (បើជារបស់បុគ្គលដែលអាចដឹងមុនបាន បើជារបស់សាធារណៈតាមគោលការណ៍កំណត់របស់អង្គភាព)

**តារាងហ្គិន**



## មេរៀនទី៧ ការរៀបចំផែនការធនធាន

ក្នុងកម្រិតយុទ្ធសាស្ត្រការរៀបចំផែនការធនធានជាប្រធានបទស្មុគស្មាញ ដែលជាកិច្ចការសំខាន់សម្រាប់រៀបចំផែនការរយៈពេលវែងរបស់ស្ថាប័នបណ្តុះបណ្តាលភាគច្រើន។ ការរៀបចំផែនការធនធានចូលរួមចំណែកក្នុងដំណើរការរៀបចំគម្រោងសម្រាប់រយៈពេលខ្លី ឬវែងដើម្បីឱ្យមានភាពច្បាស់លាស់និងប្រសិទ្ធភាពខ្ពស់ស្របតាមគោលបំណងនៃការគ្រោងទុក។

### ១. ប្រភេទផ្សេងៗរបស់ធនធាន

ធនធានរបស់គម្រោងមួយរួមមាន ធនធានមនុស្ស បរិក្ខា សម្ភារៈឬថវិកា ដើម្បីសម្រេចគោលបំណងរបស់គម្រោងនោះ។ គេអាចបែងចែកជា៖

#### ១.១. ធនធានមិនអាចជំនួសបាន

ធនធានខ្លះមានការកំណត់និងមិនអាចមានច្រើនឡើយសម្រាប់គម្រោង កាលណាប្រើហើយអស់ គឺមិនអាចរកមកបន្ថែមបានឡើយដូចជា ពេលវេលា និងធនធានរ៉ែជាដើម។ ពេលវេលាគឺជាធនធានសំខាន់បំផុតមានកាលកំណត់ជាក់លាក់សម្រាប់ការអនុវត្តគម្រោងដោយមិនអាចជំនួសបាន។ ដូចនេះហើយចាំបាច់ត្រូវតែមានបច្ចេកទេសក្នុងការរៀបចំផែនការនិងគម្រោងពេលវេលាឱ្យបានត្រឹមត្រូវ។

ក្រៅពីពេលវេលាធនធានមិនអាចជំនួសបានមានដូចជា រ៉ែ (ធ្យូងថ្ម ប្រេងកាត និងឧស្ម័នធម្មជាតិ) និងការស្តុកទុករបស់ធម្មជាតិផ្សេងៗទៀត។

#### ១.២. ធនធានអាចបន្ថែមបាន

សម្ភារៈ និងធនធានផ្សេងទៀតដែលបានមកតាមរយៈការទិញ គឺអាចបន្ថែមបាន។ ទោះជាស្តុកនៃធនធានទាំងនោះអាចអស់ក៏ពិតមែន ដោយបានយកទៅប្រើប្រាស់សម្រាប់គម្រោង តែគេអាចទិញយកមក ជំនួសបាន។ ថវិកាជាធនធានកម្រ គេអាចចាត់ទុកថាជាធនធានមិនអាចជំនួសបាន។ ប៉ុន្តែបើនិយាយពីថវិកាសម្រាប់គម្រោងវិញ គេអាចចាត់ទុកថាជាធនធានអាចជំនួសបានដោយការខ្ចីបង្វែរពីដៃគូណាមួយបាន។

#### ១.៣. ធនធានអាចប្រើឡើងវិញបាន

ធនធានដែលអាចប្រើប្រាស់ម្តងទៀតបានគឺជាទ្រព្យសកម្ម តម្រូវឱ្យមានសម្រាប់ការងារគម្រោង ប៉ុន្តែធនធានប្រភេទនេះអាចនៅសល់សម្រាប់ប្រើប្រាស់ក្នុងគម្រោងក្រោយៗទៀត។ ធនធានទាំងនេះរួមមានបរិក្ខា អគារ ការិយាល័យ ការិយាល័យ រោងចក្រ មនុស្សជាដើម។ មនុស្សជាធនធានពិសេសដែលពោរពេញដោយបទពិសោធន៍ការងារច្រើនសម្រាប់អនុវត្តគម្រោងក្រោយទៀត។

## ២. ករណីសិក្សាៈ គម្រោងសង់យានដ្ឋាន

ករណីសិក្សាស្តីពីគម្រោងសាងសង់យានដ្ឋានខាងក្រោមនេះចង់បង្ហាញពីគោលការណ៍ និង បញ្ហាខ្លះនៃការរៀបចំផែនការធនធាន។

### ២.១. និយមន័យ-គម្រោងយានដ្ឋាន

ក្រុមហ៊ុនតូចមួយទទួលភារកិច្ចសង់យានដ្ឋានមួយនៅជាប់តែងង។ សំណង់នេះត្រូវសង់អំពីឥដ្ឋប្រក់ស័ង្កសី។ ដំបូលនេះមានដាក់ស័ង្កសីភ្លឺសម្រាប់ឱ្យពន្លឺចូលជំនួសឱ្យការធ្វើបង្អួច។ គ្រោងទ្វារធ្វើអំពីឈើនិងដាក់ត្រចៀក។ ក្នុងគម្រោងនេះពុំមានលើកអ្វីធ្ងន់ទេ ហើយក៏ពុំមានសកម្មភាពណាត្រូវការធនធានមនុស្សលើសពី២នាក់ដែរ។ ក្រុមហ៊ុនដែលនឹងទទួលការងារនេះធ្វើមានមនុស្សតែ២នាក់ គឺឪពុកនិងកូន។ ឪពុកមិនអាចលើកវត្ថុអ្វីធ្ងន់បានទេ តែមានបទពិសោធន៍គ្រប់កិច្ចការសាងសង់ទាំងអស់ ចំណែកកូនវិញមានរាងកាយមាំមួន ប៉ុន្តែមិនសូវមានបទពិសោធន៍។

### ២.២. តារាងហ្គិន

ការប្រើប្រាស់តារាងហ្គិននៅពេលនេះ គឺជំនួសឱ្យការប្រើកុំព្យូទ័រដើម្បីរៀបចំផែនការធនធាន។ បង្ហាញនូវលទ្ធផលដំបូងរបស់គម្រោងនេះ ដោយការងារនីមួយៗដាក់នៅកន្លែងដែលអាចចាប់ផ្តើមលឿនបំផុត។ បន្ទាត់ផ្តេកមួយតំណាងឱ្យសកម្មភាពរបស់គម្រោងមួយ ហើយប្រវែងរបស់បន្ទាត់តំណាងឱ្យរយៈពេលរបស់សកម្មភាពប្រឡោះគិតស្មើមួយថ្ងៃ។ មួយគម្រោងនេះចាប់ផ្តើមនៅថ្ងៃទី១៣ ឧសភា ហើយប្រតិទិននេះ បាន លុបចោលនូវចុងសប្តាហ៍ និងការឈប់សម្រាកជាសាធារណៈដើម្បីឱ្យ មានភាពងាយស្រួល។

តារាងទី៧.១-៖គម្រោងយានដ្ឋាន-ការប្រមូលផ្តុំធនធានងាយៗ



### ក. ការរួមផ្គុំធនធានងាយៗ

គ្រប់សកម្មភាពទាំងអស់នៅលើតារាងហ្គិនក្នុងតារាង៧.១-បង្ហាញនូវពេលអាចចាប់ផ្តើមលឿនបំផុត។ ជាមួយគ្នានេះដែរ ក៏ពុំមានការគិតអំពីផែនការធនធានដែរ គឺគ្រាន់តែបូកបញ្ចូលនូវចំនួនពេលសម្រាប់បន្ទាត់ឈរ នីមួយៗតំណាងឱ្យថ្ងៃធ្វើការតែប៉ុណ្ណោះ។

ធនធានដែលត្រូវការប្រចាំថ្ងៃស្ថិតនៅក្នុងតារាងតូចផ្នែកខាងក្រោមលទ្ធផលដែលបានមកគេអាចនិយាយបានថាមិនពេញចិត្ត។ ថ្ងៃខ្លះពុំមានតម្រូវការកម្មករ ចំណែកថ្ងៃខ្លះទៀតត្រូវការរហូតដល់ទៅ៣នាក់។

មូលហេតុដែលនាំឱ្យគម្រោងធនធានទៅជាបែបនេះ ព្រោះអ្នករៀបចំផែនការ បានកំណត់ការចាប់ផ្តើមរបស់សកម្មភាពនីមួយៗនៅពេលដែល អាចលឿនបំផុតដោយពុំបានគិតគូរពីតម្រូវការឬអាទិភាពឡើយ។

### ខ. គម្រោងមានធនធានកំណត់

បើសិនជាគម្រោងសាងសង់តម្រូវឱ្យតែ២នាក់ ឪពុកនិងកូនធ្វើទេ ការរៀបចំដូចក្នុងរូបទី៧.១-មិនអាចអនុវត្តបានទេ។ គម្រោងពេលវេលាត្រូវរៀបចំឡើងវិញធ្វើយ៉ាងណាកុំឱ្យធនធានដែលមានតិចតួចប្រើហួសដែនកំណត់។ ដោយការប្រើប្រាស់តារាងអាចកែតម្រូវបាន សកម្មភាពទាំងឡាយអាចរំកិលទៅឆ្វេងឬទៅស្តាំបាន ដើម្បីឱ្យបន្ទាត់ឈរនីមួយៗដែលតំណាងឱ្យការងារមួយថ្ងៃមានធនធានមិនលើសពីការកំណត់។ ទោះជាតម្រូវឱ្យមានការរំកិលយ៉ាងនេះក៏ដោយ ក៏មិនត្រូវភ្លេចពីភាពសមស្របរបស់ការងារដែរ ហើយជាពិសេសទៅទៀត គឺកម្រិតកំណត់រវាងសកម្មភាពទាំងឡាយ។

**តារាងទី៧.២-៖ គម្រោងយានដ្ឋាន-ធនធានកំណត់**



រូបទី៧.២- គឺជាតារាងពេលវេលាសម្រាប់គម្រោងគម្រោងសង់យានដ្ឋានបន្ទាប់ពីបានសម្រួលក្នុងគោលបំណងរៀបចំគម្រោងពេលវេលាដែលមានធនធានកំណត់។ លទ្ធផលនៃទំហំការងារត្រូវបានស្រង់ដាក់ក្នុងតារាងតូចផ្នែកខាងក្រោម។ ធ្វើបែបនេះយើងឃើញថា រយៈពេលសរុបដើម្បីបញ្ចប់គម្រោងលើសចំនួន៩ថ្ងៃ។ បើសិនជាក្រុមហ៊ុនតូចនេះសម្រេចចិត្តធ្វើការនៅចុងសប្តាហ៍ក៏ដោយក៏មិនអាចទៅរួចដែរ។ ទោះជាយ៉ាងណាក៏ដោយ គម្រោងពេលវេលានេះមានភាពរលូនចំពោះការប្រើប្រាស់កម្លាំងពលកម្ម។

### *គ. គម្រោងមានពេលកំណត់*

គម្រោងពេលវេលាមានធនធានកំណត់ថ្មី ទោះជាមានលក្ខណៈល្អសម្រាប់អ្នកទទួលការងារធ្វើក៏ដោយ ប៉ុន្តែក៏ជាការមិនអាចទទួលយកបានរបស់អតិថិជន។ ម្ចាស់យានដ្ឋានមានការរំពឹងទុកថា រថយន្តដែលមានតម្លៃ ថ្លៃនឹងមកដល់តាមការកំណត់ ហើយចង់បានយានដ្ឋានដែលមានសុវត្ថិភាព។ បើសិនជាយានដ្ឋានថ្មីមិនអាចសង់ហើយតាមការកំណត់ទេ គេអាចប្រមើលមើលអ្នកទទួលការងារធ្វើផ្សេងទៀត។ ក្នុងស្ថានការណ៍នេះមានករណីមួយចំនួនដែលក្រុមហ៊ុនតូចដែលមានតែឪពុក និងកូនត្រូវពិចារណា៖

- បំពេញការងារដោយយោងតាមធនធានកំណត់ ហើយប្រើពេល៣៣ ថ្ងៃ (រូបភាពទី៧.២) និងធ្វើការសន្យាមិនពិតទៅអតិថិជនថានឹងសង់ហើយក្នុងរយៈពេល ២៤ ថ្ងៃ។ ទង្វើបែបនេះមិនគួរនឹងធ្វើទេ ដោយមូលហេតុអាជីវកម្មក៏ដូចជាផ្លូវចិត្ត។
- ប្រាប់ទៅអតិថិជនថា គម្រោងមិនអាចបញ្ចប់ក្នុងកំឡុងពេល២៤ថ្ងៃ ហើយមិនហ៊ានទទួលការងារនេះទេ។
- រៀបចំគម្រោងពេលវេលាដោយគ្រាន់តែផ្តុំធនធាន(រូបភាពទី៧.១) ឡើងវិញ ហើយបន្ថែមកម្លាំងពលកម្មថ្មីដោយមិនគិតពីបន្ទុកចំណាយក្នុងគោលបំណងបញ្ចប់ការងារក្នុងរយៈពេល ២៤ថ្ងៃ។
- រៀបចំផែនការគម្រោងក្នុងកំឡុងពេល២៤ថ្ងៃ ក្នុងករណីលើកលែងខ្លះ ត្រូវបន្ថែមចំនួនកម្លាំងពលកម្ម ប៉ុន្តែត្រូវត្រួតពិនិត្យ និងសម្រួលគម្រោងពេលវេលា យ៉ាងណាដើម្បីឱ្យការងារមានលំហូរល្អ និងបន្ទុកចំណាយមានប្រសិទ្ធភាពខ្ពស់។

ចំណុចចុងក្រោយត្រូវបានគេជ្រើសរើសជាញឹកញាប់ ក្នុងការរៀបចំគម្រោងពេលវេលា។ គួររំលឹកឡើងវិញថា ការរៀបចំគម្រោងពេលវេលាឡើងវិញនៃសកម្មភាពទាំងឡាយអាចធ្វើទៅបានក្នុង

ដែនកំណត់នៃភាព សមស្របបានសេចក្តីថាសកម្មភាពមួយអាចចាប់ផ្តើមបាន លុះត្រាតែសកម្មភាពអាទិភាពត្រូវបានបញ្ចប់សិន។

**តារាងទី៧.៣-៖ គម្រោងយានដ្ឋាន-ពេលកំណត់**




រូបភាពទី៧.៣-ជាតារាងហ្គិនដែលបានរៀបចំឡើងវិញ។ ធនធានដែលត្រូវការប្រចាំថ្ងៃបានដាក់នៅក្នុងតួចខាងក្រោមហើយបង្ហាញនូវការពិតថា គេអាចរៀបចំគម្រោងពេលវេលាមួយនិងមានការប្រើប្រាស់ធនធាន ប្រកបដោយភាពរលូន ដោយមានតម្រូវការតែកម្លាំងពលកម្មបន្ថែម១នាក់ទៀតគ្រប់កម្រិត។

## ៣. គោលការណ៍អាទិភាពមូលដ្ឋានសម្រាប់រៀបចំផែនការធនធាន

គោលការណ៍អាទិភាពជាមូលដ្ឋានរវាងធនធានកំណត់ឬរយៈពេលកំណត់សម្រាប់ការរៀបចំផែនការធនធាន។ ជម្រើសរវាងគោលការណ៍ទាំងពីរនេះត្រូវតែមានចាំបាច់ ទោះជាមានការមិនស៊ីគ្នារវាងរយៈពេលសម្រាប់បញ្ចប់គម្រោងនិងការទទួលបាននូវធនធានចាំបាច់ក៏ដោយ។

### ៣.១. គម្រោងពេលវេលាមានធនធានកំណត់

គម្រោងពេលវេលាមានធនធានកំណត់តម្រូវឱ្យអ្នកធ្វើផែនការ ប្រកាន់យកគោលការណ៍អាទិភាពដែលថាធនធានមានកំណត់។ ក្នុងន័យនេះអាទិភាពដំបូងបង្អស់គឺធនធានដែលគេត្រូវយកមកពិចារណាដើម្បីនឹងបញ្ចប់គម្រោង ហើយអាទិភាពបន្ទាប់មកគឺរយៈពេលខ្លីបំផុតដែលអាចបញ្ចប់គម្រោង។

### ៣.២. គម្រោងពេលវេលាមានពេលកំណត់

បើរយៈពេលសម្រាប់បញ្ចប់ជាកត្តាចម្បង ការប្រើប្រាស់ធនធានលើសត្រូវទទួលយក។ គេអាចធ្វើតាមរយៈអ្នកទទួលការងារធ្វើបន្តឬកម្មករ បុគ្គលិកអណ្តែត។ ទោះជាធនធានទូទៅមានលក្ខណៈ

កំណត់ក៏ដោយ ក្នុងករណីនេះត្រូវចាត់ទុកថាជាអាទិភាពបន្ទាប់ហើយអ្នករៀបចំផែនការត្រូវធ្វើយ៉ាងណាឱ្យការប្រើប្រាស់កម្លាំងពលកម្មមានភាពរលូន ពោលគឺតម្រូវការច្រើនពេក ឬមិនមានតម្រូវការសោះ។

## ៣.៣. វិធីសាស្ត្រដើម្បីសម្រួលការដាក់ដែនកំណត់លើធនធាន និងពេល

បើសិនជាក្នុងពេលជាមួយគ្នាតម្រូវឱ្យមានការកំណត់ធនធានផង និងពេលវេលាផងនោះ គម្រោងពេលវេលាត្រូវតែកើតឡើងដែលជាលទ្ធផលនៃការសម្របសម្រួល។

**ក. ប្រើប្រាស់ធនធានកម្រិតទី២ ដើម្បីពង្រីកដែនកំណត់ធនធាន៖** ពេលខ្លះគេអាចមានលទ្ធភាពពិចារណាពីធនធានកម្រិតទី២ (ឧ.ហ. បុគ្គលិកអណ្តែត) ឬធនធានបម្រុងមិនផ្ទាល់នៃផ្នែកណាមួយ។ ការប្រើប្រាស់នេះត្រូវបានអនុគ្រោះនៅពេលដែលធនធានធម្មតាត្រូវបានកំណត់ទៅនឹងសកម្មភាពអស់ និងរយៈពេលរបស់គម្រោងដែលមិនអាចពន្យារបាន។

**ខ. កំណត់យ៉ាងជាក់លាក់លើធនធានដែលមានស្រាប់៖** ពេលខ្លះការចាប់ផ្តើមរបស់សកម្មភាពមួយត្រូវបានពន្យារពេល ដោយធនធានពិសេសដែលគម្រោងត្រូវមិនទំនេរទោះជានៅក្នុងស្ថាប័នមានធនធានផ្សេងទៀតអាចជំនួសបាន។ ក្នុងករណីនេះគេមិនអាចងាយនឹងជំនួសទាំងស្រុងដោយមនុស្សផ្សេងទៀតទេ ប៉ុន្តែចំណែកខ្លះដែលសមស្របនឹងតម្រូវការរបស់គម្រោង។

**គ. ពន្យារពេលគម្រោង៖** ករណីនេះអ្នកគ្រប់គ្រងគម្រោងត្រូវប្រើសមត្ថភាពចរចារជាមួយនឹងស្ថាប័នពាក់ពន្ធ័ដើម្បីសម្រួលការងារ។

# មេរៀនទី៨ ការរៀបចំផែនការសម្រាប់ការតាមដាននិងវាយតម្លៃ

ក្នុងដំណើរការអនុវត្តគម្រោង ចាំបាច់ត្រូវតែមានការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីធានាថាគម្រោងបានកំពុងនឹងរីកចម្រើនទៅតាមផែនការដែលបានគ្រោងទុក ជាពិសេសអាចយល់បានអំពីបញ្ហាប្រឈមដែលកំពុងកើតមានឡើង និងត្រូវរកដំណោះស្រាយប្រកបដោយប្រសិទ្ធភាពទាន់ពេលវេលា។

## ១. តើអ្វីទៅជាការតាមដាន និងវាយតម្លៃ?

**ការតាមដាន** គឺជាគម្រោងមួយបន្ថែមទៀតលើគម្រោងកំពុងដំណើរការដើម្បីកំណត់ចំណុចខ្លាំង និងចំណុចខ្សោយរបស់គម្រោងក្នុងគោលបំណងធ្វើការ សម្រេចចិត្តធ្វើឱ្យប្រសើរឡើង តែពុំមានផ្តល់អនុសាសន៍ទេ។

*ក. ការងារតាមដានរួមមាន៖*

- ជ្រើសរើសកត្តាចង្អុលបង្ហាញ ឬសូចនាករ
- ប្រមូលទិន្នន័យនៃកត្តាចង្អុលបង្ហាញដែលបានកំណត់
- វិភាគទិន្នន័យ
- ចែកចាយព័ត៌មានជាមួយនឹងភាគីដែលពាក់ព័ន្ធ
- ធ្វើការសម្រេចចិត្តដើម្បីកែលំអការងារ
- ឬជាមធ្យោបាយប្រមូលព័ត៌មានអំពីអ្វីដែលកើតឡើងក្នុងពេលបច្ចុប្បន្ន ឬពេលកន្លងមក។

**ការវាយតម្លៃ** គឺជាត្រួតពិនិត្យត្រឡប់ថយក្រោយនៃដំណើរអនុវត្តគម្រោងដោយមានមានគោលដៅក្នុងការផ្តល់អនុសាសន៍សម្រាប់ តម្រង់ទិសបន្ថែមសកម្មភាពដែលមិនទាន់ទទួលបានលទ្ធផលល្អប្រសើរ។

*ខ. តួអង្គដែលចូលរួមក្នុងដំណើរការវាយតម្លៃមានដូចជា៖*

- អ្នកអនុវត្តគម្រោង
- អ្នកក្រៅអញ្ជើញដោយអ្នកអនុវត្តគម្រោង
- អ្នកក្រៅអញ្ជើញដោយម្ចាស់ថវិកា
- អ្នកវាយតម្លៃឯករាជ្យ។

**ការតាមដានបន្ត** គឺជាសកម្មភាពឬមធ្យោបាយប្រើសម្រាប់តាមដានលទ្ធផលរបស់ គម្រោងមួយដែលបានអនុវត្តចប់សព្វគ្រប់អស់ហើយ ដើម្បីបង្កើនប្រសិទ្ធ ភាពការងារណាមួយដែលបានកំណត់ឱ្យអនុវត្ត។ ឧទាហរណ៍ ការពិនិត្យតាមដានតាមរយៈទូរសព្ទ ឬការចុះពិនិត្យជាក់ស្តែង។

ក្នុងការតាមដាន និងវាយតម្លៃអ្នកគ្រប់គ្រង និងបុគ្គលិកគម្រោង ត្រូវដឹងអំពី៖

- កម្មវត្ថុនៃតាមដាន និងវាយតម្លៃ
- ឧបករណ៍ដែលត្រូវប្រើប្រាស់ក្នុងការតាមដាន
- ពេលវេលានៃការតាមដាន និងវាយតម្លៃ
- សមាសភាពនៃអ្នកធ្វើការតាមដាន និងវាយតម្លៃ
- ទីកន្លែងនៃការតាមដាន និងវាយតម្លៃ។

## ២. ពេលនៃការតាមដាន និងវាយតម្លៃ

ក្នុងដំណើរការគម្រោងត្រូវមានរៀបចំផែនការពេលវេលាក្នុងការតាមដាន និងវាយតម្លៃជាក់លាក់។ ជាទូទៅ ការតាមដានត្រូវតែធ្វើជារៀងរហូត តាំងពីពេលចាប់ផ្តើម រហូតដល់បញ្ចប់វដ្តរបស់គម្រោង។

ដោយឡែកការវាយតម្លៃ គេអាចបែងចែកជា ៤ ដំណាក់កាល៖

- **ការវាយតម្លៃគម្រោងដំបូង** (Pre-evaluation) ជាការជ្រើសរើសគំរូគម្រោងមួយដើម្បីកំណត់ការសន្យានៃគោលទាំងឡាយរបស់គម្រោងនិងយុទ្ធសាស្រ្តជាទូទៅរបស់ស្ថាប័ន។
- **ការវាយតម្លៃគម្រោងជាបណ្តើរៗ** (On-going evaluation) ដើម្បីវាស់នូវភាពរីកចម្រើនរបស់គម្រោង និងផ្តល់ជាអនុសាសន៍ សម្រាប់តម្រង់ទិស។
- **ការវាយតម្លៃនាពេលចុងបញ្ចប់របស់គម្រោង** (End-evaluation) ជាការសិក្សាជាបន្ទាន់ទៅលើជោគជ័យក្នុងកំឡុងពេលបញ្ចប់គម្រោងផ្តោតលើលទ្ធផលដែលអាចមើលឃើញភ្លាម។
- **ការវាយតម្លៃក្រោយពេលបញ្ចប់គម្រោង** (Post-evaluation) ជាការវាយតម្លៃទៅលើផលវិបាកទាំងឡាយដែលអាចកើតមានក្រោយពេលបញ្ចប់គម្រោងផ្តោតលើលទ្ធផលពិតប្រាកដដែលយើងចង់បាន។

## ៣. ការសិក្សា និងរៀបចំគម្រោងផែនការតាមដាន និងវាយតម្លៃ

## ៣.១. ការសិក្សាអំពីតារាងតក្កភាព

មុននឹងរៀបចំគម្រោងផែនការតាមដាន និងវាយតម្លៃ ជាការចាំបាច់ណាស់គេត្រូវសិក្សាចំណុចខាងក្រោមនេះ នៅក្នុងតារាងតក្កភាព៖

- គោលបំណង៖ មូលហេតុដែលនាំឱ្យមានគម្រោង និងជាសេចក្ដីប្រាថ្នានាពេលអនាគត ក្នុងន័យទូលាយ ជាទូទៅគេមិនអាចបំពេញបានទាំងស្រុងទេ។
- គោលដៅទូទៅ៖ ជាអ្វីដែលត្រូវធ្វើក្នុងរយៈពេលកំណត់មួយ ជាលក្ខណៈទូទៅ និងមានភាពជាក់លាក់តិចតួច។
- គោលដៅជាក់លាក់៖ នេះជាអ្វីដែលត្រូវធ្វើក្នុងរយៈពេលកំណត់មួយ ជាលក្ខណៈជាក់លាក់បំផុត និងដោយវិធីសាស្ត្រណាមួយ។
- សកម្មភាព៖ ជាអ្វីដែលត្រូវធ្វើ។
- សូចនាករ៖ នេះជាអ្វីដែលត្រូវបង្ហាញពីភាពរីកចម្រើន។

***កត្តាសំខាន់ក្នុងការងារតាមដាន និងវាយតម្លៃ គឺត្រូវជ្រើសរើសសូចនាករ។ តើអ្វីទៅជាសូចនាករ?***

ក្នុងបរិបទនៃការងារតាមដាននិងវាយតម្លៃ សូចនាករគឺជាលក្ខណៈវិនិច្ឆ័យ ប្រើប្រាស់សម្រាប់តាមដាននិងវាយតម្លៃ គោលបំណង និងគោលដៅ របស់គម្រោង ឬគេអាចនិយាយបានថាជាសញ្ញានៃការផ្លាស់ប្ដូរ ធ្វើឱ្យនរណាម្នាក់អាចដឹងពីការរីកចម្រើនគោលដៅ។ សូចនាករដែលល្អ ចាំបាច់ត្រូវតែមានលក្ខណៈ SMART៖

- Specific: ជាក់លាក់
- Measurable: អាចវាស់វែងបាន
- Attainable: អាចរកបាន
- Reliable: អាចជឿជាក់បាន
- Time-bound: ពាក់ព័ន្ធនឹងពេលវេលា

## ៣.២. ជំហាននៃការតាមដាន និងវាយតម្លៃ

ការវាយតម្លៃ តម្រូវឱ្យមានការរៀបចំផែនការមួយច្បាស់លាស់ និងមានជំហានមួយចំនួនដូចខាងក្រោម៖

- ស្វែងយល់ពីផែនការ និងបំណងរបស់គម្រោង
- ស្វែងយល់ពីគោលដៅ និងសកម្មភាព

- ត្រួតពិនិត្យធនធានដូចជា ធនធានមនុស្ស ជំនាញ និង ថវិកា មិនមែនរបស់ក្រុមអ្នកវាយតម្លៃទេ តែជារបស់គម្រោង
- ជ្រើសរើសសូចនាករ និងឧបករណ៍នានាសម្រាប់វាស់
- រៀបចំផែនការសម្រាប់វាស់ ដូចជាចាត់ចែងការសំភាសន៍ ការអង្កេត ការសង្កេតជាដើម។

## ៤. ការប្រមូលទិន្នន័យ

ទិន្នន័យជាឧបករណ៍ចាំបាច់ប្រើសម្រាប់វាស់វែងសូចនាករនៅក្នុងការតាមដាន និងវាយតម្លៃគម្រោងមានភាពត្រឹមត្រូវ។ ទិន្នន័យទាំងនោះអាចជាទិន្នន័យដែលមានស្រាប់ ឬអាចជាទិន្នន័យបឋម។

***ក. ឯកសារដែលមានទិន្នន័យស្រាប់មានដូចជា៖***

- ឯកសារបានមកពីអ្នកអនុវត្តគម្រោង
- ឯកសារគម្រោង ឬតារាងតក្កភាព
- របាយការណ៍ពីមុនៗមក
- កំណត់ហេតុអង្គប្រជុំ
- វិក័យបត្រ
- របាយការណ៍សវនកម្ម។

***ខ. ទិន្នន័យបឋម៖***

- បានមកពីការសម្ភាសន៍
- ការសង្កេត
- ការសាកល្បង
- ការអង្កេត
- ការកត់ត្រាជាឯកសារ

## ៥. របាយការណ៍

របាយការណ៍យ៉ាងហោចណាស់ត្រូវមានទម្រង់ដូចតទៅ៖

- សេចក្តីផ្តើម
- វិធីសាស្ត្រស្រាវជ្រាវ ដោយមានការបញ្ជាក់ច្បាស់ពីដែនកំណត់
- តួសេចក្តី គេអាចបែងចែកតាមវិស័យ ឬផ្នែករបស់គម្រោង
- សេចក្តីសន្និដ្ឋាន ជាការបង្ហាញនូវទស្សនៈផ្ទាល់របស់យើងទៅលើកិច្ចការកំពុងវាយតម្លៃ

- អនុសាសន៍ ជាផ្នែកសំខាន់បំផុតនៃរបាយការណ៍ ត្រូវសរសេរសង្ខេបខ្លីច្បាស់ និងត្រូវមានខ្លឹមសារ ដែលគេមិនអាចយកទៅបកស្រាយខុស ហើយអាចអនុវត្តបានដើម្បីកែលំអការងារ។

# មេរៀនទី៩ ការបញ្ចប់គម្រោង

កិច្ចការអ្វីក៏ដោយតែងមានពេលចាប់ផ្តើម ហើយក៏នឹងត្រូវមានពេលបញ្ចប់។ ដូចគ្នាដែរការងារគម្រោងនីមួយៗតែងមានការបញ្ចប់ គ្រាន់តែអាស្រ័យលើដំណើរការគម្រោងសម្រាប់រយៈពេលខ្លី មធ្យម ឬវែង ស្របទៅតាមគោលបំណងរបស់ម្ចាស់គម្រោង។ ហើយការបញ្ចប់គម្រោងមួយត្រូវមានដំណើរការ ឬនីតិវិធីផ្សេងៗដើម្បីបញ្ជាក់អំពីលទ្ធផលចុងក្រោយជាចាំបាច់ទៅតាមប្រភេទគម្រោង។ ជារួមដំណើរបញ្ចប់គម្រោងមិនងាយស្រួលទេ ជានិច្ចកាលមានភាពស្មុគស្មាញ ដែលយើងចង់ចៀសវាងឱ្យបានច្រើនបំផុត។

## ១. ប្រភេទផ្សេងៗនៃការបញ្ចប់គម្រោង

ការបែងចែងការបញ្ចប់គម្រោងជាប្រភេទផ្សេងៗ គឺអាស្រ័យទៅតាមស្ថានភាពដំណើរការចុងក្រោយរបស់គម្រោង។

### ១.១. ការបញ្ចប់គម្រោងដោយដំណើរអស់ទៅ

ការបញ្ចប់ដោយដំណើរអស់ទៅបានន័យថា៖

- គម្រោងមួយសម្រេចបានជោគជ័យ និងទៅដល់គោលបំណង
- គម្រោងត្រូវបានបញ្ឈប់ ព្រោះមិនបានទទួលជោគជ័យសោះ
- ក្នុងករណីពិសេសខ្លះទៀត គម្រោងត្រូវបានបញ្ចប់ដោយសារខ្វះលទ្ធភាពដើម្បីបញ្ចប់ ។

កាលណាមានការសម្រេចថាបញ្ចប់គម្រោងដោយដំណើរអស់ទៅ ព្រឹត្តិការណ៍ដែលអាចកត់ត្រាបានជាភស្តុតាងនៃការផ្អាកគម្រោង។ សកម្មភាពចាត់ចែងមួយចំនួនធំទៀតដែលត្រូវបំពេញ ដូចជាការចាត់ចែងការផ្ទេរ បុគ្គលិក។ រីឯសម្ភារៈ បរិក្ខា និងកម្មសិទ្ធិផ្សេងទៀតរបស់គម្រោង ត្រូវចាត់ចែងផ្ទេរទៅតាមកិច្ចសន្យារបស់គម្រោង ឬអាស្រ័យនឹងនីតិវិធីនៃការបង្កើតរបស់ស្ថាប័នអាណាព្យាបាល។ ចុងក្រោយបង្អស់ត្រូវសរសេររបាយការណ៍បញ្ចប់មួយរបស់គម្រោង។

### ១.២. ការបញ្ចប់ដោយបន្ថែម

គម្រោងមួយបញ្ចប់ដោយបន្ថែម តំណាក់កាលតភ្ជាប់ខុសពីការបញ្ចប់ដោយដំណើរអស់ទៅ ប៉ុន្តែមានការបញ្ឈប់គម្រោងប្រហាក់ប្រហែលគ្នា។ បុគ្គលិកគម្រោង កម្មសិទ្ធិផ្សេងៗ ជាញឹកញាប់ត្រូវបានបញ្ជូនពី គម្រោងដែលបញ្ចប់ទៅផ្នែកដែលទើបនឹងកើត។ ការបម្លែងរូបពីគម្រោងទៅផ្នែក ឬទៅជាសាខាត្រូវបានគាំទ្រដោយថវិកា និងការអនុវត្តន៍ផ្នែករដ្ឋបាលអនុលោមទៅនឹងបទដ្ឋាននីតិវិធីនៅក្នុងស្ថាប័នអាណាព្យាបាល។

### ១.៣. ការបញ្ចប់ដោយសមាហរណកម្ម

ការបញ្ចប់គម្រោងដោយសមាហរណកម្ម គឺជាវិធីសាស្ត្របង្រួមបញ្ចូលគ្នាពីគម្រោងច្រើនដើម្បីកាត់បន្ថយគម្រោងនៅចំនួនតិចឬនៅត្រឹមតែមួយគម្រោង។ ការបញ្ចប់គម្រោងបែបនេះ កម្មសិទ្ធិ បរិក្ខាសម្ភារៈ បុគ្គលិក និងតួនាទី របស់គម្រោងត្រូវបានបែងចែកទៅតាមផ្នែករបស់ស្ថាប័នអាណាព្យាបាល។ លទ្ធផលរបស់គម្រោងបានក្លាយជាផ្នែកស្តង់ដារមួយរបស់ស្ថាប័នអាណាព្យាបាលឬអតិថិជន។

### ១.៤. ការបញ្ចប់ដោយផ្តាច់ការផ្គត់ផ្គង់

កាត់ផ្តាច់ការផ្គត់ផ្គង់ មានមូលហេតុច្រើនយ៉ាងដែលតម្រូវឱ្យអ្នកគ្រប់គ្រងជាន់ខ្ពស់មិនចង់បញ្ចប់គម្រោងមួយដែលមិនទទួលជោគជ័យឬមិនទាន់សម័យ។ ក្នុងករណីនេះ គេត្រូវកាត់បន្ថយថវិកាឱ្យច្រើនឬបន្តិចម្តងៗជាញឹកញាប់ ដើម្បីកុំឱ្យគម្រោងមានការជឿនលឿនទៅមុខ និងជំរុញឱ្យបុគ្គលិកលាលែងពីការងារគម្រោង។ តាមការពិត គម្រោងត្រូវបានបញ្ចប់ ប៉ុន្តែតាមផ្លូវច្បាប់មិនទាន់បញ្ចប់ទេ ដែលនៅក្នុងគម្រោងនោះមានលេខាដែលនៅធ្វើរបាយការណ៍ថាគម្រោងពុំមានការរីកចម្រើនទៅមុខទេ។

## ២. ដំណើរការបញ្ចប់គម្រោង

នៅពេលមានការសម្រេចចិត្តថាបញ្ចប់គម្រោង ដំណើរការបញ្ចប់ត្រូវតែអនុវត្តន៍។ គេអាចបញ្ចប់គម្រោងដោយធ្វើផែនការជាមុននិងមានរបៀបរៀបរយឬជាការងារស្រុះស្រួលគ្នាយ៉ាងងាយបំផុត។ ការធ្វើផែនការជាឱកាសផ្តល់ឱ្យមានលទ្ធផលល្អ ដូច្នេះយើងគួរតែធ្វើផែនការរៀបចំថវិកា និងគម្រោងពេលវេលាដូចជាសម្រាប់គម្រោងទាំងមូលដែរ។ ដំណើរការបញ្ចប់គម្រោងត្រូវធ្វើឡើងដើម្បីៈ

- រៀបចំទុកដាក់ធនធានដែលបានប្រើហើយឱ្យបានសមរម្យ
- ចាត់ចែង សម្ភារៈ ឧបករណ៍របស់របស់គម្រោង។

ក្រៅពីនេះការបញ្ចប់គម្រោងក៏ពាក់ព័ន្ធនឹងកិច្ចការរដ្ឋបាលមួយចំនួនដែលអ្នកគ្រប់គ្រងគម្រោងត្រូវធ្វើដូចជាៈ

- បន្តជានាការបញ្ចប់ការងារ រួមទាំងការងារដែលផ្តល់ទៅឱ្យអ្នកទទួលធ្វើ
- ជូនដំណឹងដល់អតិថិជនពីការបញ្ចប់របស់គម្រោង ជានានូវការផ្តល់លទ្ធផល និងការទទួលស្គាល់គម្រោងត្រូវតែបានដឹងពីអតិថិជន
- ជានាការរៀបចំឯកសារទាំងអស់រួមទាំងរបាយការណ៍វាយតម្លៃចុងក្រោយបង្អស់ និងការរៀបចំរបាយការណ៍ចុងក្រោយរបស់គម្រោង
- ចាត់ចែងការជំពាក់ វិក័យប័ត្របញ្ជូនទៅអតិថិជន

- រៀបចំចាត់ចែងបុគ្គលិក សម្ភារៈ បរិក្ខា និងធនធានផ្សេងទៀតទៅ តាមកន្លែងសមស្រប
- រៀបចំចាត់ចែងគម្រោងទៅតាមផ្លូវច្បាប់ជាមួយអ្នកប្រឹក្សា បើអាចត្រូវ ចេញជាសេចក្តីប្រកាស
- កំណត់អ្វីដែលត្រូវកត់ត្រាហើយត្រូវទុកដាក់ឱ្យបានសមស្រប ហើយធានាថាអាចផ្តល់ដល់អ្នកដំកល់ឯកសាររបស់ស្ថាប័នអាណាព្យាបាល
- ការផ្គត់ផ្គង់ខ្លះអាចមានភាពស្រពិចស្រពិល បែបនេះត្រូវធ្វើការសម្រេចចិត្តថាតើត្រូវចាត់ចែងរបៀបណា ហើយត្រូវកំណត់អ្នកទទួលខុសត្រូវ
- ត្រួតពិនិត្យបញ្ជីគណនេយ្យរបស់គម្រោង។

## ៣. របាយការណ៍បញ្ចប់ - ប្រវត្តិគម្រោង

ចំណុចសំខាន់ចុងក្រោយនោះគឺការផ្តល់នូវរបាយការណ៍បញ្ចប់ដោយបញ្ជាក់អំពីការផ្ទេរ ឬបន្តនិរន្តរភាពរបស់គម្រោងជាដើម។

ប្រព័ន្ធគ្រប់គ្រងគម្រោងល្អត្រូវមានការកត់ត្រាទុកដែលគេហៅថា របាយការណ៍បញ្ចប់គម្រោង។ របាយការណ៍បញ្ចប់នេះមិនមែនជាការវាយតម្លៃមួយផ្សេងទៀតទេ តែជាប្រវត្តិរបស់គម្រោង។

ជាតុផ្សំនៃរបាយកាណ៍នេះមានដូចខាងក្រោមៈ

### ៣.១. ការស្តែងឡើងរបស់គម្រោង

ជាតុផ្សំគន្លឹះនៃរបាយការណ៍គឺការប្រៀបធៀបថាតើអ្វីដែលគម្រោង សម្រេចបាននឹងគោលបំណងរបស់គម្រោង។ ការប្រៀបធៀបនេះត្រូវមាន លក្ខណៈពិស្តារ រួមទាំងការពន្យល់ពីគម្លាតរវាងការស្តែងឡើងបច្ចុប្បន្ន និង ផែនការពីមុនមក។ ដោយរបាយការណ៍មិនមែនជាការវាយតម្លៃផ្លូវការ របាយការណ៍នេះអាចឆ្លុះបញ្ចាំងនូវការសន្និដ្ឋានរបស់អ្នកគ្រប់គ្រងគម្រោងលើជោគជ័យ និងបរាជ័យដែលកើតឡើង។ ចុងបញ្ចប់នៃការប្រៀបធៀបនេះត្រូវមានអនុសាសន៍សម្រាប់គម្រោងក្រោយៗទៀត។

### ៣.២. ការស្តែងឡើងរបស់រដ្ឋបាល

កិច្ចការរដ្ឋបាលរបស់គម្រោងមួយមិនអាចជួយដោះស្រាយបញ្ហាបច្ចេកទេសបានទេ ប៉ុន្តែអាចជំរុញឱ្យមានការអនុវត្តន៍ ឬការការពារបច្ចេកវិជ្ជាបាន។ ក្នុងការអនុវត្តន៍ រដ្ឋបាលត្រូវមានការត្រួតពិនិត្យឡើងវិញ ដើម្បីកត់សម្គាល់នូវចំណុចល្អ និងចំណុចដែលគួរកែលំអ។

### ៣.៣. រចនាសម្ព័ន្ធចាត់ចែង

ទម្រង់រចនាសម្ព័ន្ធនីមួយៗដែលបានជ្រើសរើស និងប្រើប្រាស់សម្រាប់គម្រោង តែងមានគុណសម្បត្តិនិងគុណវិបត្តិ។ ក្នុងរបាយការណ៍បញ្ចប់ត្រូវមានការបរិយាយទៅលើទម្រង់នោះ ថាតើបានជួយ

អ្វីខ្លះដល់ការងារគម្រោង។ បើសិនជាមានការកែប្រែហើយផ្តល់ជាប្រយោជន៍ដល់ការងារគម្រោងចាំបាច់ត្រូវមានការពិពណ៌នា។ អនុសាសន៍របស់ផ្នែកនេះ ត្រូវមានការពន្យល់លម្អិត និងមានហេតុផល។

## ៣.៤. ក្រុមការងារគម្រោង និងរដ្ឋបាល

របាយការណ៍ចុងក្រោយរបស់គម្រោងត្រូវមានផ្នែកសម្ងាត់មួយ សម្រាប់អ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកបុគ្គលិក នៃស្ថាប័នអាណាព្យាបាលស្តីពី អនុសាសន៍ ថាតើបុគ្គលិកនីមួយៗអាចប្រគល់ការងារក្នុងគម្រោងក្រោយៗទៀតឬមិនប្រគល់។ ដូចគ្នាដែរអ្នកគ្រប់គ្រងគម្រោងអាចផ្តល់អនុសាសន៍សម្រាប់ជាក្រុមថាតើក្រុមការងារកន្លងមកសម្រាប់ការងារក្រោយៗទៀតគួរទុកជាក្រុមដដែលឬរៀបចំក្រុមជាថ្មីឡើងវិញ។

## ៣.៥. បច្ចេកទេសគ្រប់គ្រងគម្រោង

បំណងជាមូលដ្ឋាននៃរបាយការណ៍ចុងក្រោយនេះគឺសម្រាប់ធ្វើឱ្យប្រសើរឡើងនៃគម្រោងក្រោយៗទៀត។ ទិន្នន័យរបស់គម្រោងនិងលទ្ធផលអាចរកបាននៅក្នុងរបាយការណ៍បណ្តោះអាសន្ន សវនកម្ម និងវាយតម្លៃជាច្រើនដែលបានធ្វើនៅក្នុងវដ្តរបស់គម្រោង។ ដើម្បីរក្សានូវសារៈសំខាន់នេះ អ្នកគ្រប់គ្រងគម្រោងត្រូវមានកំណត់ហេតុប្រចាំថ្ងៃ។ តែជាការកំណត់ហេតុនេះមិនមែនជាឯកសារផ្លូវការរបស់គម្រោងទេ ប្រមូលក្រៅផ្លូវការនូវការគិត ការឆ្លុះបញ្ចាំង និងការបរិយាយទៅលើអ្វីដែលកើតឡើងចំពោះគម្រោងនិងក្នុងគម្រោង។

# ឯកសារយោង

1. បណ្ឌិត ព្រុំ ទេវីះ ការរៀបចំនិងអនុវត្តគម្រោង បោះពុម្ពលើកទី២ ឆ្នាំ២០២៣

# ឧបសម្ព័ន្ធ

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាភូមិន្ទរដ្ឋបាល**

**វិន័យ គុណភាព គុណធម៌ នវានុវត្តន៍**

**សិស្សមន្ត្រីជាន់ខ្ពស់ ជំនាន់ទី១៣**

# កិច្ចការស្រាវជ្រាវគម្រោង

## ស្តីពី

# កម្មវិធីដំណើរទស្សនកិច្ចសិក្សា ក្រោមប្រធានបទ
# “សាមគ្គីភាពរបស់យុវជន ឆ្ពោះទៅរកវឌ្ឍនភាពសង្គម”


**ឧទ្ទេសនាមដោយ ៖ បណ្ឌិត ព្រុំ ទេវី**

**ស្រាវជ្រាវដោយ ៖ សិស្សមន្ត្រីជាន់ខ្ពស់ ជំនាន់ទី១៣**

- លោក ស៊ុន ច័ន្ទរង្សី
- លោក សៅ គីមស៊ុង
- លោក ស្រិន ប៊ុនថេប
- លោក ស្រ៊ុន បូរ័ត្ន
- លោក ស៊ីលី សុវណ្ណនី
- លោក រ៉ុម ប៊ុនធា


**ឆ្នាំសិក្សា ២០២៥ - ២០២៧**

# មាតិកា


**សាវតាររបស់គម្រោង** ........................................ 1

**១- ផែនការគម្រោង** ........................................ 1

1.1- គោលបំណង ........................................ 1

1.2- គោលដៅ ........................................ 1

1.3- សកម្មភាព ........................................ 2

1.4- ប្រភពថវិកា ........................................ 3

1.5- អ្នកទទួលខុសត្រូវ ........................................ 3

1.6- សូចនាករ ........................................ 5

1.7- មធ្យោបាយផ្ទៀងផ្ទាត់ ........................................ 8

1.8- ហានិភ័យ ........................................ 10

**២- ដំណើរការគម្រោង** ........................................ 11

2.1- រចនាសម្ព័ន្ធគ្រប់គ្រង ........................................ 11

2.2- ការរៀបចំអង្គការលេខ ........................................ 12

2.3- ការប្រើប្រាស់ពេលវេលា ........................................ 15

2.4- ការប្រើប្រាស់ធនធានគម្រោង ........................................ 16

2.5- ការតាមដាននិងត្រួតពិនិត្យគម្រោង ........................................ 17

2.5.1- ការតាមដានគម្រោង ........................................ 17

2.5.2- ការវាយតម្លៃគម្រោង ........................................ 17

2.5.3- ការតាមដានបន្ត ........................................ 17

2.6- ការបញ្ចប់គម្រោង ........................................ 17

2.6.1- ការបញ្ចប់គម្រោង ........................................ 17

2.6.2- ការផ្ទេរនិរន្តរភាពនៃគម្រោង ........................................ 18

**៣- ការវិភាគSWOT លើដំណើរការអនុវត្តគម្រោង** .................................................. 18
3.1- ចំណុចខ្លាំង ............................................................................................ 18
3.2- ចំណុចខ្សោយ .......................................................................................... 19
3.3- ឱកាស ................................................................................................... 19
3.4- ការគំរាមកំហែង ...................................................................................... 19
**សេចក្តីសន្និដ្ឋាន** ............................................................................................ 20

# សាវតារបស់គម្រោង

សកម្មភាពទស្សនកិច្ចសិក្សានេះត្រូវបានរៀបចំឡើងក្រោមប្រធានបទ "សាមគ្គីភាពយុវជន ឆ្ពោះទៅរកវឌ្ឍនភាពសង្គម" ដោយផ្អែកលើគោលការណ៍សំខាន់មួយដែលរាជរដ្ឋាភិបាលបានផ្ដោតអាទិភាព គឺការលើកកម្ពស់តួនាទីយុវជនក្នុងការអភិវឌ្ឍសង្គម; សេដ្ឋកិច្ច; និង បរិស្ថាន។ ក្នុងបរិបទនៃការអភិវឌ្ឍប្រទេសជាតិក្នុងយុគសម័យថ្មី យុវជនត្រូវបានចាត់ទុកជាកម្លាំងចម្បងសម្រាប់ការកសាងអនាគតដែលមានស្ថិរភាព ដោយត្រូវមានសមត្ថភាព ការយល់ដឹង និងបទពិសោធន៍គ្រប់គ្រាន់ក្នុងការចូលរួមដឹកនាំ និងដោះស្រាយបញ្ហាសង្គម។

ដើម្បីឆ្លើយតបនឹងតម្រូវការនេះ សកម្មភាពសិក្សានេះត្រូវបានរៀបចំឡើងដើម្បីបង្កើតឱកាសសិក្សា និងអន្តរកម្មជាក់ស្តែង សម្រាប់ពង្រឹងស្មារតីសាមគ្គីភាព ការទទួលខុសត្រូវ និងការចូលរួមក្នុងសហគមន៍របស់យុវជនតាមរយៈសកម្មភាពអប់រំ; សង្គម; បរិស្ថាន; និង វប្បធម៌។ ក្នុងក្របខណ្ឌនេះ សកម្មភាពសំខាន់ៗត្រូវបានកំណត់រួមមាន៖ ការចុះចែករំលែកបទពិសោធន៍ និងការណែនាំអំពីជំនាញអាជីពសម្រាប់សិស្សានុសិស្សវិទ្យាល័យកំពង់ថ្មដើម្បីលើកកម្ពស់ការរៀបចំអនាគតរបស់យុវជនឱ្យសមស្របនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម; ការចុះដាំកូនឈើចំនួន ២០០ ដើម នៅបរិវេណខាងមុខប្រាសាទអង្គរវត្ត ដើម្បីលើកកម្ពស់ការយល់ដឹងអំពីតម្លៃបរិស្ថានព្រមទាំងការចុះចែកអំណោយជូនសិស្សានុសិស្សវិទ្យាល័យអប់រំពិសេសសៀមរាប ដើម្បីលើកទឹកចិត្តដល់កុមារមានពិការភាព; និង សកម្មភាពជិះកង់ជុំវិញតំបន់វង់តូច ដើម្បីបង្កើនសាមគ្គីភាព; មិត្តភាព; ការយល់ដឹងអំពីបរិស្ថានគ្មានផ្សែងបំពុល; និង ជំរុញការយល់ដឹងអំពីអរិយធម៌, វប្បធម៌, ព្រមទាំង ប្រវត្តិសាស្ត្រខ្មែរ។

## ១- ផែនការគម្រោង

### ១.១- គោលបំណង

ដើម្បីលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងការការពារបរិស្ថាន និងអភិវឌ្ឍន៍សង្គមស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

### ១.២- គោលដៅ

**គោលដៅទី១៖** បង្កើតក្រុមការងារ សិក្សាពីតម្រូវការសម្ភារនិងរៀបចំផែនការកម្មវិធីដំណើរទស្សនកិច្ច ចាប់ពីសប្តាហ៍ទី១ ខែធ្នូ ឆ្នាំ២០២៥ ដល់ សប្តាហ៍ទី៣ ខែមេសា ឆ្នាំ២០២៥។

**គោលដៅទី២៖** ធ្វើដំណើរទៅកាន់ទីតាំងដែលបានកំណត់ និងរៀបចំកម្មវិធី នៅសប្តាហ៍ទី៣ ខែឧសភា ឆ្នាំ២០២៥។

**គោលដៅទី៣៖** សសេររបាយការណ៍; ការចំណាយ; និង លទ្ធផលនានានៃគម្រោង ដើម្បីដាក់ជូនទៅអ្នកពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៦។

### ១.៣- សកម្មភាព

ដើម្បីគាំទ្រដល់ការសម្រេចបាននូវគោលដៅនៃគម្រោងនេះ យើងអាចដាក់ចេញនូវសកម្មភាពមួយចំនួនដូចខាងក្រោម៖

**គោលដៅទី១៖** បង្កើតក្រុមការងារ សិក្សាពីតម្រូវការសម្ភារនិងរៀបចំផែនការកម្មវិធីដំណើរទស្សនកិច្ចចាប់ពីសប្តាហ៍ទី១ ខែធ្នូ ឆ្នាំ២០២៥ ដល់ សប្តាហ៍ទី៣ ខែមេសា ឆ្នាំ២០២៥។

**សកម្មភាព១.1៖** បង្កើតក្រុមការងារដែលមានសមាជិក ៦ នាក់ ដើម្បីគ្រប់គ្រង និងអនុវត្តគម្រោងនៅត្រឹមសប្តាហ៍ទី១ ខែធ្នូ ឆ្នាំ២០២៥

**សកម្មភាព១.២៖** ក្រុមការងារចុះធ្វើការសិក្សា និងកំណត់ពីតម្រូវការសម្ភារសម្រាប់កម្មវិធីដំណើរទស្សនកិច្ចសិក្សា នៅត្រឹមសប្តាហ៍ទី៤ ខែធ្នូ ឆ្នាំ២០២៥។

**សកម្មភាព១.៣៖** ក្រុមការងាររៀបចំ និងត្រៀមសម្ភារសម្រាប់ដំណើរការកម្មវិធីទស្សនកិច្ច នៅត្រឹមសប្តាហ៍ទី៤ ខែមេសា ឆ្នាំ ២០២៦។

**គោលដៅទី២៖** ធ្វើដំណើរទៅកាន់ទីតាំងដែលបានកំណត់ និងរៀបចំកម្មវិធី នៅសប្តាហ៍ទី៣ ខែឧសភា ឆ្នាំ២០២៥។

**សកម្មភាព២.1៖** យុវជនចុះចែករំលែកបទពិសោធន៍ដល់សិក្សានុសិស្សនៅថ្នាក់វិទ្យាល័យ អំពីការជ្រើសរើសជំនាញនៅថ្នាក់ឧត្តមសិក្សា នៅរសៀលថ្ងៃទីមួយ នៃកម្មវិធី នៅវិទ្យាល័យកំពង់ថ្ម ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍សមត្ថភាពរបស់យុវជនផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច។

**សកម្មភាព២.២៖** យុវជនចុះដាំកូនឈើចំនួន២០០ដើម នៅបរិវេណខាងមុខប្រាសាទអង្គរវត្ត នៅព្រឹកថ្ងៃទីពីរ នៃកម្មវិធី ដើម្បីលើកកម្ពស់អំពីសារប្រយោជន៍នៃបរិស្ថាន និងចុះចែកអំណោយជូនវិទ្យាល័យអប់រំពិសេសសៀមរាប នៅរសៀលថ្ងៃទីពីរ នៃកម្មវិធី ដើម្បីលើកទឹកចិត្តដល់សិស្សានុសិស្សដែលមានពិការភាពចូលរួមក្នុងការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច។

**សកម្មភាព២.៣៖** យុវជនជិះកង់ នៅព្រឹកថ្ងៃទីបី នៃកម្មវិធី ចាប់ផ្តើមចេញពីចំណុចខាងមុខប្រាសាទអង្គរវត្ត រួចបន្តដំណើរជុំវិញ វង់តូច និងបញ្ចប់ត្រង់ចំណុចខាងមុខនៃប្រាសាទអង្គរវត្ត ដើម្បីសាមគ្គីភាព; មិត្តភាព; បរិស្ថានគ្មានផ្សែងបំពុល; និង បញ្ជ្រាបការយល់ដឹងអំពីអរិយធម៌; វប្បធម៌; និង ប្រវត្តិសាស្ត្រខ្មែរ។

**គោលដៅទី៣៖** សសេរបាយការណ៍; ការចំណាយ; និង លទ្ធផលនានានៃគម្រោង ដើម្បីដាក់ជូនទៅអ្នកពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៦។

**សកម្មភាព៣.1៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោងទាំងមូល នៅត្រឹមសប្តាហ៍ទី៤ ខែឧសភា ឆ្នាំ២០២៦។

**សកម្មភាព៣.២៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគម្រោង នៅត្រឹមសប្តាហ៍ទី៤ ខែឧសភា ឆ្នាំ២០២៦។

**សកម្មភាព៣.៣៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបចំណាយ និងលទ្ធផលនៃគម្រោងជូនទៅអ្នកដែលពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី១ ខែមិថុនា ២០២៦។

### ១.៤- ប្រភពថវិកា

គម្រោងខាងលើនេះ ទទួលបានថវិកាមកពីប្រភពចំនួន ៣ ដូចខាងក្រោម៖

**ប្រភពថវិកាទី ១៖** កញ្ចប់ថវិកាចូលរួមវិភាគទាន ពីសំណាក់អ្នកចូលរួមកម្មវិធីចំនួន៥០នាក់ ដោយម្នាក់ត្រូវចំណាយ ៦០ ដុល្លារអាមេរិក សរុបចំនួន ៣០០០ ដុល្លារអាមេរិក សម្រាប់ប្រើប្រាស់ក្នុងចំណាយទូទៅ និងចំណាយលើសកម្មភាពដំណើរទស្សនកិច្ច ក្នុងគោលដៅទី១ និងទី២។

**ប្រភពថវិកាទី ២៖** កញ្ចប់ថវិកាឧបត្ថម្ភពីក្រុមហ៊ុន ដែលចាប់អារម្មណ៍ជាមួយគម្រោងនេះ ចំនួន ៣៥០០ ដុល្លារអាមេរិក សម្រាប់ប្រើប្រាស់ជាប្រាក់ចំណាយលើសកម្មភាពដំណើរទស្សនកិច្ច ក្នុងគោលដៅទី២។

**ប្រភពថវិកាទី ៣៖** កញ្ចប់ថវិកាឧបត្ថម្ភ ពីសំណាក់សប្បុរសជន ដែលចាប់អារម្មណ៍ជាមួយគម្រោងនេះ ចំនួន ១០០០ ដុល្លារអាមេរិក សម្រាប់ប្រើប្រាស់ក្នុងចំណាយទូទៅ និងចំណាយលើសកម្មភាពដំណើរទស្សនកិច្ច ក្នុងគោលដៅទី១ និងទី២។

### ១.៥- អ្នកទទួលខុសត្រូវ

កម្មវិធីដំណើរទស្សនកិច្ចសិក្សា រយៈពេល ៣យប់ និង៤ថ្ងៃនេះ មានលោក ស៊ិន ច័ន្ទរង្សី ជាអ្នកទទួលខុសត្រូវរួម និងមានក្រុមការងារជួយសម្របសម្រួលព្រមទាំងទទួលខុសត្រូវតាមសកម្មភាពនីមួយៗ។ សមាសភាពអ្នកទទួលខុសត្រូវគម្រោងនេះមានដូចខាងក្រោម៖

**គោលដៅទី១៖** បង្កើតក្រុមការងារ សិក្សាពីតម្រូវការសម្ភារនិងរៀបចំផែនការកម្មវិធីដំណើរទស្សនកិច្ចចាប់ពីសប្តាហ៍ទី១ ខែធ្នូ ឆ្នាំ២០២៥ ដល់ សប្តាហ៍ទី៣ ខែមេសា ឆ្នាំ២០២៥។

**សកម្មភាព១.1៖** បង្កើតក្រុមការងារដែលមានសមាជិក ៦ នាក់ ដើម្បីគ្រប់គ្រង និងអនុវត្តគម្រោង នៅត្រឹមសប្តាហ៍ទី១ ខែធ្នូឆ្នាំ២០២៥ **ដឹកនាំនិងទទួលខុសត្រូវដោយ លោក ស៊ិន ច័ន្ទរង្សី។**

**សកម្មភាព១.២៖** ក្រុមការងារចុះធ្វើការសិក្សា និងកំណត់ពីតម្រូវការសម្ភារសម្រាប់កម្មវិធីដំណើរទស្សនកិច្ចសិក្សា នៅត្រឹមសប្តាហ៍ទី៤ ខែធ្នូ ឆ្នាំ២០២៥ **ដឹកនាំនិងទទួលខុសត្រូវដោយ លោក សៅ គីមស៊ុង។**

**សកម្មភាព១.៣៖** ក្រុមការងាររៀបចំ និងត្រៀមសម្ភារសម្រាប់ដំណើរការកម្មវិធីទស្សនកិច្ច នៅត្រឹមសប្តាហ៍ទី៤ ខែមេសា ឆ្នាំ ២០២៦ **ដឹកនាំនិងទទួលខុសត្រូវដោយ លោក ស្រិន ប៊ុនថេប។**

**គោលដៅទី២៖** ធ្វើដំណើរទៅកាន់ទីតាំងដែលបានកំណត់ និងរៀបចំកម្មវិធី នៅសប្តាហ៍ទី៣ ខែឧសភា ឆ្នាំ២០២៥។

**សកម្មភាព២.1៖** យុវជនចុះចែករំលែកបទពិសោធន៍ដល់សិក្សានុសិស្សនៅថ្នាក់វិទ្យាល័យ អំពីការជ្រើសរើសជំនាញនៅថ្នាក់ឧត្តមសិក្សា នៅរសៀលថ្ងៃទីមួយ នៃកម្មវិធី នៅវិទ្យាល័យកំពង់ថ្ម ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍សមត្ថភាពរបស់យុវជនផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច **ដឹកនាំនិងទទួលខុសត្រូវដោយ លោក ស៊្រុន បូរ័ត្ន។**

**សកម្មភាព២.២៖** យុវជនចុះដាំកូនឈើចំនួន២០០ដើម នៅបរិវេណខាងមុខប្រាសាទអង្គរវត្ត នៅព្រឹកថ្ងៃទីពីរ នៃកម្មវិធី ដើម្បីលើកកម្ពស់អំពីសារប្រយោជន៍នៃបរិស្ថាន និងចុះចែកអំណោយជូនវិទ្យាល័យអប់រំពិសេសសៀមរាប នៅរសៀលថ្ងៃទីពីរ នៃកម្មវិធី ដើម្បីលើកទឹកចិត្តដល់សិស្សានុសិស្សដែលមានពិការភាពចូលរួមក្នុងការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច **ដឹកនាំនិងទទួលខុសត្រូវដោយ លោក ស៊ីលី សុវណ្ណី។**

**សកម្មភាព២.៣៖** យុវជនជិះកង់ នៅព្រឹកថ្ងៃទីបី នៃកម្មវិធី ចាប់ផ្តើមចេញពីចំណុចខាងមុខប្រាសាទអង្គរវត្ត រួចបន្តដំណើរជុំវិញ វង់តូច និងបញ្ចប់ត្រង់ចំណុចខាងមុខនៃប្រាសាទអង្គរវត្ត ដើម្បីសាមគ្គីភាព មិត្តភាព បរិស្ថានគ្មានផ្សែងបំពុល និងបញ្ជ្រាបការយល់ដឹងអំពី អរិយធម៌ វប្បធម៌ និងប្រវត្តិសាស្ត្រខ្មែរ **ដឹកនាំនិងទទួលខុសត្រូវដោយ លោក រ៉ុម ប៊ុនជា។**

**គោលដៅទី៣៖** សសេររបាយការណ៍; ការចំណាយ; និង លទ្ធផលនានានៃគម្រោង ដើម្បីដាក់ជូនទៅអ្នកពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៦។

**សកម្មភាព៣.1៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោងទាំងមូល នៅត្រឹមសប្តាហ៍ទី៤ ខែឧសភា ឆ្នាំ២០២៦ **ដឹកនាំនិងទទួលខុសត្រូវដោយ លោក សៅ គីមស៊ុង។**

**សកម្មភាព៣.២៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគម្រោង នៅត្រឹមសប្តាហ៍ទី៤ ខែឧសភា ឆ្នាំ២០២៦ **ដឹកនាំនិងទទួលខុសត្រូវដោយ លោក ស្រិន ប៊ុនថេប។**

**សកម្មភាព៣.៣៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបចំណាយ និងលទ្ធផលនៃគម្រោងជូនទៅអ្នកដែលពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី១ ខែមិថុនា ២០២៦ **ដឹកនាំនិងទទួលខុសត្រូវដោយ លោក ស៊ិន ច័ន្ទរង្សី។**

## ១.៦- សូចនាករ

សូចនាករសម្រាប់វាស់វែង នៅក្នុងគម្រោងនេះ រួមមាន៖

**គោលដៅទី១៖** បង្កើតក្រុមការងារ សិក្សាពីតម្រូវការសម្ភារនិងរៀបចំផែនការកម្មវិធីដំណើរទស្សនកិច្ចចាប់ពីសប្តាហ៍ទី១ ខែធ្នូ ឆ្នាំ២០២៥ ដល់ សប្តាហ៍ទី៣ ខែមេសា ឆ្នាំ២០២៥។

**សកម្មភាព១.1៖** បង្កើតក្រុមការងារដែលមានសមាជិក ៦ នាក់ ដើម្បីគ្រប់គ្រង និងអនុវត្តគម្រោង នៅត្រឹមសប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៥

***សូចនាករទី១.១.1៖*** *ក្រុមការងារដែលមានសមាជិក៦នាក់ ដើម្បីគ្រប់គ្រង និងអនុវត្តគម្រោង បានបង្កើតយ៉ាងយូរត្រឹមសប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២៥។*

**សកម្មភាព១.២៖** ក្រុមការងារចុះធ្វើការសិក្សា និងកំណត់ពីតម្រូវការសម្ភារសម្រាប់កម្មវិធីដំណើរទស្សនកិច្ចសិក្សា នៅត្រឹមសប្តាហ៍ទី៤ ខែធ្នូ ឆ្នាំ២០២៥។

***សូចនាករទី១.២.1៖*** *ក្រុមការងារបានចុះជួបលោកនាយកវិទ្យាល័យកំពង់ថ្ម នៅព្រឹកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥ ដើម្បីពិភាក្សាអំពីរបៀបវារៈនៃកម្មវិធីចុះចែករំលែកបទពិសោធន៍ ព្រមទាំងការសម្របសម្រួលកម្មវិធី។*

***សូចនាករទី១.២.២៖*** *ក្រុមការងារបានចុះជួបអាជ្ញាធរអេប្បូរា នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥ ដើម្បីដាក់លិខិតស្នើសុំអនុញ្ញាតការចុះធ្វើសកម្មភាពដាំកូនឈើ ជិះកង់ និងស្នើសុំកូនឈើចំនួន២០០ដើម។*

***សូចនាករទី១.២.៣៖*** *ក្រុមការងារបានចុះជួបនាយកវិទ្យាល័យអប់រំពិសេសសៀមរាប នៅរសៀលថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២៥ ដើម្បីស្វែងយល់អំពីតម្រូវការរបស់សាលា និងពិភាក្សាអំពីរបៀបវារៈនៃកម្មវិធី។*

**សកម្មភាព១.៣៖** ក្រុមការងាររៀបចំ និងត្រៀមសម្ភារសម្រាប់ដំណើរការកម្មវិធីទស្សនកិច្ច នៅត្រឹមសប្ដាហ៍ទី៤ ខែមេសា ឆ្នាំ ២០២៦។

***សូចនាករទី១.៣.1៖*** *ក្រុមការងារបានរៀបចំឡានក្រុងចំនួន២គ្រឿង ៤៥កៅអី និង១៥កៅអី នៅត្រឹមសប្ដាហ៍ទី៤ ខែមេសា ឆ្នាំ២០២៦។*

***សូចនាករទី១.៣.២៖*** *ក្រុមការងារបានរៀបចំទូរតុវាយប៉េងប៉ុងចំនួន១ និងសៀវភៅសសេរ៥០០ក្បាល សម្រាប់ប្រគល់ជូនជូនដល់វិទ្យាល័យកំពង់ថ្ម នៅត្រឹមសប្ដាហ៍ទី៣ ខែមេសា ឆ្នាំ២០២៦។*

***សូចនាករទី១.៣.៣៖*** *ក្រុមការងារបានរៀបចំទូរតុវាយប៉េងប៉ុងចំនួន២ សៀវភៅសសេរចំនួន៥០០ក្បាល សាប៊ូបោកខោអាវចំនួន១០កញ្ចប់ សម្រាប់ប្រគល់ជូនវិទ្យាល័យអប់រំពិសេស ខេត្តសៀមរាប នៅត្រឹមសប្ដាហ៍ទី៣ ខែមេសា ឆ្នាំ២០២៦។*

***សូចនាករទី១.៣.៤៖*** *ក្រុមការងារបានរៀបចំទូរសិក្ខាសាលាត្រៀមដល់យុវជន នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៦ ដើម្បីតម្រង់ទិសអំពីការចែករំលែកបទពិសោធន៍ ក៏ដូចជាត្រៀមសម្រាប់ដំណើរការកម្មវិធីទាំងមូល។*

**គោលដៅទី២៖** ធ្វើដំណើរទៅកាន់ទីតាំងដែលបានកំណត់ និងរៀបចំកម្មវិធី នៅសប្ដាហ៍ទី៣ ខែឧសភា ឆ្នាំ២០២៥។

**សកម្មភាព២.1៖** យុវជនចុះចែករំលែកបទពិសោធន៍ដល់សិក្សានុសិស្សនៅថ្នាក់វិទ្យាល័យ អំពីការជ្រើសរើសជំនាញនៅថ្នាក់ឧត្តមសិក្សា នៅរសៀលថ្ងៃទីមួយ នៃកម្មវិធី នៅវិទ្យាល័យកំពង់ថ្ម ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍សមត្ថភាពរបស់យុវជនផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច។

***សូចនាករទី២.១.1៖*** *យុវជនបានចុះចែករំលែកបទពិសោធន៍ដល់សិក្សានុសិស្សនៅថ្នាក់វិទ្យាល័យចំនួន២០០នាក់ អំពីការជ្រើសរើសជំនាញនៅថ្នាក់ឧត្តមសិក្សា រសៀលថ្ងៃទីមួយ នៃកម្មវិធី។*

***សូចនាករទី២.១.២៖*** *យុវជនបានក្រុមការងារបានផ្ដល់ជូននូវតុវាយប៉េងប៉ុងចំនួន១ និងសៀវភៅសសេរ៥០០ក្បាល ដល់វិទ្យាល័យកំពង់ថ្ម នៅរសៀលថ្ងៃទីមួយ នៃកម្មវិធី។*

***សូចនាករទី២.១.៣៖*** *ក្រុមការងារផ្ដិតយករូបភាពចំនួន១០០រូប និងវីឌីអូអនុស្សាវរីយ៍ចំនួន១០វីឌីអូ។*

**សកម្មភាព២.២៖** យុវជនចុះដាំកូនឈើចំនួន២០០ដើម នៅបរិវេណខាងមុខប្រាសាទអង្គរវត្ត នៅព្រឹកថ្ងៃទីពីរ នៃកម្មវិធី ដើម្បីលើកកម្ពស់អំពីសារប្រយោជន៍នៃបរិស្ថាន និងចុះចែកអំណោយជូនវិទ្យាល័យអប់រំពិសេសសៀមរាប នៅរសៀលថ្ងៃទីពីរ នៃកម្មវិធី ដើម្បីលើកទឹកចិត្តដល់សិស្សានុសិស្សដែលមានពិការភាពចូលរួមក្នុងការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច។

***សូចនាករទី២.២.1៖*** *យុវជនបានចុះដាំកូនឈើចំនួន២០០ដើម នៅបរិវេណខាងមុខប្រាសាទអង្គរវត្ត នៅព្រឹកថ្ងៃទីពីរ នៃកម្មវិធី។*

***សូចនាករទី២.២.២៖*** *យុវជនបានចុះចែកជូននូវតុវាយប៉េងប៉ុងចំនួន២ សៀវភៅសរសេរចំនួន៥០០ក្បាល សាប៊ូបោកខោអាវចំនួន១០កញ្ចប់ ដល់វិទ្យាល័យអប់រំពិសេស ខេត្តសៀមរាប នៅរសៀលថ្ងៃទីពីរ នៃកម្មវិធី។*

***សូចនាករទី២.២.៣៖*** *ក្រុមការងារផ្ដិតយករូបភាពចំនួន២០០រូប និងវីឌីអូអនុស្សាវរីយ៍ចំនួន២០វីឌីអូ។*

**សកម្មភាព២.៣៖** យុវជនជិះកង់ នៅព្រឹកថ្ងៃទីបី នៃកម្មវិធី ចាប់ផ្ដើមចេញពីចំណុចខាងមុខប្រាសាទអង្គរវត្ត រួចបន្តដំណើរជុំវិញ វង់តូច និងបញ្ចប់ត្រង់ចំណុចខាងមុខនៃប្រាសាទអង្គរវត្ត ដើម្បីសាមគ្គីភាព; មិត្តភាព; បរិស្ថានគ្មានផ្សែងបំពុល; និង បញ្ជ្រាបការយល់ដឹងអំពីអរិយធម៌, វប្បធម៌, និង ប្រវត្តិសាស្ត្រខ្មែរ។

***សូចនាករទី២.៣.1៖*** *យុវជនបានជិះកង់ចំនួន៦០កង់ នៅព្រឹកថ្ងៃទីបី នៃកម្មវិធី ចាប់ផ្ដើមចេញពីចំណុចខាងមុខប្រាសាទអង្គរវត្ត រួចបន្តដំណើរជុំវិញ វង់តូច និងបញ្ចប់ត្រង់ចំណុចខាងមុខនៃប្រាសាទអង្គរវត្ត។*

***សូចនាករទី២.៣.២៖*** *ក្រុមការងារផ្ដិតយករូបភាពចំនួន១០០រូប និងវីឌីអូអនុស្សាវរីយ៍ចំនួន១០វីឌីអូ។*

**គោលដៅទី៣៖** សរសេររបាយការណ៍; ការចំណាយ; និង លទ្ធផលនានានៃគម្រោង ដើម្បីដាក់ជូនទៅអ្នកពាក់ព័ន្ធ នៅត្រឹមសប្ដាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៦។

**សកម្មភាព៣.1៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោងទាំងមូល នៅត្រឹមសប្ដាហ៍ទី៤ ខែឧសភា ឆ្នាំ២០២៦។

***សូចនាករទី3.១.1៖*** *របាយការណ៍បូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោង និងវិក័យប័ត្រចំណាយ បានចងក្រង យ៉ាងយូរត្រឹមសប្ដាហ៍ទី៤ ខែឧសភា ឆ្នាំ២០២៦។*

**សកម្មភាព៣.២៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគម្រោង នៅត្រឹមសប្ដាហ៍ទី៤ ខែឧសភា ឆ្នាំ២០២៦។

***សូចនាករទី3.២.១៖*** *របាយការណ៍បូកសរុបលទ្ធផលនៃគម្រោងនិងកម្រងរូបភាពព្រម ទាំងវីឌីអូសកម្មភាព បានចងក្រងយ៉ាងយូរត្រឹមសប្ដាហ៍ទី៤ ខែឧសភា ឆ្នាំ២០២៦។*

**សកម្មភាព៣.៣៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបចំណាយ និងលទ្ធផលនៃគម្រោងជូនទៅអ្នកដែលពាក់ព័ន្ធ នៅត្រឹមសប្ដាហ៍ទី១ ខែមិថុនា ២០២៦។

***សូចនាករទី3.៣.១៖*** *របាយការណ៍បូកសរុបចំណាយ និងលទ្ធផលនៃគម្រោង បានប្រគល់ទៅកាន់អ្នកដែលពាក់ព័ន្ធ នៅត្រឹមសប្ដាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៦។*

## ១.៧- មធ្យោបាយផ្ទៀងផ្ទាត់

**គោលដៅទី១៖** បង្កើតក្រុមការងារ សិក្សាពីតម្រូវការសម្ភារនិងរៀបចំផែនការកម្មវិធីដំណើរទស្សនកិច្ចចាប់ពីសប្ដាហ៍ទី១ ខែធ្នូ ឆ្នាំ២០២៥ ដល់ សប្ដាហ៍ទី៣ ខែមេសា ឆ្នាំ២០២៥។

**សកម្មភាព១.1៖** បង្កើតក្រុមការងារដែលមានសមាជិក ៦ នាក់ ដើម្បីគ្រប់គ្រង និងអនុវត្តគម្រោង នៅត្រឹមសប្ដាហ៍ទី១ ខែតុលា ឆ្នាំ២០២៥ **ដឹកនាំនិងទទួលខុសត្រូវដោយ លោក ស៊ិន ច័ន្ទរង្សី។**

***មធ្យោបាយផ្ទៀងផ្ទាត់១.១.1៖*** *បញ្ជីឈ្មោះក្រុមការងារភ្ជាប់ជាមួយតំណែង តួនាទី និងទំនួលខុសត្រូវ។*

**សកម្មភាព១.២៖** ក្រុមការងារចុះធ្វើការសិក្សា និងកំណត់ពីតម្រូវការសម្ភារៈសម្រាប់កម្មវិធីដំណើរទស្សនកិច្ចសិក្សា នៅត្រឹមសប្ដាហ៍ទី៤ ខែធ្នូ ឆ្នាំ២០២៥ **ដឹកនាំនិងទទួលខុសត្រូវដោយ លោក សៅ គីមស៊ុង។**

***មធ្យោបាយផ្ទៀងផ្ទាត់១.២.1៖*** *បញ្ជីឈ្មោះ និងចំនួនសម្ភារៈដែលត្រូវប្រើប្រាស់សម្រាប់កម្មវិធីដំណើរទស្សនកិច្ចសិក្សា។*

**សកម្មភាព១.៣៖** ក្រុមការងាររៀបចំ និងត្រៀមសម្ភារសម្រាប់ដំណើរការកម្មវិធីទស្សនកិច្ច នៅត្រឹមសប្ដាហ៍ទី៤ ខែមេសា ឆ្នាំ ២០២៦ **ដឹកនាំនិងទទួលខុសត្រូវដោយ លោក ស្រិន ប៊ុនថេប។**

***មធ្យោបាយផ្ទៀងផ្ទាត់១.៣.1៖*** *បញ្ជីផ្ទៀងផ្ទាត់ចំនួនសម្ភារនិងរូបថតអំណោយ។*

**គោលដៅទី២៖** ធ្វើដំណើរទៅកាន់ទីតាំងដែលបានកំណត់ និងរៀបចំកម្មវិធី នៅសប្ដាហ៍ទី៣ ខែឧសភា ឆ្នាំ២០២៥។

**សកម្មភាព២.1៖** យុវជនចុះចែករំលែកបទពិសោធន៍ដល់សិក្សានុសិស្សនៅថ្នាក់វិទ្យាល័យ អំពីការជ្រើសរើសជំនាញនៅថ្នាក់ឧត្តមសិក្សា នៅរសៀលថ្ងៃទីមួយ នៃកម្មវិធី នៅវិទ្យាល័យកំពង់ថ្ម ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍សមត្ថភាពរបស់យុវជនផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច **ដឹកនាំនិងទទួលខុសត្រូវដោយ លោក ស៊្រុន បូរ័ត្ន។**

***មធ្យោបាយផ្ទៀងផ្ទាត់២.១.1៖*** *តារាងបែងចែកក្រុមធ្វើបទបង្ហាញទៅតាមថ្នាក់។*

***មធ្យោបាយផ្ទៀងផ្ទាត់២.១.២៖*** *បញ្ជីផ្ទៀងផ្ទាត់ចំនួនអំណោយដែលត្រូវប្រគល់ជូនវិទ្យាល័យកំពង់ថ្ម។*

***មធ្យោបាយផ្ទៀងផ្ទាត់២.១.៣៖*** *កម្រងរូបភាព និងវីឌីអូនៃសកម្មភាពគម្រោង។*

**សកម្មភាព២.២៖** យុវជនចុះដាំកូនឈើចំនួន២០០ដើម នៅបរិវេណខាងមុខប្រាសាទអង្គរវត្ត នៅព្រឹកថ្ងៃទីពីរ នៃកម្មវិធី ដើម្បីលើកកម្ពស់អំពីសារប្រយោជន៍នៃបរិស្ថាន និងចុះចែកអំណោយជូនវិទ្យាល័យអប់រំពិសេសសៀមរាប នៅរសៀលថ្ងៃទីពីរ នៃកម្មវិធី ដើម្បីលើកទឹកចិត្តដល់សិស្សានុសិស្សដែលមានពិការភាពចូលរួមក្នុងការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច **ដឹកនាំនិងទទួលខុសត្រូវដោយ លោក ស៊ីលី សុវណ្ណី។**

***មធ្យោបាយផ្ទៀងផ្ទាត់២.២.1៖*** *លិខិតអនុញ្ញាតសកម្មភាពដាំកូនឈើ និងប្រគល់កូនឈើចំនួន២០០ដើម អនុញ្ញាតដោយអាជ្ញាធរអប្សរា។*

***មធ្យោបាយផ្ទៀងផ្ទាត់២.២.២៖*** *បញ្ជីផ្ទៀងផ្ទាត់ចំនួនអំណោយដែលត្រូវប្រគល់ជូនវិទ្យាល័យអប់រំពិសេស ខេត្តសៀមរាប។*

***មធ្យោបាយផ្ទៀងផ្ទាត់២.២.៣៖*** *កម្រងរូបភាព និងវីឌីអូនៃសកម្មភាពគម្រោង។*

**សកម្មភាព២.៣៖** យុវជនជិះកង់ នៅព្រឹកថ្ងៃទីបី នៃកម្មវិធី ចាប់ផ្ដើមចេញពីចំណុចខាងមុខប្រាសាទអង្គរវត្ត រួចបន្តដំណើរជុំវិញ វង់តូច និងបញ្ចប់ត្រង់ចំណុចខាងមុខនៃប្រាសាទអង្គរវត្ត ដើម្បីសាមគ្គីភាព; មិត្តភាព; បរិស្ថានគ្មានផ្សែងបំពុល; និង បញ្ជ្រាបការយល់ដឹងអំពីអរិយធម៌, វប្បធម៌, និង ប្រវត្តិសាស្ត្រខ្មែរ **ដឹកនាំនិងទទួលខុសត្រូវដោយ លោក រ៉ុម ប៊ុនជា។**

***មធ្យោបាយផ្ទៀងផ្ទាត់២.៣.1៖*** *លិខិតអនុញ្ញាតសកម្មភាពជិះកង់ អនុញ្ញាតដោយអាជ្ញាធរអប្សរា។*

***មធ្យោបាយផ្ទៀងផ្ទាត់២.៣.២៖*** *កម្រងរូបភាព និងវីឌីអូនៃសកម្មភាពគម្រោង។*

**គោលដៅទី៣៖** សរសេររបាយការណ៍ ការចំណាយ និងលទ្ធផលនានានៃគម្រោង ដើម្បីដាក់ជូនទៅអ្នកពាក់ព័ន្ធ នៅត្រឹមសប្ដាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៦។

**សកម្មភាព៣.1៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោងទាំងមូល នៅត្រឹមសប្ដាហ៍ទី៤ ខែឧសភា ឆ្នាំ២០២៦ **ដឹកនាំនិងទទួលខុសត្រូវដោយ លោក សៅ គីមស៊ុង។**

***មធ្យោបាយផ្ទៀងផ្ទាត់៣.1.១៖*** *បញ្ជីរាល់ការចំណាយ និងវិក័យប័ត្រទូទាត់ប្រាក់។*

**សកម្មភាព៣.២៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគម្រោង នៅត្រឹមសប្ដាហ៍ទី៤ ខែឧសភា ឆ្នាំ២០២៦ **ដឹកនាំនិងទទួលខុសត្រូវដោយ លោក ស្រិន ប៊ុនថេប។**

***មធ្យោបាយផ្ទៀងផ្ទាត់៣.២.1៖*** *បញ្ជីឈ្មោះយុវជន បញ្ជីចំនួនអំណោយ កម្រងរូបថត និងវីឌីអូអនុស្សាវរីយ៍នៃសកម្មភាពគម្រោង។*

**សកម្មភាព៣.៣៖** ក្រុមការងារធ្វើរបាយការណ៍បូកសរុបចំណាយ និងលទ្ធផលនៃគម្រោងជូនទៅអ្នកដែលពាក់ព័ន្ធ នៅត្រឹមសប្ដាហ៍ទី១ ខែមិថុនា ២០២៦ **ដឹកនាំនិងទទួលខុសត្រូវដោយ លោក ស៊ិន ច័ន្ទរង្សី។**

***មធ្យោបាយផ្ទៀងផ្ទាត់៣.៣.1៖*** *លិខិតបញ្ជាក់ការទទួលបាននូវរបាយការណ៍ពីអ្នកដែលពាក់ព័ន្ធ។*

## ១.៨- ហានិភ័យ

ហានិភ័យ នៅក្នុងគម្រោងនេះ រួមមាន៖

**គោលដៅទី១៖** បង្កើតក្រុមការងារ សិក្សាពីតម្រូវការសម្ភារនិងរៀបចំផែនការកម្មវិធីដំណើរទស្សនកិច្ចចាប់ពីសប្ដាហ៍ទី១ ខែធ្នូ ឆ្នាំ២០២៥ ដល់ សប្ដាហ៍ទី៣ ខែមេសា ឆ្នាំ២០២៥។

**សកម្មភាព១.1៖** បង្កើតក្រុមការងារដែលមានសមាជិក ៦ នាក់ ដើម្បីគ្រប់គ្រង និងអនុវត្តគម្រោងនៅត្រឹមសប្ដាហ៍ទី១ ខែតុលា ឆ្នាំ២០២៥

***ហានិភ័យ១.1.១៖*** *សមាសភាពក្រុមការងារមិនឯកភាពក្នុងការបែងចែកតួនាទីភារកិច្ច។*

**គោលដៅទី២៖** ធ្វើដំណើរទៅកាន់ទីតាំងដែលបានកំណត់ និងរៀបចំកម្មវិធី នៅសប្ដាហ៍ទី៣ ខែឧសភា ឆ្នាំ២០២៥។

**សកម្មភាព២.1៖** យុវជនចុះចែករំលែកបទពិសោធន៍ដល់សិក្សានុសិស្សនៅថ្នាក់វិទ្យាល័យ អំពីការជ្រើសរើសជំនាញនៅថ្នាក់ឧត្ដមសិក្សា នៅរសៀលថ្ងៃទីមួយ នៃកម្មវិធី នៅវិទ្យាល័យកំពង់ថ្ម ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍សមត្ថភាពរបស់យុវជនផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច។

*ហានិភ័យ២.១.១៖ អាកាសធាតុប្រែប្រួលអាចមានភ្លៀងធ្លាក់។*

**សកម្មភាព២.២៖** យុវជនចុះដាំកូនឈើចំនួន២០០ដើម នៅបរិវេណខាងមុខប្រាសាទអង្គរវត្ត នៅព្រឹកថ្ងៃទីពីរ នៃកម្មវិធី ដើម្បីលើកកម្ពស់អំពីសារប្រយោជន៍នៃបរិស្ថាន និងចុះចែកអំណោយជូនវិទ្យាល័យអប់រំពិសេសសៀមរាប នៅរសៀលថ្ងៃទីពីរ នៃកម្មវិធី ដើម្បីលើកទឹកចិត្តដល់សិស្សានុសិស្សដែលមានពិការភាពចូលរួមក្នុងការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច។

*ហានិភ័យ២.២.១៖ អាជ្ញាធរបដិសេធ។*

*ហានិភ័យ២.២.១៖ អាកាសធាតុប្រែប្រួលអាចមានភ្លៀងធ្លាក់។*

**សកម្មភាព២.៣៖** យុវជនជិះកង់ នៅព្រឹកថ្ងៃទីបី នៃកម្មវិធី ចាប់ផ្ដើមចេញពីចំណុចខាងមុខប្រាសាទអង្គរវត្ត រួចបន្តដំណើរជុំវិញវង់តូច និងបញ្ចប់ត្រង់ចំណុចខាងមុខនៃប្រាសាទអង្គរវត្ត ដើម្បីសាមគ្គីភាព; មិត្តភាព; បរិស្ថានគ្មានផ្សែងបំពុល; និង បញ្ជ្រាបការយល់ដឹងអំពី អរិយធម៌ វប្បធម៌ និងប្រវត្តិសាស្ត្រខ្មែរ។

*ហានិភ័យ២.៣.១៖ អាជ្ញាធរបដិសេធ។*

*ហានិភ័យ២.៣.២៖ អាកាសធាតុប្រែប្រួលអាចមានភ្លៀងធ្លាក់។*

## ២- ដំណើរការគម្រោង

### ២.១- រចនាសម្ព័ន្ធគ្រប់គ្រង

ការបែងចែកធនធានមនុស្សនៅក្នុងគម្រោងស្ដីពី៖ "កម្មវិធីដំណើរទស្សនកិច្ចសិក្សា ក្រោមប្រធានបទ "សាមគ្គីភាពរបស់យុវជន ឆ្ពោះទៅរកវឌ្ឍនភាពសង្គម" នេះ មានសមាសភាពដូចខាងក្រោម៖

**ក- ប្រធានគម្រោង** មានកាតព្វកិច្ច និង ទំនួលខុសត្រូវដូចជា៖

- គ្រប់គ្រង; ដឹកនាំ; និង សម្របសម្រួលក្រុមការងារ ព្រមទាំង ភាគីពាក់ព័ន្ធក្នុងគម្រោងទាំងមូល។
- អនុម័តផែនការនានា (ហិរញ្ញវត្ថុ និងផែនការអនុវត្ត) និងត្រួតពិនិត្យ វាយតម្លៃលទ្ធផលគម្រោង។

**ខ- ផ្នែករៀបចំផែនការ** មានកាតព្វកិច្ច និង ទំនួលខុសត្រូវដូចជា៖

- បែកចែកភារកិច្ចការងារ និងរៀបចំកាលវិភាគការងារសម្រាប់សមាជិក។
- តាមដាន និងធ្វើរបាយការណ៍ អំពីវឌ្ឍនភាពនៃគម្រោង ទៅកាន់ប្រធានគម្រោង។

**គ- ផ្នែកហិរញ្ញវត្ថុ** មានកាតព្វកិច្ច និង ទំនួលខុសត្រូវដូចជា៖

- រៀបចំ និងតាមដានផែនការថវិកា ព្រមទាំងការចំណាយផ្សេងៗ របស់គម្រោង។
- ត្រួតពិនិត្យ និងរៀបចំរបាយការណ៍ថវិកា និងចំណាយជាប្រចាំ ទៅកាន់ប្រធានគម្រោង។

**ឃ- ផ្នែកទំនាក់ទំនង និង សហប្រតិបត្តិការ** មានកាតព្វកិច្ច និង ទំនួលខុសត្រូវដូចជា៖

- ជាភ្នាក់ងារទំនងទំនងទៅកាន់អាជ្ញាធរមូលដ្ឋាន និងដៃគូសហការនានា។
- ទាក់ទង និងផ្សព្វផ្សាយព័ត៌មានសប្បុរសធម៌ ព្រមទាំងប្រមូលប្រាក់ឧបត្ថម្ភ។

**ង- ផ្នែកភស្តុភារ** មានកាតព្វកិច្ច និង ទំនួលខុសត្រូវដូចជា៖

- រៀបចំបរិក្ខារ/សម្ភារៈ; គ្រប់គ្រងការដឹកជញ្ជូន; និង សម្របសម្រួលកក់ទីតាំង។

**ច- ផ្នែកកិច្ចការទូទៅ** មានកាតព្វកិច្ច និង ទំនួលខុសត្រូវដូចជា៖

- រៀបចំ និងគ្រប់គ្រងកម្មវិធីសម្រាប់ដំណើរទស្សនកិច្ចទាំងមូល។

### ២.២- ការរៀបចំអង្គភាពលេខ

អង្គការលេខសម្រាប់គ្រប់គ្រង លើការអនុវត្តន៍គម្រោងស្តីអំពី កម្មវិធីដំណើរទស្សនកិច្ចសិក្សា ក្រោមប្រធានបទ "សាមគ្គីភាពរបស់យុវជន ឆ្ពោះទៅរកវឌ្ឍនភាពសង្គម" ត្រូវបានរៀបរៀងឡើងដូចខាងក្រោម៖



ប្រធានគម្រោង

**សុិន ច័ន្ទរង្សី**

លេខទូរស័ព្ទ៖ +855 97 2112 566
អ៊ីម៉ែល៖ sinchannrangsey@gmail.com



ប្រធានផ្នែកភស្តុភារ

**ស៊ីលី សុវណ្ណនី**

លេខទូរស័ព្ទ៖ +855 97 3700 540
អ៊ីម៉ែល៖ sovannysily1605@gmail.com



ប្រធានផ្នែកទំនាក់ទំនង និង សហប្រតិបត្តិការ

**ស្រ៊ុន បូរ័ត្ន**

លេខទូរស័ព្ទ៖ +855 86 9090 44
អ៊ីម៉ែល៖ srunboroth@gmail.com



ប្រធានផ្នែករៀបចំផែនការ

**ស្រិន ប៊ុនថេប**

លេខទូរស័ព្ទ៖ +855 97 7300 450
អ៊ីម៉ែល៖ bunthapsrinn@gmail.com



ប្រធានផ្នែកហិរញ្ញវត្ថុ

**សៅ គីមស៊ុង**

លេខទូរស័ព្ទ៖ +855 70 7040 64
អ៊ីម៉ែល៖ kimsorngsao@gmail.com



ប្រធានផ្នែកកិច្ចការទូទៅ

**រ៉ុម ប៊ុនធា**

លេខទូរស័ព្ទ៖ +855 10 318 214
អ៊ីម៉ែល៖ rombunthea622@gmail.com

**អនុម័តដោយ**



សុិន ច័ន្ទរង្សី

**រៀបរៀងដោយ**



ស្រិន ប៊ុនថេប

## ២.៣- ការប្រើប្រាស់ពេលវេលា

ការប្រើប្រាស់ពេលវេលាសម្រាប់គម្រោង បានរៀបចំដូចខាងក្រោម៖

| ល.រ. | សកម្មភាពការងារ | រយៈពេល | ថ្ងៃចាប់ផ្តើម | ថ្ងៃបញ្ចប់ |
|---|---|---|---|---|
| ១ | **គម្រោងស្តីពី៖ កម្មវិធីដំណើរទស្សនកិច្ចសិក្សា ក្រោមប្រធានបទ "សាមគ្គីភាពរបស់យុវជន ឆ្ពោះទៅរកវឌ្ឍនភាពសង្គម"** | **១៨៩ ថ្ងៃ** | **១ ធ្នូ ២០២៥** | **៧ មិថុនា ២០២៥** |
| ២ | **គោលដៅទី១៖ បង្កើតក្រុមការងារ សិក្សាពីតម្រូវការសម្ភារនិងរៀបចំផែនការកម្មវិធីដំណើរទស្សនកិច្ចចាប់ពីសប្តាហ៍ទី១ ខែធ្នូ ឆ្នាំ២០២៥ ដល់ សប្តាហ៍ទី៣ ខែមេសា ឆ្នាំ២០២៥។** | ១៦៨ ថ្ងៃ | ១ ធ្នូ ២០២៥ | ២៤ មេសា ២០២៦ |
| ៣ | សកម្មភាព១.១៖ បង្កើតក្រុមការងារដែលមានសមាជិក ៦ នាក់ ដើម្បីគ្រប់គ្រង និងអនុវត្តគម្រោង នៅត្រឹមសប្តាហ៍ទី ១ ខែធ្នូ ឆ្នាំ២០២៥ | ៦ ថ្ងៃ | ១ ធ្នូ ២០២៥ | ៦ ធ្នូ ២០២៥ |
| ៤ | សកម្មភាព១.២៖ ក្រុមការងារចុះធ្វើការសិក្សា និងកំណត់ពីតម្រូវការសម្ភារសម្រាប់កម្មវិធីដំណើរទស្សនកិច្ចសិក្សា នៅត្រឹមសប្តាហ៍ទី៤ ខែធ្នូ ឆ្នាំ២០២៥។ | ២៤ ថ្ងៃ | ៨ ធ្នូ ២០២៥ | ៣១ ធ្នូ ២០២៥ |
| ៥ | សកម្មភាព១.៣៖ ក្រុមការងាររៀបចំ និងត្រៀមសម្ភារសម្រាប់ដំណើរការកម្មវិធីទស្សនកិច្ច នៅត្រឹមសប្តាហ៍ទី៤ ខែមេសា ឆ្នាំ ២០២៦។ | ១១៦ ថ្ងៃ | ៥ មករា ២០២៦ | ៣០ មេសា ២០២៦ |
| ៦ | **គោលដៅទី២៖ ធ្វើដំណើរទៅកាន់ទីតាំងដែលបានកំណត់ និងរៀបចំកម្មវិធី នៅសប្តាហ៍ទី៣ ខែឧសភា ឆ្នាំ២០២៥។** | **៧ ថ្ងៃ** | **១៨ ឧសភា ២០២៦** | **២៤ ឧសភា ២០២៦** |
| ៧ | សកម្មភាព២.១៖ យុវជនចុះចែករំលែកបទពិសោធន៍ដល់សិក្សានុសិស្សនៅថ្នាក់វិទ្យាល័យ អំពីការជ្រើសរើសជំនាញនៅថ្នាក់ឧត្តមសិក្សា នៅសៀលថ្ងៃទីមួយ នៃកម្មវិធី នៅវិទ្យាល័យកំពង់ថ្ម ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍សមត្ថភាពរបស់យុវជនផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច។ | ៧ ថ្ងៃ | ១៨ ឧសភា ២០២៦ | ២៤ ឧសភា ២០២៦ |
| ៨ | សកម្មភាព២.២៖ យុវជនចុះដាំកូនឈើចំនួន២០០ដើម នៅបរិវេណខាងមុខប្រាសាទអង្គរវត្ត នៅព្រឹកថ្ងៃទីពីរ នៃកម្មវិធី ដើម្បីលើកកម្ពស់អំពីសារប្រយោជន៍នៃបរិស្ថាន និងចុះចែកអំណោយជូនវិទ្យាល័យអប់រំពិសេសសៀមរាប នៅរសៀលថ្ងៃទីពីរ នៃកម្មវិធី ដើម្បីលើកទឹកចិត្តដល់សិស្សានុសិស្សដែលមានពិការភាពចូលរួមក្នុងការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច។ | ៧ ថ្ងៃ | ១៨ ឧសភា ២០២៦ | ២៤ ឧសភា ២០២៦ |
| ៩ | សកម្មភាព២.៣៖ យុវជនជិះកង់ នៅព្រឹកថ្ងៃទីបី នៃកម្មវិធី ចាប់ផ្តើមចេញពីចំណុចខាងមុខប្រាសាទអង្គរវត្ត រួចបន្តដំណើរជុំវិញ វង់តូច និងបញ្ចប់ត្រង់ចំណុចខាងមុខនៃប្រាសាទអង្គរវត្ត ដើម្បីសាមគ្គីភាព មិត្តភាព បរិស្ថានគ្មានផ្សែងបំពុល និងបញ្ជ្រាបការយល់ដឹងអំពី អរិយធម៌ វប្បធម៌ និងប្រវត្តិសាស្ត្រខ្មែរ។ | ៧ ថ្ងៃ | ១៨ ឧសភា ២០២៦ | ២៤ ឧសភា ២០២៦ |
| ១០ | **គោលដៅទី៣៖ សសេរបាយការណ៍ ការចំណាយ និងលទ្ធផលនានានៃគម្រោង ដើម្បីដាក់ជូនទៅអ្នកពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៦។** | **១៤ ថ្ងៃ** | **២៥ ឧសភា ២០២៦** | **៦ មិថុនា ២០២៦** |
| ១១ | សកម្មភាព៣.១៖ ក្រុមការងារធ្វើរបាយការណ៍បូកសរុបថវិកា ដែលបានចំណាយសម្រាប់គម្រោងទាំងមូល នៅត្រឹមសប្តាហ៍ទី៤ ខែឧសភា ឆ្នាំ២០២៦។ | ៧ ថ្ងៃ | ២៥ ឧសភា ២០២៦ | ៣១ ឧសភា ២០២៦ |
| ១២ | សកម្មភាព៣.២៖ ក្រុមការងារធ្វើរបាយការណ៍បូកសរុបនូវលទ្ធផលនានានៃគម្រោង នៅត្រឹមសប្តាហ៍ទី៤ ខែឧសភា ឆ្នាំ ២០២៦។ | ៧ ថ្ងៃ | ២៥ ឧសភា ២០២៦ | ៣១ ឧសភា ២០២៦ |
| ១៣ | សកម្មភាព៣.៣៖ ក្រុមការងារធ្វើរបាយការណ៍បូកសរុបចំណាយ និងលទ្ធផលនៃគម្រោងជូនទៅអ្នកដែលពាក់ព័ន្ធ នៅត្រឹមសប្តាហ៍ទី១ ខែមិថុនា ២០២៦។ | ៧ ថ្ងៃ | ១ មិថុនា ២០២៦ | ៧ មិថុនា ២០២៦ |



## ២.៤- ការប្រើប្រាស់ធនធានគម្រោង

| ដំណាក់កាល | ល.រ | បរិយាយការចំណាយ | ឯកតា | បរិមាណ | តម្លៃក្នុងមួយឯកតា | តម្លៃសរុប | សម្គាល់ |
|---|---|---|---|---|---|---|---|
| មុនពេលកម្មវិធី | 1 | ផ្នែកផ្សព្វផ្សាយ | ឈុត | 1 | $200.00 | $200.00 | ប្រភពថវិកាទី២ |
| | 2 | ថ្លៃចុះសិក្សាទីតាំង | ដង | 2 | $100.00 | $200.00 | ប្រភពថវិកាទី២ |
| | 3 | អាវយឺត | នាក់ | 50 | $4.00 | $200.00 | ប្រភពថវិកាទី២ |
| **សរុបរង** | | | | | | $600.00 | |
| អំឡុងពេលកម្មវិធី | 4 | ថ្លៃស្នាក់នៅ សម្រាប់យប់ទី១ | តង់ | 25 | $15.00 | $375.00 | ប្រភពថវិកាទី១ |
| | 5 | ថ្លៃស្នាក់នៅ សម្រាប់យប់ទីពីរ | យប់ | 17 | $40.00 | $680.00 | ប្រភពថវិកាទី១ |
| | 6 | ថ្លៃស្នាក់នៅ សម្រាប់យប់ទីបី | យប់ | 17 | $40.00 | $680.00 | ប្រភពថវិកាទី១ |
| | 7 | អាហារ សម្រាប់ថ្ងៃទី១ | | | | | |
| | | 6.1 អាហារពេលព្រឹក | នាក់ | 50 | $2.50 | $125.00 | ប្រភពថវិកាទី២ |
| | | 6.2 អាហារថ្ងៃត្រង់ | នាក់ | 50 | $5.00 | $250.00 | ប្រភពថវិកាទី២ |
| | | 6.3 អាហារពេលល្ងាច | នាក់ | 50 | $7.00 | $350.00 | ប្រភពថវិកាទី២ |
| | 8 | អាហារ សម្រាប់ថ្ងៃទី២ | | | | | |
| | | 7.1 អាហារពេលព្រឹក | នាក់ | 50 | $2.50 | $125.00 | ប្រភពថវិកាទី១ |
| | | 7.2 អាហារថ្ងៃត្រង់ | នាក់ | 50 | $5.00 | $250.00 | ប្រភពថវិកាទី១ |
| | | 7.3 អាហារពេលល្ងាច | នាក់ | 50 | $7.00 | $350.00 | ប្រភពថវិកាទី១ |
| | 9 | អាហារ សម្រាប់ថ្ងៃទី៣ | | | | | |
| | | 8.1 អាហារពេលព្រឹក | នាក់ | 50 | $2.50 | $125.00 | ប្រភពថវិកាទី២ |
| | | 8.2 អាហារថ្ងៃត្រង់ | នាក់ | 50 | $5.00 | $250.00 | ប្រភពថវិកាទី២ |
| | | 8.3 អាហារពេលល្ងាច | នាក់ | 50 | $7.00 | $350.00 | ប្រភពថវិកាទី២ |
| | 10 | អាហារ សម្រាប់ថ្ងៃទី៤ | | | | | |
| | | 9.1 អាហារពេលព្រឹក | នាក់ | 50 | $2.50 | $125.00 | ប្រភពថវិកាទី១ |
| | | 9.2 អាហារថ្ងៃត្រង់ | នាក់ | 50 | $5.00 | $250.00 | ប្រភពថវិកាទី១ |
| | 11 | ភេសជ្ជៈ និងទឹកសុទ្ធ | | | | | |
| | | 10.1 ទឹកសុទ្ធ | កេស | 30 | $3.00 | $90.00 | ប្រភពថវិកាទី១ |
| | | 10.2 ទឹកក្រូច | កេស | 16 | $9.00 | $144.00 | ប្រភពថវិកាទី១ |
| | 12 | ចំណាយសម្រាប់កម្មវិធី | | | | | |
| | | 11.1 កម្មវិធីនៅវិទ្យាល័យកំពង់ថ្ម | ឈុត | 1 | $270.00 | $270.00 | ប្រភពថវិកាទី៣ |
| | | 11.2 កម្មវិធីដាំកូនឈើ | ឈុត | 200 | $1.00 | $200.00 | ប្រភពថវិកាទី៣ |
| | | 11.3 កម្មវិធីនៅវិទ្យាល័យអប់រំពិសេសសៀមរាប | ឈុត | 1 | $300.00 | $330.00 | ប្រភពថវិកាទី៣ |
| | | 11.4 កម្មវិធីជិះកង់ | គ្រឿង | 50 | $4.60 | $230.00 | ប្រភពថវិកាទី៣ |
| | 13 | ឡានក្រុង | គ្រឿង | 2 | $500.00 | $1;000.00 | ប្រភពថវិកាទី២ |
| **សរុបរង** | | | | | | $6;549.00 | |
| | 14 | ផ្សេងៗ (រដ្ឋបាល; សង្គ្រោះបឋម និងចំណាយរាយរង) | ឈុត | 1 | $350.00 | $350.00 | ប្រភពថវិកាទី២ |
| **សរុបរង** | | | | | | $350.00 | |
| | | **សរុបរួម** | | | | $7;499.00 | |

## ២.៥- ការតាមដាននិងត្រួតពិនិត្យគម្រោង

### ២.៥.១- ការតាមដានគម្រោង

ការតាមដានទៅលើសកម្មភាពដែលបានកំណត់ក្នុងការអនុវត្ត បានដំណើរការទៅតាមផែនការ និងពេលវេលាកំណត់ឬទេ ដែលត្រូវធ្វើឡើងនៅក្នុងកំឡុងពេលអនុវត្តគម្រោងដោយប្រធានផ្នែករៀបចំផែនការនៃគម្រោង។ លើសពីនេះទៅទៀត ការតាមដានគម្រោងនេះ គឺដើម្បីធានាថា ដំណើរការនៅតែរលូនទៅតាមផែនការដែលបានដាក់ចេញឱ្យអនុវត្ត។ ចំពោះការតាមដានគម្រោង នឹងត្រូវប្រើប្រាស់កញ្ចប់ថវិកាផ្ទាល់ខ្លួនដោយចាត់ទុកជាសកម្មភាពស្ម័គ្រចិត្តសម្រាប់គម្រោង។

### ២.៥.២- ការវាយតម្លៃគម្រោង

ការវាយតម្លៃគម្រោង នឹងត្រូវធ្វើឡើងនៅចុងបញ្ចប់នៃគម្រោង ដោយប្រធានគម្រោងផ្ទាល់។ ក្នុងន័យនេះ ប្រធានគម្រោងនឹងដឹកនាំកិច្ចប្រជុំត្រួតពិនិត្យ និងវាយតម្លៃ ដែលកិច្ចប្រជុំនេះត្រូវមានសមាសភាពក្រុមការងារនៃគម្រោងទាំងអស់ ដើម្បីវាយតម្លៃទៅលើលទ្ធផលនៃសកម្មភាព ថាបានឆ្លើយតបទៅតាមគោលបំណងនិងការរំពឹងទុករបស់គម្រោងនេះ។ ជាមួយគ្នានេះ ការតាមដាននៅគ្រប់ដំណាក់កាលទាំងអស់នៃគម្រោង នឹងត្រូវបានកត់ត្រាទុកជាឯកសារ និងវាស់ស្ទង់នូវកម្រិតពេញចិត្ត និងទាន់ពេលវេលានៃសកម្មភាពនីមួយៗ តាមពីការចាប់ផ្តើមគម្រោងរហូតដល់បញ្ចប់គម្រោង។ ចំពោះការវាយតម្លៃគម្រោងនឹងត្រូវប្រើប្រាស់កញ្ចប់ថវិការផ្ទាល់ខ្លួនរបស់ប្រធានគម្រោង និងក្រុមការងារ ដោយចាត់ទុកជាសកម្មភាពស្ម័គ្រចិត្តសម្រាប់គម្រោង។

### ២.៥.៣- ការតាមដានបន្ត

ការតាមដានបន្ត ត្រូវធ្វើឡើងនៅរយៈពេល មួយខែ បន្ទាប់ពីគម្រោងត្រូវបានបញ្ចប់ ដោយប្រធានគម្រោង ដើម្បីតាមដានមើលនូវប្រសិទ្ធិភាព និងនិរន្តភាពនៃគម្រោងដែលបានអនុវត្ត អាចជះឥទ្ធិពលកម្រិតណាទៅលើស្មារតីសាមគ្គីភាព និងការយល់ដឹងអំពីបរិស្ថាន ព្រមទាំងវប្បធម៌របស់យុវជនដែលជាក្រុមគោលដៅ។ ចំពោះការតាមដានបន្តនឹងត្រូវប្រើប្រាស់កញ្ចប់ថវិកាផ្ទាល់ខ្លួនរបស់ប្រធានគម្រោង ដោយចាត់ទុកជាសកម្មភាពស្ម័គ្រចិត្តសម្រាប់គម្រោង។

## ២.៦- ការបញ្ចប់គម្រោង

### ២.៦.១- ការបញ្ចប់គម្រោង

គម្រោង កម្មវិធីដំណើរទស្សនកិច្ចសិក្សា ក្រោមប្រធានបទ "សាមគ្គីភាពរបស់យុវជន ឆ្ពោះទៅរកវឌ្ឍនភាពសង្គម" ទៅកាន់ខេត្តកំពង់ធំ និងខេត្តសៀមរាប មានរយៈពេល ១៨៩ថ្ងៃ ដោយគិតចាប់ពីសប្តាហ៍ទី១ ខែធ្នូ ឆ្នាំ២០២៥ ដល់សប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៦។ គម្រោងសប្បុរសធម៌នេះ បានសម្រេចគោលបំណងក្នុងការ

លើកកម្ពស់ការចូលរួមរបស់យុវជនក្នុងការការពារបរិស្ថាន និងអភិវឌ្ឍន៍សង្គមស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ តាមរយៈការរៀបចំ ដោយមានផែនការ ការចូលរួមយ៉ាងសកម្មពីអ្នកពាក់ព័ន្ធ និងការអនុវត្តប្រកបដោយប្រសិទ្ធភាព ក្រុមការងារគម្រោងនឹងទទួលបាននូវបទពិសោធន៍ និងចំណេះដឹង ក្នុងការធ្វើផែនការគម្រោង រៀបចំចាត់ចែងភារកិច្ច ទំនួលខុសត្រូវ រួមទាំងធនធាននានា ការទំនាក់ទំនងសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធ និងការតាមដាន ព្រមទាំងវាយតម្លៃគម្រោងដោយផ្ទាល់។ ម្យ៉ាងទៀត សមាជិកគម្រោងនឹងទទួលនូវការស្វែងយល់ជាក់ស្តែងអំពីស្ថានភាពបរិស្ថាន និងការអប់រំនៅខេត្តកំពង់ធំ និងខេត្តសៀមរាប។

### ២.៦.២- ការផ្សេវនិរន្តរភាពនៃគម្រោង

ក្រោយពីគម្រោងបានបញ្ចប់ ដើម្បីជានានូវទិន្នន័យលទ្ធផលដែលប្រមូលបានពីការអនុវត្តគម្រោង ក្រុមការងារគម្រោងសម្រេចផ្ញើជូនអ្នកពាក់ព័ន្ធទាំងអស់នូវរបាយការណ៍របស់គម្រោង ដើម្បីជានាឱ្យបាននូវតម្លាភាពនៃគម្រោង។ លើសពីនេះទៅទៀត ដើម្បីជាឯកសារយោង និងព័ត៌មានទាក់ទងទៅនឹងស្ថានភាពជាក់ស្តែង សម្រាប់អនុវត្តជាគោលដៅសកម្មភាពនាពេលអនាគត ក្រុមការងារនឹងផ្សព្វផ្សាយរបាយការណ៍របស់គម្រោងជាសាធារណៈ នៅលើគេហទំព័រផ្លូវការក្នុងប្រព័ន្ធទំនាក់ទំនងសង្គមនានា។ ជាមួយនឹងការចែករំលែករបាយការណ៍នេះ នឹងក្លាយជាគំរូ និងបំផុសគំនិតដល់អ្នកជំនាន់ក្រោយក្នុងការរៀបចំ ព្រមទាំងអនុវត្តសកម្មភាពសប្បុរសធម៌ក្នុងសង្គមនាអនាគត។

## ៣- ការវិភាគSWOT លើដំណើរការអនុវត្តគម្រោង

គម្រោង "កម្មវិធីដំណើរទស្សនកិច្ចសិក្សា ក្រោមប្រធានបទ "សាមគ្គីភាពរបស់យុវជន ឆ្ពោះទៅរកវឌ្ឍនភាពសង្គម" គឺជាកម្មវិធីសប្បុរសធម៌ ដែលមានចូលរួមវិភាគទានពីសំណាក់យុវជន ការចូលរួមពីសំណាក់ក្រុមហ៊ុនដៃគូ និងសប្បុរសជនដទៃទៀត ដែលមានគោលបំណងដើម្បីលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងការការពារបរិស្ថាន និងអភិវឌ្ឍន៍សង្គមស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល តាមរយៈការចុះចែករំលែកចំណេះដឹង ការធ្វើសកម្មភាពដែលបង្ហាញអំពីការចូលរួមថែរក្សា ការពារបរិស្ថានដែលរួមមានការដាំកូនឈើ និងការជិះកង់ ព្រមទាំងការផ្តល់អំណោយសប្បុរសធម៌ជាសម្ភារៈសិក្សាដែលចាំបាច់ដល់សាលារៀន។ ជាមួយគ្នានេះដែរ ក្នុងការអភិវឌ្ឍន៍គម្រោង ការវិភាគSWOT លើដំណើរការអនុវត្តគម្រោងរួមមានដូចខាងក្រោម៖

### ៣.១- ចំណុចខ្លាំង

- **ភាពច្បាស់លាស់នៃរចនាសម្ព័ន្ធ៖** ការបែងចែកភារកិច្ចជា ៦ផ្នែក (រៀបចំផែនការ; ហិរញ្ញវត្ថុ; ទំនាក់ទំនង; ឡូជីស្ទីក; និង កិច្ចការទូទៅ) ជួយឱ្យការងារមានម្ចាស់ការខ្ពស់។

- **ភាពរឹងមាំនៃឯកសារយោង៖** មានការរៀបចំលិខិតស្នើសុំ និងលិខិតអនុញ្ញាតពីអាជ្ញាធរបានត្រឹមត្រូវ ដែលកាត់បន្ថយភាពរអាក់រអួលផ្នែកច្បាប់ និងរដ្ឋបាល។
- **ស្មារតីក្រុម៖** សមាជិកជាសិស្សមន្ត្រីជាន់ខ្ពស់ ជំនាន់ទី១៣ ដែលមានចំណេះដឹង និងឆន្ទៈខ្ពស់ក្នុងការចូលរួមជួយសង្គម។
- **តម្លាភាព៖** ការកំណត់សូចនាករវាស់វែងច្បាស់លាស់សម្រាប់គ្រប់សកម្មភាព ងាយស្រួលក្នុងការធ្វើរបាយការណ៍ជូនម្ចាស់ជំនួយ។

### ៣.២- ចំណុចខ្សោយ

- **ការពឹងផ្អែកលើការស្ម័គ្រចិត្ត៖** ដោយសារសមាជិកគ្រប់រូបសុទ្ធតែមានភារកិច្ចរៀងៗខ្លួន ការប្រមូលផ្តុំគ្នាក្នុងពេលតែមួយអាចមានការលំបាក។
- **ថវិកាមានកម្រិត៖** ការពឹងផ្អែកលើការកៀរគរថវិកាក្នុងរយៈពេលខ្លី អាចជួបបញ្ហាប្រសិនបើមិនទទួលបានការឧបត្ថម្ភតាមការរំពឹងទុក។
- **សមាមាត្រអ្នកដឹកនាំ និងអ្នកចូលរួម៖** សមាជិកបង្គោល ៦នាក់ គ្រប់គ្រងយុវជន ៥០នាក់ គឺជាបន្ទុកធ្ងន់ក្នុងការមើលការខុសត្រូវឱ្យបានសព្វគ្រប់ជ្រុងជ្រោយ។

### ៣.៣- ឱកាស

- **ការគាំទ្រពីគោលនយោបាយរដ្ឋ៖** គម្រោងស្របតាមយុទ្ធសាស្ត្របញ្ចកោណ និងគោលនយោបាយជាតិអភិវឌ្ឍន៍យុវជន ដែលងាយនឹងទទួលបានការគាំទ្រ។
- **ទំនោរនៃការចូលរួមការងារសង្គម៖** បច្ចុប្បន្នយុវជន និងក្រុមហ៊ុនឯកជនមានការចាប់អារម្មណ៍ខ្លាំងលើការងារបរិស្ថាន និងការងារសប្បុរសធម៌។
- **បច្ចេកវិទ្យាផ្សព្វផ្សាយ៖** អាចប្រើប្រាស់បណ្តាញសង្គមដើម្បីផ្សព្វផ្សាយលទ្ធផលគម្រោង។

### ៣.៤- ការគំរាមកំហែង

- **អាកាសធាតុមិនអំណោយផល៖** ភ្លៀងធ្លាក់អាចបង្អាក់សកម្មភាពជិះកង់ និងការដាំកូនឈើ។
- **ហានិភ័យសុវត្ថិភាពផ្លូវថ្នល់៖** ការធ្វើដំណើរជាក្រុមធំទៅកាន់ខេត្តសៀមរាប និងកំពង់ធំ អាចជួបបញ្ហាចរាចរណ៍ ឬការរអាក់រអួលនៃមធ្យោបាយដឹកជញ្ជូន។
- **ទំនុកចិត្តលើការគ្រប់គ្រងថវិកា៖** ភាពមិនច្បាស់លាស់ណាមួយក្នុងការចំណាយ អាចប៉ះពាល់ដល់កេរ្តិ៍ឈ្មោះក្រុមការងារ។

## សេចក្តីសន្និដ្ឋាន

ជារួមមក គម្រោងដំណើរទស្សនកិច្ចសិក្សាដែលបានរៀបចំឡើងដោយ **សិស្សមន្ត្រីជាន់ខ្ពស់ ជំនាន់ទី១៣** ក្រោមប្រធានបទ **"សាមគ្គីភាពរបស់យុវជន ឆ្ពោះទៅរកវឌ្ឍនភាពសង្គម"** គឺជាគម្រោងដែលមានលក្ខណៈយុទ្ធសាស្ត្រ និងបានសម្រេចនូវលទ្ធផលយ៉ាងត្រចះត្រចង់ ស្របតាមទិសដៅរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់តួនាទីយុវជន។ តាមរយៈការអនុវត្តតាមដំណាក់កាលនីមួយៗ ចាប់តាំងពីការរៀបចំផែនការ ការកំណត់សូចនាករវាស់វែង រហូតដល់ការគ្រប់គ្រងហានិភ័យ គម្រោងបានបង្ហាញឱ្យឃើញនូវចំណុចសំខាន់ៗដូចខាងក្រោម៖

- **ជោគជ័យនៃកិច្ចសហការ និងសាមគ្គីភាព៖** គម្រោងបានក្លាយជាវេទិកាមួយដែលបង្ហាញពីស្មារតីសាមគ្គីភាពយ៉ាងរឹងមាំរវាងសិស្សមន្ត្រី; យុវជន; និង សហគមន៍។ ការចុះចែករំលែកបទពិសោធន៍នៅវិទ្យាល័យកំពង់ថ្ម និងការគាំទ្រដល់កុមារមានពិការភាពនៅសៀមរាប គឺជាការបង្ហាញពីគុណធម៌ និងការទទួលខុសត្រូវខ្ពស់ចំពោះសង្គមជាតិ។
- **ការរួមចំណែកដល់បរិស្ថាន និងវប្បធម៌៖** សកម្មភាពដាំកូនឈើចំនួន ២០០ដើម និងការជិះកង់ជុំវិញតំបន់ប្រវត្តិសាស្ត្រអង្គរ មិនត្រឹមតែជួយដល់កិច្ចគាំពារបរិស្ថានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបញ្ជ្រាបការយល់ដឹងអំពីតម្លៃអរិយធម៌ខ្មែរដល់យុវជនជំនាន់ក្រោយ។
- **ប្រសិទ្ធភាពនៃការគ្រប់គ្រងគម្រោង៖** បើទោះបីជាមានការប្រឈមនឹងហានិភ័យមួយចំនួន ដូចជាការប្រែប្រួលអាកាសធាតុ ឬការលំបាកក្នុងការកៀគរថវិកាក៏ដោយ ប៉ុន្តែតាមរយៈរចនាសម្ព័ន្ធគ្រប់គ្រងដ៏ច្បាស់លាស់របស់ក្រុមការងារ បានធ្វើឱ្យគម្រោងដំណើរការទៅដោយរលូន គ្មានបញ្ហាធ្ងន់ធ្ងរណាមួយកើតឡើងឡើយ។

នេះមិនត្រឹមតែផ្តល់ជាសម្ភារៈ និងចំណេះដឹងដល់សហគមន៍គោលដៅប៉ុណ្ណោះទេ ប៉ុន្តែវាគឺជាបទពិសោធន៍ដ៏មានតម្លៃបំផុតសម្រាប់សិស្សមន្ត្រីជាន់ខ្ពស់ ក្នុងការអភិវឌ្ឍជំនាញដឹកនាំ; ជំនាញទំនាក់ទំនង; និងការងារជាក្រុម។ ទាំងអស់នេះគឺជាទុនដ៏សំខាន់ ដើម្បីក្លាយជាមន្ត្រីរាជការដែលប្រកបដោយ វិន័យ គុណភាព គុណធម៌ និងនវានុវត្តន៍ ដើម្បីបម្រើសង្គមជាតិ និងរួមចំណែកដល់វឌ្ឍនភាពនៃប្រទេសជាតិទៅថ្ងៃអនាគត។